ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង

# Community Participation in Education at Primary School in Svay Rieng Province

ដោយ/**By**

**ពៅ ស្រីម៉ៅ**

**POEV SREYMAO**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០

ឯកទេស ៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២៣

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង

# Community Participation in Education at Primary School in Svay Rieng Province

ដោយ

**ពៅ ស្រីម៉ៅ**

POEV SREYMAO

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០

ឯកទេស ៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២៣

គ្រូណែនាំគោល ៖ បណ្ឌិត អ៊ឹម គឿន

គ្រូណែនាំរង ៖ បណ្ឌិត សោន វណ្ណៈ

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

នាងខ្ញុំ **ពៅ ស្រីម៉ៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី១០ ឯកទេស**គ្រប់គ្រងអប់រំ** នៃវិទ្យាស្ថានជាតិអប់រំ។

សូមធ្វើការអះអាងថា ខ្លឹមសារក្នុងនិក្ខេបបទស្តីពី **«ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង»** គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំពិតៗ ដោយមិនបានក្លែងបន្លំ ឬពាក់ព័ន្ធជាមួយនឹងនិក្ខេបបទអ្នកដទៃទេ ក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីទទួលបានសញ្ញាបត្រ។ ទិន្នន័យ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវ ដែលបានលើកឡើងនៅក្នុងនិក្ខេបបទនេះ គឺជាទិន្នន័យ និងលទ្ធផលថ្មី ហើយមិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងនិក្ខេបបទរបស់គេឡើយ។

នាងខ្ញុំសូមសន្យាថា និក្ខេបបទនេះមិនមានការក្លែងបន្លំ និងមិនមានការលួចចម្លងពីនិស្សិត ឬស្នាដៃអ្នកដទៃ។ ក្នុងករណីដែលវិទ្យាស្ថានជាតិអប់រំពិនិត្យឃើញថា មានករណីខាងលើកើតឡើងពិតប្រាកដមែន នាងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃសុក្រ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃ៨ ខែធ្នូ ឆ្នាំ២០២៣

ហត្ថលេខា



**ពៅ ស្រីម៉ៅ**

# លិខិតបញ្ជាក់

**បណ្ឌិត អ៊ឹម គឿន** ជាគ្រូណែនាំគោល

**បណ្ឌិត សោន វណ្ណៈ** ជាគ្រូណែនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោកស្រី **ពៅ ស្រីម៉ៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ នៃវិទ្យាស្ថានជាតិអប់រំ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង**» ពិតប្រាកដមែន។

ថ្ងៃ សុក្រ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែ ធ្នូ ឆ្នាំ២០២៣

ហត្ថលេខា





.........................................................

**បណ្ឌិត អ៊ឹម គឿន**

អ្នកស្រាវជ្រាវ និងគ្រូដឹកនាំថ្នាក់ក្រោយឧត្តមសិក្សា

នៃវិទ្យាស្ថានជាតិអប់រំ

.........................................................

**បណ្ឌិត សោន វណ្ណៈ**

គ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:**[illegible]**អយក.**[illegible]

(**ការសម្គាល់**)

**លិខិតឧទ្ទេសនាម**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំផ្ទេរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ក្រសួង អយក | ប្រធាន |
| ២-ឯកឧត្តម | អ៊ុង បូរាត | ក្រសួង អយក | អនុប្រធាន |
| ៣-ឯកឧត្តម | លាង សេងហាក់ | ក្រសួង អយក | សមាជិក |
| ៤-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរ.ភ្នំពេញ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | នាយកដ្ឋានបវ. | សមាជិក |
| ១២-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហ៊ិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ ៤៥០១ អយក.[illegible]

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អៃ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៊ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមាននាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ជាបឋម នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈកម្មការគ្រប់គ្រង ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មមារញឹក និងមានតម្លៃបំផុត មកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា។ ជាពិសេស នាងខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះ បណ្ឌិត **អ៊ឹម គឿន**សាស្ត្រាចារ្យដឹកនាំសរសេរនិក្ខេបបទ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការពិនិត្យវាយតម្លៃ ជួយណែនាំ និងផ្តល់យោបល់ណែនាំដល់រូបនាងខ្ញុំ ក្នុងការសរសេរនិក្ខេបបទស្តីពី «**ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង**»។ នាងខ្ញុំក៏សូមថ្លែងអំណរគុណដល់បណ្ឌិត **សោន វណ្ណារ:** សាស្ត្រាចារ្យដឹកនាំរង ដែលតែងតែផ្តល់នូវកម្លាំងចិត្ត ចំណេះដឹង ចែករំលែកបទពិសោធន៍ ហើយធ្វើឱ្យរូបខ្ញុំទទួលបានជោគជ័យនាថ្ងៃនេះ។

នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះលោកឪពុក **ពៅ តី** អ្នកម្តាយ **ម៉ុក ណារ៉ា** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងដល់រូបកូនឱ្យបានទទួលការសិក្សារហូតរូបកូនមានថ្ងៃនេះ។

នាងខ្ញុំសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រងរបស់សាលាបឋមសិក្សាទាំង១៣ ដែលបានអនុញ្ញាត និងចូលរួមសហការធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក/លោកស្រីសាស្ត្រាចារ្យ លោក លោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

ការសិក្សានេះ មានគោលបំណងសិក្សាពីមានគោលបំណងសិក្សាស្វែងយល់អំពីទម្រង់នៃការចូលរួមរបស់សហគមន៍ នៅក្នុងកម្រិតអប់រំបឋមសិក្សា និងអំពីកត្តាដែលនាំឱ្យមានការចូលរួមទាំងនោះ ។ សាលាបឋមសិក្សាចំនួន១៣សាលាត្រូវបានជ្រើសរើស ដើម្បីចុះប្រមូលទិន្នន័យនិងធ្វើការសម្ភាសន៍ជាមួយក្រុមគោលដៅ ដែលរួមមាននាយកសាលា លោកគ្រូអ្នកគ្រូ គណៈកម្មការទ្រទ្រង់សាលា មាតាបិតាសិស្ស និងព្រះចៅអធិការវត្ត ។ លទ្ធផលដែលទទួលបានពីការសម្ភាសន៍និងទិន្នន័យបានពីការបំពេញកម្រងសំណួរ បានបង្ហាញឱ្យឃើញថា ទម្រង់ និងការលើកទឹកចិត្តក្នុងការចូលរួមរបស់សហគមន៍នៅសាលាបឋមសិក្សាទាំង១៣ក្នុងក្រុងស្វាយរៀង មានលក្ខណៈស្មុគស្មាញ ហើយការចូលរួមនោះ មានទម្រង់ផ្សេងៗជាច្រើន ព្រមទាំងមានកម្រិតខុសៗគ្នា។ ប៉ុន្តែការចូលរួមភាគច្រើនមានទម្រង់ជាការរួមវិភាគទានជា ថវិកាជាងការចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្តឬចូលរួមក្នុងសកម្មភាពបង្រៀននិងរៀន ។

ការស្រាវជ្រាវនេះក៏បង្ហាញផងដែរថា មិនមែនប្រជាជន គ្រប់រូបនៅក្នុងសហគមន៍បានចូលរួមក្នុងសកម្មភាពសិក្សានៅសាលាបឋមសិក្សាទាំង១៣នោះទេ ការស្រាវជ្រាវនៅបានកត់សម្គាល់ពីបញ្ហាប្រឈមមួយចំនួន ដែលរាំងស្ទះដល់ការចូលរួមរបស់សហគមន៍ក្នុងការអប់រំផងដែរ ។ លទ្ធផលក៏បានបង្ហាញថាទម្រង់នៃការចូលរួមរបស់សហគមន៍មានបីប្រភេទគឺ (១) ការចូលរួមចំណែកឧបត្ថម្ភដល់សាលារៀន (២) ការចូលរួមនៅតាមសាលា (៣) ការចូលរួមសកម្មភាពអប់រំនៅផ្ទះ ។ ម្យ៉ាងទៀតការយល់ដឹងរបស់មាតាបិតាសិស្សពីតម្លៃ និងប្រយោជន៍នៃការអប់រំ ព្រមទាំងសេចក្ដីប្រាថ្នារបស់ពួកគេ ក្នុងការចង់ឱ្យអនាគតកូនចៅខ្លួនបានប្រសើរ គឺជាកត្តាពី ខាងក្នុងដ៏សំខាន់ដែលបានជំរុញពួកគេឱ្យចូលរួម ។ លើសពីនេះទៅទៀត ទំនុកចិត្ត និងតម្លាភាពក្នុង ការដឹកនាំចាត់ចែងរបស់សាលារៀន គឺជាកត្តាពីខាងក្រៅដែលនាំឱ្យមានការចូលរួមពីសំណាក់សហគមន៍ ផងដែរ ។ របាយការណ៍នេះត្រូវបញ្ចប់ ដោយអ្នកសិក្សាលើកឡើងពីការឆ្លុះបញ្ចាំងរបស់គាត់និងបានបង្ហាញពីគំនិតសម្រាប់ពិចារណារក្នុងការកសាងគោលនយោបាយ ឬកម្មវិធី ក្នុងការជំរុញការចូលរួម របស់សហគមន៍ឱ្យកាន់តែមានប្រសិទ្ធភាព ។ ការសិក្សានេះ បានផ្ដល់អត្ថប្រយោជន៍ជាច្រើនដល់ដំណើរអភិវឌ្ឍសាលារៀន និងបទពិសោធន៍ល្អៗចំពោះនាយក/នាយិកា លោក

គ្រូ អ្នកគ្រូនិងគណៈកម្មការទ្រទ្រង់សាលា។ ការសិក្សានេះ ក៏បានជួយលើកកម្ពស់គុណភាពអប់រំ និងការធានាគុណភាព និងប្រសិទ្ធភាពអប់រំតាមរយៈការចូលរួមរបស់សហគមន៍នៅសាលាបឋមសិក្សាក្នុងខេត្តស្វាយរៀង។ អ្នកស្រាវជ្រាវនិងរីករាយជាមួយការអានហើយបន្តស្រាវជ្រាវបន្ថែមទៀតដើម្បីបង្កើនការចូលរួមនិងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។

## Abstract

The purpose of this study was to find out about the forms of community participation in primary education and the factors that lead to such participation. Thirteen primary schools were selected to collect data and conduct interviews with target groups, including principals, teachers, school support committees, parents and pagoda chaplains. The results of the interviews and the data from the completion of the questionnaire show that the forms and motivations of community participation in the 13 primary schools in Svay Rieng City are complex, and that the participation forms vary and has different levels. But most participation takes the form of financial contributions rather than participation in decision-making or participation in teaching and learning activities.

The study also showed that not all people in the community participated in the 13 primary school learning activities, the study noted some of the challenges that hinder community participation in education. Well. The results also show that there are three types of community participation: (1) school contribution, (2) school participation, and (3) home participation. On the other hand, parents' understanding of the value and benefits of education, as well as their desire for a better future for their children, is an important internal factor that motivates them to participate. In addition, trust and transparency in school leadership are external factors that lead to community involvement. This report concludes with the scholar highlighting his or her reflections and presenting ideas for consideration in formulating policies or programs to promote community involvement more effectively.

This study has provided many benefits to the school development process and good experiences for principals / teachers, teachers and school support committees. The study also helped improve the quality of education and ensure the quality and effectiveness of education through community participation in primary schools in Svay Rieng province. Researchers will enjoy reading and continue to do more research to increase participation and development of education in Cambodia.

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន.....................................................i

លិខិតបញ្ជាក់ ....................................................................................i i

លិខិតឧទ្ទេសនាម ...............................................................................i i i

លិខិតថ្លែងអំណរគុណ .........................................................................v i i

មូលន័យសង្ខេប .................................................................................v i i i

Abstract ..............................................................................................x

មាតិកា....................................................................................................

xiError ! Bookmark not defined.

បញ្ជីតារាង និងរូបភាព.........................................................................xiv

បញ្ជីអក្សរកាត់ និងពាក្យបច្ចេកទេស.....................................................xv

ជំពូក១ ..................................................................................................1

សេចក្តីផ្តើម ............................................................................................1

១.១ លំនាំបញ្ហា ..................................................................................1

១.២ ចំណោទបញ្ហា.................................................................................2

១.៣ គោលបំណងស្រាវជ្រាវ .....................................................................4

១.៤ សំណួរស្រាវជ្រាវ ............................................................................4

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ...........................................................5

១.៦. ដែនកំណត់ និង វិសាលភាពនៃការសិក្សាស្រាវជ្រាវ ...............................6

១.៧ រចនាសម្ព័ន្ធនៃនិក្ខេបបទ....................................................................6

**ជំពូក២**........................................................................................8

**ការរំលឹកទ្រឹស្តី** ........................................................................................8

២.១ តើសហគមន៍ជាអ្វី? ........................................................................................8

២.២ តើការចូលរួមគឺជាអ្វី? ........................................................................................11

២.៣ តើអ្វីទៅជាការចូលរួមរបស់សហគមន៍ក្នុងការអប់រំ? ........................................................................................12

២.៤ គំរូនៃភាពជាដៃគូសហគមន៍-សាលារៀន........................................................................................13

២.៥កម្រិតនៃការចូលរួមរបស់សហគមន៍........................................................................................16

២.៦ កត្តាជំរុញសម្រាប់ការចូលរួមរបស់សហគមន៍........................................................................................16

២.៧ ភាពពាក់ព័ន្ធនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ ........................................................................................17

២.៨ ការស្រាវជ្រាវថ្មីៗនៃការចូលរួមសហគមន៍ក្នុងការអប់រំ ........................................................................................18

២.៩ ការចូលរួមរបស់សហគមន៍ក្នុងគោលនយោបាយអប់រំនៅប្រទេសកម្ពុជា ........................................................................................20

**២.៩.១ គោនយោបាយសាលាបណ្តាញនិងការចូលរួមរបស់សហគមន៍........................................................................................23**

២.៩.២ គោនយោបាយសាលាកុមារមេត្រី និងការចូលរួមរបស់សហគមន៍........................................................................................25

២.៩.៣ គោលនយោបាយសាលាជំនាន់ថ្មី និងការចូលរួមរបស់សហគមន៍ **........................................................................................25**

**ជំពូក៣**........................................................................................30

**វិធីសាស្ត្រនៃការស្រាវជ្រាវ** ........................................................................................30

៣.១ គម្រោងនៃការស្រាវជ្រាវ........................................................................................32

៣.២ ការប្រមូលទិន្នន័យ........................................................................................34

៣.៣ ឧបករណ៍ស្រាវជ្រាវ........................................................................................35

៣.៤ ការជ្រើសរើសសំណាក........................................................................................37

៣.៥ ការវិភាគទិន្នន័យ........................................................................................38

**៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ**........................................................................................38

**ជំពូក៤**........................................................................................41

**លទ្ធផលនិងការពិភាក្សា**........................................................................................41

៤.១ ទិន្នន័យព័ត៌មានទូទៅ ........................................................................................41

៤.១.១ ព័ត៌មានទូទៅរបស់គ្រូ........................................................................................42

៤.១.២ ព័ត៌មានទូទៅរបស់មាតាបិតាសិស្ស.......................................................................43

៤.២ ទម្រង់នៃការចូលរួមរបស់មាតាបិតាសិស្សក្នុងការអប់រំ.......................................................46

៤.២.១ ការវិភាគលម្អិតទៅលើទម្រង់នៃការចូលរួមរបស់មាតាបិតាសិស្សតាមសមាសភាពនីមួយៗ.......................................................................................................47

៤.២.១.១ ការវិភាគលម្អិតទៅលើទម្រង់នៃការចូលរួមរបស់មាតាបិតាសិស្សតាមបែបបរិមាណវិស័យ.......................................................................................47

៤.២.១.២ ការវិភាគលម្អិតទៅលើទម្រង់នៃការចូលរួមរបស់មាតាបិតាសិស្សតាមបែបគុណវិស័យ.......................................................................................50

៤.២.២ ការវិភាគទៅលើកត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សក្នុងការអប់រំ.......................55

៤.២.២.១ ការវិភាគលម្អិតទៅលើកត្តាជំរុញលើកទឹកចិត្តក្នុងការចូលរួមរបស់មាតាបិតាសិស្សតាមបែប បរិមាណវិស័យ.......................................................................55

៤.២.២.២ ការវិភាគលម្អិតទៅលើកត្តាជំរុញលើកទឹកចិត្តក្នុងការចូលរួមរបស់មាតាបិតាសិស្សតាមបែបគុណវិស័យ.......................................................................56

៤.២.៣ ការវិភាគលម្អិតទៅលើទម្រង់នៃការចូលរួមរបស់គ្រូបង្រៀនតាមសមាសភាពនីមួយៗ..59

៤.២.៣.១ ការវិភាគទៅលើទម្រង់នៃការចូលរួមរបស់គ្រូបង្រៀនតាមបែបបរិមាណវិស័យ.......................................................................................ៗ59

៤.២.៣.២ ការវិភាគលម្អិតទៅលើទម្រង់នៃការចូលរួមរបស់គ្រូបង្រៀនតាមបែបគុណវិស័យ.......................................................................................65

៤.២.៤ ការវិភាគលម្អិតទៅលើកត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀនក្នុងការអប់រំ.......................66

៤.២.៤.១ ការវិភាគទៅលើកត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សក្នុងការអប់រំតាមបែបបរិមាណ វិស័យ.......................................................................................66

៤.២.៤.២ ការវិភាគទៅលើកត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សក្នុងការអប់រំតាមបែបគុណវិស័យ.......................................................................................68

៤.២.៥ ការវិភាគលម្អិតទៅលើឧបសគ្គនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ...................71

៤.២.៥.១ ការវិភាគទៅលើឧបសគ្គនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំតាមបែបបរិមាណ  វិស័យ.......................................................................................71

៤.២.៥.២ ការវិភាគលម្អិតទៅលើឧបសគ្គនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំតាមបែបគុណវិស័យ.......................................................................................72

**៤.៣.ទស្សនៈយល់ឃើញអំពីការចូលរួមរបស់សហគមន៍ក្នុងការអប់រំ.......................................77**

៤.៤ ការសហការរវាងសហគមន៍ជាមួយសាលារៀន.......................................................79

៤.៥ ការពិភាក្សារួមនៃហេតុផលនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ.............................81

**សេចក្ដីសន្និដ្ឋាន និង សំណូមពរ** ........ 90

៥.១ សេចក្ដីសន្និដ្ឋាន ........ 90

៥.២ សំណូមពរ ........ 93

**ឯកសារយោង** ........ 97

**ឧបសម្ព័ន្ធ** ........ 100

**ឧបសម្ព័ន្ធ«ក»កម្រងសំណួរសម្រាប់មាតាបិតាសិស្ស** ........ 109

**ឧបសម្ព័ន្ធ«ខ»កម្រងសំណួរសម្រាប់គ្រូបង្រៀន** ........ 112

**ឧបសម្ព័ន្ធ«គ»សំណួរសម្ភាសន៍សម្រាប់នាយក** ........ 115

**ឧបសម្ព័ន្ធ«ខ»សំណួរសម្ភាសន៍សម្រាប់ព្រះចៅអធិការវត្ត** ........ 117

# បញ្ជីតារាង និងរូបភាព


រូបភាព ៤.២.២.១ ទម្រង់នៃការចូលរួមរបស់មាតាបិតាសិស្ស.................................................... ៤៦

រូបភាព១ ទម្រង់នៃការចូលរួមនៅផ្ទះរបស់មាតាបិតាសិស្ស........................................................៤៧

រូបភាព២ទម្រង់នៃការចូលរួមនៅតាមសាលារៀនរបស់មាតាបិតាសិស្ស........................................៤៨

រូបភាព៣ ទម្រង់នៃការចូលរួមបរិច្ចាកដល់សាលារៀនរបស់មាតាបិតាសិស្ស...................................៤៩

រូបភាព ៤.២.៣.១ ការវិភាគលម្អិតទៅលើកត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សចូលរួមក្នុងការអប់រំ ៥៥

រូបភាព ៤.២.៣.១ កត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សចូលរួមក្នុងការអប់រំ...............................៥៧

រូបភាព ៤.២.៤.១ ការវិភាគលម្អិតទៅលើទម្រង់នៃការចូលរួមរបស់គ្រូបង្រៀន..............................៥៩

រូបភាព១ ទម្រង់នៃការចូលរួមនៅតាមសាលារបស់គ្រូបង្រៀន....................................................៦១

រូបភាព២ ទម្រង់នៃការចូលរួមចំណែកដល់សាលារបស់គ្រូបង្រៀន..............................................៦៣

រូបភាព៣ ទម្រង់នៃការចូលរួមនៅផ្ទះរបស់គ្រូបង្រៀន..............................................................៦៤

រូបភាព ៤.២.៥.១ កត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀនចូលរួមក្នុងការអប់រំ.......................................៦៧

តារាង៣.១ គម្រោងស្រាវជ្រាវ..........................................................................................៣២

តារាង៣.៣.២ អ្នកចូលរួមសម្ភាសន៍ ..................................................................................៣៦

តារាង៣ .៤ ក្រុមគោលដៅ និងអ្នកចូលរួម ...........................................................................៣៧

តារាង៤.១.១ ព័ត៌មានទូទៅរបស់គ្រូបង្រៀន....................................................................... ៤១

តារាង៤.១.២ ព័ត៌មានទូទៅរបស់មាតាបិតាសិស្ស .................................................................៤៣

តារាង៤.២.២.១ទម្រង់នៃការចូលរួមរបស់មាតាបិតាសិស្ស .......................................................៤៧

តារាង៤.២.៣.២ កត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សចូលរួមក្នុងការអប់រំ................................ ៥៥

តារាង៤.២.៤ ទម្រង់នៃការចូលរួមរបស់គ្រូបង្រៀន ............................................................... ៦០

តារាង៤.២.៣.២ កត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀនចូលរួមក្នុងការអប់រំ........................................ ៦៥

តារាង៤.២.៦ ការវិភាគលម្អិតទៅលើឧបសគ្គនៃការចូលរួមរបស់សហគមន៍ ................................ ៧១
តារាង៤.៣ ទស្សនៈរបស់អ្នកចូលរួមស្តីពីការចូលរួមរបស់សហគមន៍ក្នុងការអប់រំ........................... ៧៤
តារាង៤.៤ ការសហការរបស់សហគមន៍ក្នុងការអប់រំ ............................................................. ៧៦
តារាង ៤.៥ កត្តាជំរុញឱ្យមានការចូលរួមពីសហគមន៍នៅក្នុងសាលារៀន....................................៧៨

# បញ្ជីអក្សរកាត់ និងពាក្យបច្ចេកទេស

- ADB : ធនាគារអភិវឌ្ឍអាស៊ី
- CFS : កម្មវិធីសាលាកុមារមេត្រី
- CS : សាលាបណ្តាញ
- NGS : សាលាជំនាន់ថ្មី
- UNICEF: មូលនិធិសង្គ្រោះកុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ ( យូនីសេហ្វ )
- KAPE : អង្គការសកម្មភាពអប់រំ នៅកម្ពុជា ( ខេប )
- NCP : គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ
- M : តម្លៃមធ្យមពិន្ទុ
- SD : គម្លាតស្តង់ដា
- SC : Student Council
- SPSS : កម្មវិធីវិភាគទិន្នន័យ
- UNESCO : United Nations Educational, Scientific and Cultural Organization
- WB : The World Bank
- CODING : ការប្រមូល ចងក្រងគំនិត និងសំយោគគំនិត

# ជំពូក១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហា

សាកលភាវូបនីយកម្មនៃការអប់រំបាននឹងកំពុងទទួលរងនូវនិន្នាការពីគ្នាទៅវិញទៅមកតាមរយៈការចូលរួមជាសហគមន៍តាមតំបន់និងទទួលយកនូវការចែករំលែកចំណេះដឹងបទពិសោធន៍លើការផ្លាស់ប្តូរនៃបរិបទអប់រំបច្ចុប្បន្នតាមស្ថានភាពនៃប្រទេសនីមួយៗលើពិភពលោក។ ការចូលរួមរបស់សហគមន៍គឺមានសារៈសំខាន់ណាស់ដើម្បីទទួលបានជោគជ័យនៃកម្មវិធីអភិវឌ្ឍន៍សហគមន៍។ គម្រោង និងកម្មវិធីអភិវឌ្ឍន៍ដែលមានការចូលរួមយ៉ាងខ្លាំងក្លាអាចបង្កើនភាពជាម្ចាស់ និងនិរន្តរភាពក្នុងការអភិវឌ្ឍន៍(Kumar,2000) និងគម្រោងនានាជួយអភិវឌ្ឍសហគមន៍ឱ្យទទួលបានជោគជ័យ។ ដូចគ្នានេះដែរការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំជួយលើកកម្ពស់ការអប់រំនិងការរៀនសូត្ររបស់កុមារ។ ការស្រាវជ្រាវបានបង្ហាញថាការចូលរួមរបស់គ្រួសារ និងសហគមន៍ក្នុងការអប់រំមានភាពវិជ្ជមានលើការសិក្សារបស់កុមារនិងអាចបង្កើនសក្តានុពលនៃការរៀនសូត្ររបស់កុមារ ដែលមានផលវិជ្ជមានក្នុងរយៈពេលវែងមកលើការសិក្សាពេញមួយជីវិតរបស់ពួកគេ(Epstein,1992,1995,2006)។

តាមការស្រាវជ្រាវ កន្លងមកបានរកឃើញពីទម្រង់និងកម្រិតនៃការចូលរួមរបស់សហគមន៍ផ្សេងៗពីគ្នាជាពិសេសក្នុងវិស័យអប់រំ (Epstein,1995 ; Ngoun,2012 ; Sanders,2001 ; Griffin&Steen,2010 ; Pak,2012)។ ការចូលរួមរបស់សហគមន៍ក្នុងការអប់រំមានទម្រង់ផ្សេងៗគ្នាជាច្រើន ប្រជាជនក្នុងសហគមន៍អាចចូលរួមតាមរយៈ ហិរញ្ញវត្ថុ សម្ភារៈ កម្លាំងពលកម្ម និងគំនិតនានា។ ការសហការរវាងសហគមន៍និងសាលារៀនដើម្បីសម្រេចបានតាមគោលដៅអប់រំជាតិ សហគមន៍មានតួនាទីនិងភារកិច្ច ដូចជា៖(១)ការប្រមូលកុមារឱ្យចូលរៀន (២)ស្វែងរកចំណូល និងថវិការ (៣) ការគ្រប់គ្រងថវិកា (៤)ការថែរក្សាទ្រព្យសម្បត្តិសាលារៀន (៥)ការចូលរួមសាងសង់ និងជួសជុលសាលារៀន (៦)ការបំផុសកូនចៅឱ្យទៅសាលា

រៀន (៧)ការតាមដានការសិក្សារៀនសូត្ររបស់សិស្ស (៨)ការចូលរួមកសាង អនុវត្តផែនការរបស់សាលា និងការងារតាមដានត្រួតពិនិត្យ (៩)ការពង្រឹង និងពង្រីកសមត្ថភាពយល់ដឹងអំពីការអភិវឌ្ឍសាលារៀន **(ឯកសារបំប៉ននាយកសាលារៀនបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ)**។ ដំណើរការនៃទម្រង់នៃការចូលរួមផ្សេងៗកើតឡើងមិនស្មើគ្នានិងអាស្រ័យលើភាពជាអ្នកដឹកនាំ ការយល់ដឹង និងការប្ដេជ្ញាចិត្តរបស់បុគ្គលនិងអ្នកគ្រប់គ្រងសាលា(Griffin&Steen,2010)។ ដោយសារកត្តាទាំងនេះទើបមានការស្រាវជ្រាវក្នុងសហគមន៍ដែលបានពិនិត្យមើលអំពីទម្រង់និងដំណើរការនៃការចូលរួមរបស់សហគមន៍ដែលកើតឡើង និងការគៀងគរសហគមន៍ និងភាគីពាក់ព័ន្ធឱ្យចូលរួមសហការជាមួយ។ កម្រិតដែលសហគមន៍ចូលរួមក្នុងការអប់រំនិងរបៀបផ្សេងៗនៃការចូលរួមនឹងត្រូវបានពិភាក្សាតាមរយៈការវិភាគនៃការរកឃើញ។ ការស្រាវជ្រាវនេះក៏រំពឹងថានឹងបន្ថែមចំណេះដឹង ដែលមានស្រាប់លើការចូលរួមរបស់សហគមន៍ក្នុងការអប់រំផងដែរ។ ដើម្បីរៀបចំសាលារៀនឱ្យក្លាយទៅជាសាលារៀនសហគមន៍ដើម្បីសហគមន៍ និងជាសហគមន៍ដែលបានចូលរួមអភិវឌ្ឍ ដោយផ្ដោតលើការបណ្ដុះបណ្ដាលអ្នកសិក្សាឱ្យទទួលបានលទ្ធផលសិក្សាដែលឆ្លើយតបនឹងតម្រូវការមូលដ្ឋាន និងសម្រេចបានតាមគោលដៅអប់រំជាតិ និងគោលបំណងអប់រំមូលដ្ឋានព្រមទាំងអាចធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនិងការរៀនសូត្ររបស់កុមារនៅកម្ពុជាតាមរយៈការចូលរួមរបស់សហគមន៍។

## ១.២ ចំណោទបញ្ហា

ការអប់រំ គឺជាកម្លាំងចលករដ៏សំខាន់មួយរបស់ប្រទេសកម្ពុជាដើម្បីសម្រេចបាននូវគោលដៅប្រែក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការផ្ដល់ការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្នដល់ប្រជាជនកម្ពុជាគ្រប់រូបក្រោមក្របខណ្ឌគោលការណ៍អប់រំសម្រាប់ទាំងអស់គ្នា គឺជាកិច្ចការចម្បងដែលរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងអនុវត្ត (MOEYS, 2019)។ ការចូលរួមពីស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល មាតាបិតាសិស្ស និងសហគមន៍គឺជាគន្លឹះមួយ និងកត្តាជំរុញលើកទឹកចិត្តដល់ការសិក្សារបស់កុមារ និងបង្កើនការរៀន

សូត្ររបស់ពួកគេ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងគោលនយោបាយជាតិផ្សេងទៀតត្រូវបានអនុវត្តក្នុងវិស័យអប់រំនៃប្រទេសកម្ពុជាបានរួមបញ្ចូលការចូលរួមពីសហគមន៍ ដោយបានដាក់ចេញនូវកម្មវិធីសំខាន់ផ្សេងៗរបស់ខ្លួនដើម្បីបង្កើនគុណភាពនិងភាពពាក់ព័ន្ធនៃការអប់រំក្នុងសហគមន៍។

នៅក្នុងប្រទេសកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បានផ្តួចផ្តើមបង្កើតសហគមន៍មួយដែលចូលរួមដោយគណៈកម្មាធិការទ្រទ្រង់សាលារៀន(SSC)ក្នុងប្រព័ន្ធអប់រំឆ្នាំ១៩៩៣ (MoEYS,2012)។ គោលនយោបាយរបស់ រដ្ឋាភិបាលកម្ពុជា ចង់ឱ្យប្រជាជនកម្ពុជាក្លាយជាពលរដ្ឋពេញលេញដែលមានចំណេះដឹង ចំណេះធ្វើ បំណិន ប៉ុន្តែទាមទារឱ្យមានការចូលរួមគ្រប់រូបភាពពីសហគមន៍និងសាលារៀន។ ការធ្វើវិមជ្ឈការដោយប្រគល់នូវភាពជាម្ចាស់លើមុខងារសិទ្ធិអំណាចការទទួលខុសត្រូវលើធនធាន (ហរិញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ និងគ្រប់នាយកដ្ឋានរបស់វិស័យអប់រំ និងសាលារៀនត្រូវអនុវត្តតាមគោលការណ៍នេះ។ គោលនយោបាយនេះចាត់ទុកការចូលរួមរបស់សហគមន៍ជាអ័ក្សកណ្តាលនៃការអភិវឌ្ឍន៍ការអប់រំ។ គណៈកម្មាធិការទ្រទ្រង់សាលា សមាគមន៍ មាតាបិតា សិស្ស គ្រូ និងក្រុមប្រឹក្សាភិបាលត្រូវរួមសហការជាមួយគណៈគ្រប់គ្រងសាលាក្នុងការធ្វើផែនការការអនុវត្តការត្រួតពិនិត្យ និងការវាយតម្លៃកម្មវិធីរបស់សាលារៀន។ សហគមន៍ បង្កើនភាពសហការគ្នាពិតជាធ្វើឱ្យកិច្ចដំណើរការក្នុងសាលារៀនមានភាពរលូន និងសាងជំនឿទុកចិត្តក្នុងសហគមន៍អ្នកសិក្សាកាន់តែប្រសើរដែលរួមចំណែកធ្វើឱ្យសិស្សទទួលបានលទ្ធផលសិក្សាល្អហើយអាចទាក់ទាញការចូលរួមរបស់សហគមន៍ក្នុងការអប់រំកាន់តែច្រើនឡើង (Epstein, 2006; Bray, 1999, 2001, 2003) ។

ទោះជាយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវអំពីការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅតាមបណ្តាប្រទេសនៅអឺរ៉ុប និងប្រទេសនៅអាស៊ីដែលមានប្រាក់ចំណូលខ្ពស់និងប្រាក់ចំណូលមធ្យមដូចជានៅប្រទេសជប៉ុន ហុងកុង សិង្ហបុរីនិងកូរ៉េ ប៉ុន្តែមានចំនួនតិចនៅប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជាផងដែរ(Bray,2003; Pang,2004)។ តាមការស្រាវជ្រាវបានបង្ហាញថាវិស័យអប់រំនៅកម្ពុជាមានការសិក្សាស្រាវជ្រាវតិចតួចណាស់អំពីការចូលរួមរបស់មាតាបិតឬសហគមន៍ (Save the Children Cambodia, 2015)។ យោងទៅតាមអង្គការ Save the Children Cambodia មានតែការសិក្សាមួយចំនួនប៉ុណ្ណោះដែល

ត្រូវបានធ្វើឡើងនៅក្នុងសហគមន៍ ស្ដីពីការចូលរួមរបស់សហគមន៍ក្នុងការអប់រំរួមមាន **ងួន**(២០១១), Save the Children Cambodia (2013), UNDP (2013), Save the Children Cambodia (2014) **និង** Save the Children Cambodia (2015)។ លើសពីនេះទោះបីជារដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍អន្តរជាតិមួយចំនួន (**ដូចជាធនាគារពិភពលោក យូនីសេហ្វ យូណេស្កូ និង** ADB) បានធ្វើការស្រាវជ្រាវ ត្រួតពិនិត្យរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការអប់រំក៏ពុំសូវមានឯកសារដែលបង្ហាញពីការចូលរួមរបស់សហគមន៍ជាពិសេសការចូលរួមរបស់ក្រុមគ្រួសារក្នុងការអប់រំនោះទេ។

ដោយមើលឃើញពីភាពចាំបាច់ទៅលើការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ និងដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់របស់ក្រសួងអបរំ យុវជននិងកីឡា ក៏ដូចជាកំណែទម្រង់របស់រាជរដ្ឋាភិបាលការសិក្សាលើប្រធានបទ «**ការចូលរួមរបស់សហគមន៍ក្នុងវិស័យអបរំកម្រិតបឋមសិក្សានៅខេត្តស្វាយរៀង**» ត្រូវបានលើកយកមកពិភាក្សា ដើម្បីស្វែងយល់ពីភាពវិជ្ជមាន រឺភាពរាំងស្ទះក្នុងការចូលរួមរបស់សហគមន៍ក្នុងខេត្តស្វាយរៀង និងផ្ដល់កិច្ចពិភាក្សាលើដំណោះស្រាយ រឺយន្តការដែលមានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការអប់រំ។ ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ បានផ្ដល់សារៈសំខាន់ដល់សហគមន៍ សាលារៀន បន្ដយកចិត្តទុកដាក់លើសហការចូលរួម និងធានាបាននូវការសម្រេចផែនការអប់រំរបស់ខេត្តស្វាយរៀងស្របតាមទិសដៅការពង្រឹងគុណភាពសិក្សានិងឆ្លើយតបទៅនឹងផែនទីបង្ហាញផ្លូវអប់រំកម្ពុជាឆ្នាំ២០៣០។

## ១.៣ គោលបំណងស្រាវជ្រាវ

ទាក់ទងនឹងបញ្ហាខាងលើការសិក្សាស្រាវជ្រាវនៃប្រធានបទ«**ការចូលរួមរបស់សហគមន៍ក្នុងវីស័យអប់រំនៅបឋមសិក្សាក្នុងខេត្តសស្វាយរៀង**»នេះមានគោលបំណងពីរគឺ៖

១. ដើម្បីកំណត់សកម្មភាពការចូលរួមពីសហគមន៍ក្នុងការអប់រំនៅបឋមសិក្សាក្នុងខេត្តស្វាយរៀង។

២.ដើម្បីស្វែងយល់ហេតុផលរបស់សហគមន៍ចូលរួមក្នុងការអប់រំនៅបឋមសិក្សាក្នុងខេត្តស្វាយរៀង។

## ១.៤ សំណួរស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងឆ្លើយសំណួរស្រាវជ្រាវសំខាន់ៗចំនួនពីរ៖

១. តើអ្វីជាការចូលរួមរបស់សហគមន៍នៅក្នុងសាលាបឋមសិក្សា? ជាពិសេស ទម្រង់ផ្សេងៗ នៃការចូលរួមរបស់សហគមន៍នៅសាលាបឋមសិក្សា។

២.តើកត្តាអ្វីខ្លះដែលជំរុញឱ្យមានការចូលរួមបែបនេះ? ទាក់ទិននឹង កត្តាខាងក្នុង និងខាងក្រៅនៅពីក្រោយការចូលរួមក្នុងការអប់រំ។

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការសិក្សានេះមានទិដ្ឋភាពពីរផ្សេងគ្នា គឺតួនាទីដ៏សំខាន់នៃការចូលរួមរបស់សហគមន៍ខ្លួនឯង និងការរួមចំណែកក្នុងការស្រាវជ្រាវនេះក្នុងកំណែទម្រង់វិមជ្ឈការក្នុងវិស័យអប់រំនៅប្រទេសកម្ពុជា។ ការចូលរួមរបស់សហគមន៍ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយកែលម្អគុណភាពនិងភាពពាក់ព័ន្ធនៃការអប់រំក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលរដ្ឋាភិបាលតែម្នាងមិនអាចធ្វើឱ្យការអប់រំមានគុណភាពល្អនោះទេព្រោះវាបណ្តាលឱ្យមានកង្វះខាតធនធានហិរញ្ញវត្ថុ និងបច្ចេកទេសពីសហគមន៍ក្នុងស្រុកវិញ។ ការចូលរួមរបស់សហគមន៍អាចជួយបង្កើនធនធានដែលមានកម្រិតអាចជួយកែលម្អកម្មវិធីសិក្សា សម្ភារសិក្សា សកម្មភាពបង្រៀន និងរៀន។ ការចូលរួមរបស់សហគមន៍ត្រូវបានគេជឿជាក់ថាអាចធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង និងភាពជាអ្នកដឹកនាំរបស់សាលារៀនតាមរយៈការបង្កើនគណនេយ្យភាពក្នុងការអប់រំជាមួយសហគមន៍ជាពិសេសក្នុងការគ្រប់គ្រងសាលារៀន។ គោលនយោបាយនិងប្រព័ន្ធគ្រប់គ្រងសមស្រប គឺជួយគាំទ្រនិងជំរុញដល់ការពង្រឹងមូលដ្ឋាននៃការចូលរួមរបស់សហគមន៍យ៉ាងសកម្មនៅក្នុងដំណើរការសាលារៀន។ គោលនយោបាយ និងយន្តការបែបនេះទាមទារភស្តុតាងនិងព័ត៌មានជាក់ស្តែងដែលអាចទទួលបានតាមរយៈការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗដើម្បីគាំទ្រដល់ដំណើរការគោលនយោបាយអប់រំ។ ទោះជាយ៉ាងណាក៏ដោយតាមការសិក្សាស្រាវជ្រាវជាច្រើនបានបញ្ជាក់ថា ការចូលរួមរបស់សហគមន៍ក្នុងការអប់រំនៅកម្ពុជានៅមានកម្រិតនៅឡើយ។ ដូច្នេះគេរំពឹងថា លទ្ធផលនៃការសិក្សានេះនឹងអាចប្រើជាចំណេះដឹងមូលដ្ឋានសម្រាប់អ្នករៀបចំផែនការអប់រំ អ្នកបង្កើតគោលនយោបាយអប់រំ និងអ្នកអនុវត្តគោលនយោបាយអប់រំ។ ការខិតខំគៀងគរសហគមន៍ឱ្យចូលរួមយ៉ាងច្រើនក្នុងការផ្តល់សេវាអប់រំនេះ ដែលមានប្រយោជន៍ជាពិសេស

សម្រាប់បរិបទកម្ពុជាដែលគំនិតរបស់សហគមន៍ក្នុងការចូលរួមមិនត្រូវបានគេស្រាវជ្រាវយ៉ាងទូលំទូលាយតាមបែបវិទ្យាសាស្ត្រនៅឡើយ។ ប្រទេសកម្ពុជាកំពុងឆ្ពោះទៅរកកំណែទម្រង់វិមជ្ឈការក្នុងវិស័យអប់រំដែលត្រូវការរឹតតែខ្លាំងក្នុងការពិនិត្យមើលការចូលរួមរបស់សហគមន៍នៅកម្រិតមូលដ្ឋាន។

## ១.៦. ដែនកំណត់ និង វិសាលភាពនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយទទួលបានជោគជ័យ គឺមានកត្តារួមផ្សំជាច្រើន។ ក្នុងនោះដែរការកំណត់ពីដែនកំណត់និងវិសាលភាពនៃការសិក្សាជាចំណុចដ៏សំខាន់ ដើម្បីកុំឱ្យការស្រាវជ្រាវប្រាសចាកពីប្រធានបទឬមិនចំគោលដៅ។ វិសាលភាពនៃការសិក្សាស្រាជ្រាវនេះគឺផ្តោតទៅលើតែ (១)សកម្មភាពចូលរួមយ៉ាងសកម្មរបស់សមាជិកសហគមន៍ក្នុងការគាំទ្រសាលារៀន (២)ស្ថានភាពសេដ្ឋកិច្ចសង្គមរបស់សហគមន៍ប៉ុណ្ណោះ។ ការសិក្សាស្រាវជ្រាវពីប្រធានបទ **«ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅបឋមសិក្សានៅខេត្តស្វាយរៀង»** នេះបានកំណត់យកសាលាបឋមសិក្សាគោលដៅចំនួន១៣សាលារៀននៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង។ សាលារៀនទាំងនោះរួមមាន សាលាបឋមសិក្សាព្រះសីហនុ សាលាបឋមសិក្សា២ធ្នូ សាលាបឋមសិក្សាចេក សាលាបឋមសិក្សាកន្ទុយរ៉ៃ សាលាបឋមសិក្សាចុងព្រែក សាលាបឋមសិក្សាពមករា សាលាសិក្សាជម្ពូព្រឹក្សា សាលាបឋមសិក្សាគយត្របែក សាលាបឋមសិក្សាស្វាយតឿ សាលាបឋមសិក្សាព្រះទន្លេ សាលាបឋមសិក្សាក្រសាំងជ្រុំ សាលាបឋមសិក្សាសាមគ្គី សាលាបឋមសិក្សាអកនាគ។ ក្នុងនោះជាតុសំណាកគឺអ្នកដែលកចូលរួមក្នុងការសិក្សានេះគឺនាយកសាលា គ្រូបង្រៀន និងថ្នាក់ដឹកនាំគណៈកម្មាធិការគ្រប់គ្រងសាលា មាតាបិតាសិស្សនិងព្រះសង្ឃ ។

## ១.៧ រចនាសម្ព័ន្ធនៃនិក្ខេបបទ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវនេះមាន ៥ ជំពូកដូចរៀបរាប់ខាងក្រោម៖

- **ជំពូកមួយ៖** សេចក្តីផ្តើមរួមមានលំនាំបញ្ហានៃការស្រាវជ្រាវចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាជ្រាវសំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាព នៃការស្រាវជ្រាវនិង

របចនាសម្ព័ន្ធនៃការស្រាវជ្រាវដោយនាំយកចំណាប់អារម្មណ៍របស់អ្នកអានទៅកាន់ហេតុផលគោលបំណង និងសារៈសំខាន់នៃការសិក្សា។

❖ **ជំពូកពីរ៖** រំលឹកទ្រឹស្តីនិយាយអំពីបរិបទនៃការស្រាវជ្រាវដែលឧទ្ទិសដល់ការពិនិត្យឡើងវិញនៃទ្រឹស្តីនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ ផ្តោតលើនិយមន័យនៃសហគមន៍ដែននៃការចូលរួមរបស់សហគមន៍កម្រិតនិងហេតុផលនៅពីក្រោយការចូលរួមបែបនេះ។ វាផ្តល់ព័ត៌មានលម្អិតអំពីប្រវត្តិសាស្ត្រនិងគោលនយោបាយ អប់រំទាក់ទង នឹងការចូលរួមរបស់សហគមន៍ និងទំនាក់ទំនងនៃបរិបទអប់រំទៅនឹងទ្រឹស្តីដែលពាក់ព័ន្ធ។

❖ **ជំពូកបី៖** បង្ហាញពីវិធីសាស្ត្រស្រាជ្រាវការវិភាគទិន្នន័យនិងការវិភាគទ្រឹស្តីដែលពិនិត្យមើលក្របខ័ណ្ឌគំនិតដែលត្រូវបានប្រើសម្រាប់ការសិក្សាស្រាវជ្រាវ និងទ្រឹស្តីអំពីការចូលរួមរបស់សហគមន៍នៅក្នុងការអប់រំជាពិសេសទាក់ទងនឹងបរិបទនៃការអភិវឌ្ឍន៍។

❖ **ជំពូកបួន៖** បង្ហាញពីលទ្ធផលស្រាវជ្រាវនៃការសិក្សា និងបកស្រាយយ៉ាងលម្អិតទៅលើបំណងនៃការស្រាវជ្រាវដោយយោងទៅលើលទ្ធផលនៃការស្រាជ្រាវទ្រឹស្តី និងខ្លឹមសារដែលមាននៅក្នុងកម្រងសំណួរ។

❖ **ជំពូកប្រាំ៖** សេចក្តីសន្និដ្ឋានលើប្រធានបទតាមរយៈលទ្ធផលនៃការស្រាវជ្រាវការដាក់ចេញជាអនុសាសន៍ និងសំណូមពរនានាជូនទៅភាគីពាក់ព័ន្ធ លើការអប់រំជាពិសេសអ្នកសរសេររៀបចំគោលនយោបាយអប់រំដើម្បីប្រែក្លាយសាលារៀន និងសហគមន៍ឱ្យមានការអភិវឌ្ឍ និងផ្លាស់ប្តូរជាវិជ្ជមាននៅគ្រប់កម្រិតសាលារៀនផ្តោតលើការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ ។

# ជំពូក២

# ការរំលឹកទ្រឹស្តី

ជំពូកនេះត្រូវបានឧទ្ទិសដល់ការពិនិត្យឡើងវិញនៃទ្រឹស្តីនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ ផ្តោតលើនិយមន័យនៃសហគមន៍ ដែននៃការចូលរួមរបស់សហគមន៍ កម្រិត និងហេតុផលនៅពីក្រោយការចូលរួមនេះ។ ការពិនិត្យឡើងវិញតាមទ្រឹស្តីផ្តល់នូវការណែនាំជាគំនិតអំពីអ្វីដែលត្រូវរកមើលនៅពេលណា ពិនិត្យលើអ្វីដែលបង្កើតឱ្យមានការចូលរួមរបស់សហគមន៍នៅក្នុងតំបន់ ទាក់ទងនឹង មធ្យោបាយរបស់រដ្ឋ និងសហគមន៍ទាក់ទងគ្នាទៅវិញទៅមកជុំវិញការសិក្សា។

## ២.១ តើសហគមន៍ជាអ្វី?

សហគមន៍ ត្រូវបានកំណត់ជាតំបន់ភូមិសាស្ត្រដែលមានមនុស្សមានសង្គមអន្តរកម្ម និងមានភាពសាមញ្ញមួយ ឬច្រើន (Hillery, 1955)។ Bray (2001) បានចង្អុលបង្ហាញថាសហគមន៍មានប្រាំប្រភេទ (១) គាត់កំណត់សហគមន៍ដោយផ្អែកលើ ទីតាំងភូមិសាស្ត្រដែលបុគ្គលរស់នៅ ដូចជាភូមិ ឬស្រុក។ (២) គាត់ពិពណ៌នាអំពីសហគមន៍តាមក្រុមជនជាតិភាគតិច និងពូជសាសន៍របស់ពួកគេ ដោយការជួយខ្លួនឯងរចនាសម្ព័ន្ធគាំទ្រ។ (៣) សហគមន៍ត្រូវបានចាត់ថ្នាក់តាមប្រភេទមូលដ្ឋានរបស់សាសនាផ្សេងៗគ្នារបស់ពួកគេ។ (៤) សហគមន៍សំដៅទៅលើបុគ្គលទាំងឡាយដែលចែករំលែក ការព្រួយបារម្ភចំពោះគ្រួសាររបស់ពួកគេ។ ជាចុងក្រោយ (៥) Bray បានកំណត់សហគមន៍ដោយផ្អែកលើការចែករំលែក សប្បុរសធម៌ដើម្បីលើកកម្ពស់សុខុមាលភាពរបស់អ្នកដទៃដោយការបរិច្ចាកធនធានផ្សេងៗក្នុងបុព្វហេតុល្អណាមួយ។

ដូចគ្នានេះដែរ លោក Shaeffer (1992) បានបង្ហាញថាសហគមន៍ខ្លះ ដូចគ្នា ខណៈពេលដែលសហគមន៍ផ្សេងទៀតគឺខុសគ្នា និងខ្លះរួបរួមសាមគ្គីគ្នាខណៈខ្លះទៀតមានជម្លោះ។ សហគមន៍ខ្លះត្រូវបានគ្រប់គ្រងដឹកនាំដោយអ្នកដឹកនាំដែលត្រូវបានជ្រើសរើសតាមបែបប្រជាធិបតេយ្យ ដែលធ្វើសកម្មភាពទាក់ទងគ្នា ដោយស្វ័យភាពពីរដ្ឋាភិបាលកម្រិតផ្សេងទៀត ហើយខ្លះទៀតត្រូវបានគ្រប់គ្រងដោយមេដឹកនាំ និងតំណាងអាជ្ញាធរកណ្តាល ។

Zenter (1964) ចង្អុលបង្ហាញទិដ្ឋភាពបីនៃសហគមន៍ (១) សហគមន៍គឺជារចនាសម្ព័ន្ធក្រុមថា តើការរៀបចំសមាជិកដែលមានតួនាទីជាផ្លូវការ ឬ មិនផ្លូវការត្រូវបានដាក់បញ្ចូលជុំវិញគោលដៅ ទាក់ទង នឹងបញ្ហាកាន់កាប់រួម និងការប្រើប្រាស់កន្លែងរស់នៅ។ (២)សមាជិកនៃសហគមន៍មានកម្រិតនៃអត្ត សញ្ញាណសមូហភាពជាមួយនឹងកន្លែងកាន់កាប់។ ចុងក្រោយ (៣)សហគមន៍មានកម្រិតស្វ័យភាព និង ការទទួលខុសត្រូវក្នុងមូលដ្ឋាន។

DeFilippis និង Susan (2008) «សហគមន៍» គឺរួមបញ្ចូលមនុស្ស និងទីកន្លែងដូចជា «មនុស្ស ទីកន្លែង និង ស្ថាប័នដែលយើងជួបប្រទះក្នុងជីវិតប្រចាំថ្ងៃផ្តល់ឱកាស និងការគាំទ្រ សកម្មភាព ក៏ដូចជា ឧបសគ្គ និងឧបសគ្គ» (ទំ.១)។ សហគមន៍ខ្មែរក្នុងអតីតកាលមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងវត្ត ព្រះពុទ្ធសាសនាមជ្ឈមណ្ឌលសង្គម វប្បធម៌ និងសាសនានៃសហគមន៍ (Pellini, 2005)។ ឥរិយាបថនេះ គឺនៅតែអនុវត្តនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។ សហគមន៍ខ្មែរ យោងទៅតាម Clayton (1995) និង Pellini (2005) គឺជាឋានានុក្រមសង្គមដែលមនុស្សចាស់មានគោរពយ៉ាងខ្លាំង។ មេភូមិ ប្រជាពលរដ្ឋ គ្រួសារអ្នក មាន និងសមាជិកសហគមន៍អ្នកចេះអក្សរត្រូវបានដឹងថាជាអ្នកដឹកនាំសហគមន៍ (Pellini, 2005)។ នៅ ក្នុងការស្រាវជ្រាវ «សហគមន៍» សំដៅទៅលើក្រុមចម្រុះនៃភាគីពាក់ព័ន្ធរួមបញ្ចូលទាំងឪពុកម្តាយ អាជ្ញាធ រមូលដ្ឋាន សង្គមស៊ីវិល អង្គការសហគមន៍ អង្គការក្រៅរដ្ឋាភិបាល អ្នកជំនួញ មីក្រូស្ថាប័នហិរញ្ញវត្ថុ យុវជន ព្រះវិហារ វត្តពុទ្ធសាសនា និងស្ថាប័នឯកជនដទៃទៀត។ ដែលមានគោលបំណងរួមក្នុងការអប់រំ។ ទាក់ទងនឹងការអប់រំមនុស្សទាំងនេះ និងស្ថាប័នដែលមានសកម្មភាពនៅក្នុងសហគមន៍អាច ឬមិនអាច ចូលរួមក្នុងការអប់រំនៅក្នុងសាលារៀន នៅផ្ទះ ឬក្នុងសហគមន៍។

ដោយឡែកនៅប្រទេសកម្ពុជាទំនាក់ទំនងសាលារៀន និង សហគមន៍ គេនិយមចែកសហគមន៍ជា ពីរផ្នែកគឺ សហគមន៍ជាតិ និង សហគមន៍អន្តរជាតិ (**ឯកសារស្តីពីទំនាក់ទំនងសាលារៀននិងសហគមន៍ បោះពុម្ព, ២០០២**)។

**២.១.១ សហគមន៍ជាតិ**៖មានដូចជា៖ គ្រូបង្រៀន រួមទាំងគណៈគ្រប់គ្រងសាលា និង បុគ្គលិក កម្ម ករសិស្សានុសិស្ស មាតាបិតាសិស្ស សមាគមមាតាបិតាសិស្ស សមាគមជាតិ សមាគមអាណិកជនខ្មែរ

ប្រជាជនទូទៅ អាជ្ញាធរដែនដី រដ្ឋអំណាចភូមិ ឃុំ ស្រុក ខេត្ត ព្រះសង្ឃ អាចារ្យវត្ត ដូនជី ទាហាន ប៉ូលីស អគ្គនាយកដ្ឋាន នាយកដ្ឋាន ស្ថាប័នផ្សេងៗ ក្រសួង មន្ទីរ ទូទាំងប្រទេស ... ។

**២.១.២ សហគមន៍អន្តរជាតិ៖**

**២.១.២.១** ទីភ្នាក់ងារផ្តល់ជំនួយជាពហុភាគីដល់ប្រព័ន្ធអប់រំដូចជា៖

- ធនាគារអភិវឌ្ឍអាស៊ី (ADB) ជួយដល់ផ្នែកអភិវឌ្ឍសៀវភៅសិក្សា និងផ្នែកអប់រំវិជ្ជាជីវៈបច្ចេកទេសអង្គការសហប្រជាជាតិ (UN) រួមមាន UNICEF UNDP UNFPA UNESCO ដែលផ្នែកខ្លះត្រូវរ៉ាប់រងអនុវត្តដោយអង្គការផ្សេងៗដូចជា អង្គការ ILO / CARERE......។
- ធនាគារពិភពលោក (WB) កំពុងសាកល្បងកម្មវិធីដកពិសោធដើម្បីផ្តល់ប្រាក់កម្ចី
- សហគមន៍អឺរ៉ុប(EU) តាមរយៈកម្មវិធី PASEC ដែលទីបញ្ចប់ជំហានទី ១ នៃកម្មវិធីសំរាប់ប្រទេស និងជំហានទីពីរ រយៈពេល២ឆ្នាំកន្លងមក។

**២.១.២.២** អ្នកផ្តល់ជំនួយទ្វេភាគី : ដូចជា៖

រដ្ឋាភិបាលប្រទេសបារាំងតាមរយៈ Francophonie និងInstitute of Technology of Cambodia ក្នុងនោះមាន ៖

- ភ្នាក់ងារ ACCT (Agence de cooperation culturelle et Technique)
- ភ្នាក់ងារ AUPELF-UREF (Association des Universités Partiellement et Entierement de langue Française et Union des Réseaux d'Expression Française)
- ភ្នាក់ងារប្រទេសអូស្ត្រាលី Aus AID (Australian Agency International Developnent)
- ភ្នាក់ងារប្រទេសជប៉ុនតាមរយៈ JICA (Japan International Cooperation agency)
- ភ្នាក់ងារប្រទេសអង់គ្លេស UK/ODA តាមរយៈ CfBT-CBC
- ភ្នាក់ងារប្រទេសអាល្លឺម៉ង់ច្រើនតាមរយៈ GTZ-Don Bosco
- ភ្នាក់ងារប្រទេសចិន ផ្នែកខាងកីឡា
- ភ្នាក់ងារប្រទេស រុស្ស៊ី ផ្នែកអាហារូបករណ៍

– ភ្នាក់ងារប្រទេសវៀតណាម ផ្នែកអាហារូបករណ៍

**២.១.២.៣** ការផ្តល់ជំនួយតាមរយៈអង្គការក្រៅរដ្ឋាភិបាល NGOs ដូចជាអង្គការRedd Barna (ប្រទេស Norway), Care International (សហរដ្ឋអាមេរិក-អូស្ត្រាលី),JSRC-JIVC -Japan (ពីមុន JSRC បច្ចុប្បន្ន SVA),ASAC-Japan, Taipei Overseas Peace Service (Tops),Enfant du Cambodge, ICS (Nether Lands),Assemblies of Gods, Pour un Sour ire d'Enfant,SIPAR, Quaker Service Australia, Lutheran World Service, Don Bosco Foundation,VSO (Voluntary Service Overseas),World Vision, New Humanity)... ។

## ២.២ តើការចូលរួមគឺជាអ្វី?

ការចូលរួមត្រូវបានយល់ជាទូទៅថាជាការចូលរួមរបស់ភ្នាក់ងារទាំងពីខាងក្នុង និងនៅខាងក្រៅសហគមន៍ដើម្បីធ្វើការរួមគ្នាក្នុងគម្រោងអភិវឌ្ឍន៍ដើម្បីផលប្រយោជន៍រួម **(Cornwall, 2006, 2008; Mohan & Stokke, 2000)**។ ពាក្យ «ការចូលរួម» អាចត្រូវបានបកស្រាយតាមវិធីផ្សេងៗគ្នាអាស្រ័យលើបរិបទ។ **Shaeffer (1994)** បញ្ជាក់ពីកម្រិត ឬកម្រិតនៃការចូលរួមផ្សេងៗគ្នាចំនួនប្រាំពីររួមមាន៖

- ការចូលរួមតាមរយៈការប្រើប្រាស់សេវាមួយប៉ុណ្ណោះ (ដូចជាការចុះឈ្មោះកុមារនៅក្នុងសាលា ឬការប្រើប្រាស់កន្លែងថែទាំសុខភាពបឋម);
- ការចូលរួមតាមរយៈការរួមចំណែក (ឬការទាញយក) នៃថវិកា សម្ភារៈ និងកម្លាំងពលកម្ម។
- ការចូលរួមតាមរយៈ «ការចូលរួម» (ឧ. នៅឯកិច្ចប្រជុំរបស់ឪពុកម្តាយនៅសាលារៀន) បង្កប់ន័យអកម្ម ការទទួលយកការសម្រេចចិត្តរបស់អ្នកដទៃ
- ការចូលរួមតាមរយៈការពិគ្រោះយោបល់លើបញ្ហាជាក់លាក់មួយ
- ការចូលរួមក្នុងការផ្តល់សេវា ជាញឹកញាប់ជាដៃគូជាមួយតួអង្គផ្សេងទៀត
- ការចូលរួមជាអ្នកអនុវត្តអំណាចដែលបានផ្ទេរសិទ្ធិ

- ការចូលរួម «ក្នុងការសម្រេចចិត្តពិតប្រាកដនៅគ្រប់ដំណាក់កាល» រួមទាំងការកំណត់អត្តសញ្ញាណលើបញ្ហាការសិក្សាអំពីលទ្ធភាពការធ្វើផែនការ ការអនុវត្ត និងការវាយតម្លៃ។ Shaeffer ផ្តល់បន្ថែមនូវសកម្មភាពជាក់លាក់មួយចំនួនដែលពាក់ព័ន្ធ នឹងការចូលរួមក្នុងកម្រិតខ្ពស់បរិបទអភិវឌ្ឍន៍ដែលអាចអនុវត្តបានក្នុងវិស័យអប់រំសកម្មភាពទាំងនោះរួមមានៈ
  - ការប្រមូលនិងវិភាគព័ត៌មាន
  - ការកំណត់អាទិភាព និងការកំណត់គោលដៅ
  - ការវាយតម្លៃធនធានដែលមាន
  - ការសម្រេចចិត្ត និងរៀបចំផែនការកម្មវិធី
  - រៀបចំយុទ្ធសាស្ត្រ ដើម្បីអនុវត្តកម្មវិធីទាំងនេះ និងការបែងចែកការទទួលខុសត្រូវក្នុងចំណោមអ្នកចូលរួម។
  - កម្មវិធីគ្រប់គ្រង
  - តាមដានវឌ្ឍនភាពនៃកម្មវិធី និង
  - ការវាយតម្លៃលទ្ធផល និងផលប៉ះពាល់។

## ២.៣ តើអ្វីទៅជាការចូលរួមរបស់សហគមន៍ក្នុងការអប់រំ?

ការចូលរួមរបស់សហគមន៍ក្នុងការអប់រំគឺជាដំណើរការដែលកុមារ ឪពុកម្តាយ ប្រជាពលរដ្ឋ សហគមន៍ អាជ្ញាធរមូលដ្ឋាន គ្រូបង្រៀន វិស័យឯកជន និង ភាគីពាក់ព័ន្ធផ្សេងទៀតចូលរួមនៅក្នុងកម្មវិធីសាលារៀន ឬនៅក្នុងស្ថាប័នដែលទាក់ទងនឹងការអប់រំ(Griffin & Steen, 2010)។ ការស្រាវជ្រាវបង្ហាញថាលទ្ធផលសិក្សាប្រែប្រួលក្នុងចំណោមកុមារ ដែលមកពីមជ្ឈដ្ឋានផ្សេងគ្នាកុមារដែលមានឪពុកម្តាយចូលរួមក្នុងការសិក្សារបស់ពួកគេជាទូទៅទទួលបានលទ្ធផលសិក្សាល្អជាងសិស្សដទៃទៀត។ ទំនាក់ទំនងរវាងគ្រូបង្រៀន ឪពុកម្តាយ និងសហគមន៍គឺមានសារៈសំខាន់ណាស់ក្នុងការបង្កើត និងបន្តព្យាយាមអភិវឌ្ឍភាពជាដៃគូរវាងសាលារៀន ឪពុកម្តាយ និងសហគមន៍។ ប្រភេទនៃការចូលរួមផ្សេងៗដើម្បីពន្យល់ពីរបៀប

ដែលសាលារៀន គ្រួសារ និងសហគមន៍អាចធ្វើការរួមគ្នាគឺៈ (១)ការចិញ្ចឹមកូន ការបង្កើតបរិយាកាសដែលគាំទ្រដល់ការរៀនសូត្ររបស់កុមារទាំងក្នុងផ្ទះ និងនៅសាលារៀន (២)ការប្រាស្រ័យទាក់ទងគ្នាប្រកបដោយប្រសិទ្ធភាពរវាងសាលាមួយជាមួយផ្ទះមួយ និងផ្ទះមួយជាមួយសាលាអាចឱ្យមាតាបិតាសិស្សសិក្សាអំពីកម្មវិធីសិក្សា និងភាពរីកចម្រើនរបស់កូនពួកគេនៅក្នុងសាលារៀនក៏ដូចជាគ្រូអាចយល់ដឹងពីរបៀបរៀនរបស់កុមាររៀននៅផ្ទះ (៣)ការស្ម័គ្រចិត្តៈដើម្បីជ្រើសរើសនិងរៀបចំជំនួយនិងការគាំទ្រពីឪពុកម្ដាយ (៤)ការរៀននៅផ្ទះៈ ដើម្បីផ្ដល់ព័ត៌មាន និងគំនិតដល់គ្រួសារអំពីរបៀបជួយសិស្សនៅផ្ទះជាមួយនឹងការងារផ្ទះនិងសកម្មភាព និងកម្មវិធីសិក្សាផ្សេងៗ ការសម្រេចចិត្តនិងផែនការ (៥)ការសម្រេចចិត្តដើម្បីរួមបញ្ចូលក្រុមគ្រួសារនៅក្នុងការសម្រេចចិត្តរបស់សាលា ដើម្បីឱ្យមានតំណាងអាណាព្យាបាលនិងតំណាងនៅក្នុងកិច្ចប្រជុំសាលា និង(៦)សហការជាមួយសហគមន៍ ដើម្បីកំណត់អត្តសញ្ញាណនិងរួមបញ្ចូលធនធានដូចជាសេវាកម្មពីសហគមន៍ដើម្បីពង្រឹងកម្មវិធីសាលារៀន ការអនុវត្តរបស់គ្រួសារ និងការរៀនសូត្ររបស់សិស្ស។

## ២.៤ គំរូនៃភាពជាដៃគូសហគមន៍-សាលារៀន

ការបែងចែកធនធានតាមរបៀបដែលអំណោយផលដល់លទ្ធផលសិក្សា តាមសាលាដោយអំពាវនាវឱ្យមានភាពជាដៃគូរវាងរដ្ឋ សាលា និងសហគមន៍(Cummings, 1997; Williams,1997)។ «ការអប់រំសម្រាប់ទាំងអស់គ្នា ទាំងអស់សម្រាប់ការអប់រំ» គឺជាឃ្លាដ៏ល្អដែលឆ្លុះបញ្ចាំងពីសាលារៀន និងសហគមន៍របស់ខ្លួនធ្វើជាដៃគូនឹងគ្នា។ ការពិតដែលថាសហគមន៍បានចែករំលែកប្រពៃណី ទំនួលខុសត្រូវក្នុងការផ្តល់ការអប់រំ និងការចូលរួមយ៉ាងច្រើនមានផលវិជ្ជមានស្ដីពីប្រតិបត្តិការសាលា និងសមិទ្ធិផលរបស់សិស្ស (Bray, 2001; Rose, 2003; Uemura,1999)។ ជាលទ្ធផលគំរូផ្សេងៗបានជួយនាំសហគមន៍ទៅរកសាលារៀនកាន់តែច្រើន។ Bray (2001) បានបង្ហាញគំរូនៃភាពជាដៃគូរវាងរដ្ឋ និងសហគមន៍ ដែលក្នុងនោះសាលាក្នុងនាមជាភ្នាក់ងាររបស់រដ្ឋ និងសហគមន៍របស់ខ្លួនចែករំលែកនូវទំនួលខុសត្រូវធ្វើការសម្រេចចិត្ត និងផ្ដល់ការអប់រំដល់កុមារ។ គំរូបែបនេះត្រូវបានលេចចេញជាគំរូចម្បងក្នុងភាពជាដៃគូអប់រំដែល

សមហេតុផលផងដែរ ។ តាម Epstein (1995, 1997) បានសិក្សាស្វែងរកវិធីដើម្បីជួយកុមារឱ្យទទួលបានជោគជ័យក្នុងសាលារៀន និងឆាកជីវិតហើយផ្តោតលើភាពជាដៃគូរបស់សាលារៀន គ្រួសារ និងសហគមន៍ ៖ (១) កែលម្អកម្មវិធីសាលារៀន និងបរិយាកាសសាលារៀន (២) ផ្តល់សេវាគ្រួសារ និងការគាំទ្រ។ (៣) បង្កើនជំនាញនិងភាពជាអ្នកដឹកនាំរបស់ឪពុកម្តាយ (៤)ផ្សារភ្ជាប់គ្រួសារ សាលារៀននិងសហគមន៍ (៥) ជួយគ្រូបង្រៀនក្នុងការងាររបស់ពួកគេ។ គំរូភាពជាដៃគូក៏គាំទ្រដល់អ្វីដែលបានរៀបរាប់ខាងលើ ប៉ុន្តែសង្កត់ធ្ងន់លើដៃគូនីមួយៗដើរតួនាទីផ្សេងគ្នាដោយផ្អែកលើកម្រិតនៃអំណាចខុសៗគ្នារបស់ពួកគេ (Williams, 1997)។ ភាគីខ្លះមានឥទ្ធិពល និងមានសកម្មភាពច្រើនជាងអ្នកផ្សេងទៀតដោយចូលរួមក្នុងសកម្មភាពរបស់សាលា និងផ្តួចផ្តើមគំនិតសម្រាប់ការកែលម្អរបស់សាលារៀនថែមទៀតផង។ គំរូភាពជាដៃគូដែលបានរៀបរាប់អាចសន្មតថាសហគមន៍ជាដៃគូមានឆន្ទៈ និងអាចធ្វើការរួមគ្នាជាមួយសាលា ដើម្បីកែលម្អការអប់រំ។ គំរូទាំងនេះផ្តល់នូវគោលការណ៍សំខាន់ពីរគឺ (១)ការអន្តរាគមន៍ដើម្បីលើកកម្ពស់ការអប់រំមានគោលបំណងឆ្លុះបញ្ចាំងឱ្យឃើញកាន់ច្បាស់នៃបរិបទមូលដ្ឋាន ដែលមានប្រសិទ្ធិភាពកាន់តែខ្លាំងនៅពេលដែលមធ្យោបាយសម្រាប់ការចូលរួមត្រូវបានបង្កើតឡើងសម្រាប់សហគមន៍។ (២)ក្រៅពីការរួមចំណែកជាសម្ភារៈសហគមន៍ក៏ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុផងដែរ (Bray, 1996) និងទទួលយកភាពជាម្ចាស់នៃសាលាទាក់ទងនឹងហិរញ្ញវត្ថុ ថែមទាំងការសម្រេចចិត្តសំខាន់ជាច្រើនទៀតផង។ អារម្មណ៍នៃភាពជាម្ចាស់នេះឆ្លុះបញ្ចាំងពីភាពរឹងមាំនៃភាពជាដៃគូរវាងសាលា និងសហគមន៍របស់ខ្លួន។

សរុបសេចក្តីមក ទំនាក់ទំនងរវាងសាលារៀន និង សហគមន៍ជាកត្តាសកម្មភាពដ៏សំខាន់ និងមិនអាចខ្វះបានដែលនេះជាទំនាក់ទំនងដែលផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ សាលារៀនដែលពុំបានទទួលការចូលរួមអភិវឌ្ឍពីសំណាក់សហគមន៍ពិតជាពុំមានលទ្ធភាពបំពេញតួនាទីរបស់ខ្លួនបានសមស្របឡើយ។ សាលារៀនដែលមានការចូលរួមតែងតែមានការអភិវឌ្ឍបានទាំងផ្នែកបរិមាណ និងទាំងផ្នែកគុណភាពនៅក្នុងការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ធ្វើឱ្យសហគមន៍កែប្រែមុខមាត់ពីអន់ថយទៅជឿនលឿន ពីក្រីក្រទៅសំបូររុងរឿង។ នៅពេលដែលសហគមន៍កាន់តែសម្បូររុងរឿងនោះសហគមន៍កាន់តែមានលទ្ធភាពជួយសាលារៀនឱ្យកាន់តែបំពេញមុខងារបានល្អប្រសើរសម្រាប់បម្រើផលប្រយោជន៍ ឬ ដោះ

ស្រាយតម្រូវការរបស់សហគមន៍វិញ។ ដូចនេះ ការចូលរួមរបស់សហគមន៍ត្រូវតែយកចិត្តទុកដាក់ពង្រឹង និងកែលម្អទំនាក់ទំនងរបស់សាលាជាមួយ សហគមន៍ តាមរយៈការយល់ជ្រួតជ្រាបឱ្យបានច្បាស់អំពីទំនាក់ទំនងរវាងសាលារៀន និងសហគមន៍។ ការក្តាប់ឱ្យបានអំពីតួនាទី និងភារកិច្ចរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀន ការអនុវត្តឱ្យបានល្អប្រសើរនូវ គោលការណ៍ទំនាក់ទំនង និងការចេះជ្រើសរើសរកយុទ្ធវិធីសមស្របមកអនុវត្តដើម្បីទាក់ទាញសហគមន៍ឱ្យចូលរួមក្នុងការអប់រំ និងការអភិវឌ្ឍសាលារៀន ។

**២.៥ កម្រិតនៃការចូលរួមសហគមន៍**

បន្ថែមពីលើការពិនិត្យសមាសភាពនៃការចូលរួម អ្នកប្រាជ្ញជាច្រើនបានសិក្សាពីកម្រិតនៃការចូលរួម វិសាលភាពដែលសហគមន៍ចូលរួមក្នុងការអប់រំនៅក្នុងសាលាក្នុងតំបន់របស់ពួកគេ។ Shaeffer (1992) បានរកឃើញថាកម្រិតនៃការចូលរួមរបស់សហគមន៍គឺមានកម្រិតទាបក្នុងសង្គម និង តំបន់សេដ្ឋកិច្ច។ នេះគឺដោយសារតែតំបន់នេះមាននិន្នាការមានជាតុដូចខាងក្រោម: (១)កង្វះការលើកកម្ពស់ចំពោះគោលបំណងទូទៅនៃការអប់រំ (២)ភាពមិនស៊ីគ្នារវាងឪពុកម្តាយ និងសាលារៀនការរំពឹងទុករបស់សហគមន៍ចំពោះការអប់រំខុសពីអ្វីដែលសាលាត្រូវបានមើលឃើញថាជាការផ្តល់។ (៣)ជំនឿថាការអប់រំមានសារៈសំខាន់ និងជាភារកិច្ចរបស់រដ្ឋ (៤)រយៈពេលដែលត្រូវការដើម្បីដឹងពីអត្ថប្រយោជន៍នៃការសិក្សា និង (៥)រចនាសម្ព័ន្ធ មុខងារ និងឧបសគ្គរបស់សាលា។ Shaeffer (1994) ពិពណ៌នាអំពីពីកិច្ចសហប្រតិបត្តិរវាងសហគមន៍ និងសាលារៀនត្រូវបានហៅថាការចូលរួម។ ពាក្យថា «ការចូលរួម» មានន័យថាកិច្ចសហការយ៉ាងសកម្មជាមួយ(១)ការប្រើប្រាស់សេវាអប់រំ(២)ការរួមចំណែកធនធាន(៣)ការចូលរួមប្រជុំ(៤)ការពិគ្រោះយោបល់លើបញ្ហា(៥)ការចូលរួមក្នុងការផ្តល់សេវា(៦)ការអនុវត្តអំណាចផ្ទេរសិទ្ធិ និងការសម្រេចចិត្ត(៧)អំណាចពិតប្រាកដ និងការសម្រេចចិត្តនៅគ្រប់ដំណាក់កាល(Shaeffer, 1994, pp.16-17)

## ២.៦ កត្តាជំរុញសម្រាប់ការចូលរួមរបស់សហគមន៍

យោងទៅតាម Rose ការចូលរួមរបស់សហគមន៍កើតឡើងនៅពេលដែល រដ្ឋាភិបាលប្រឈមនឹងកង្វះថវិកាសម្រាប់គាំទ្រកម្មវិធីអប់រំ (Rose, 2003)។ សហគមន៍ និងឪពុកម្តាយត្រូវបានអំពាវនាវឱ្យចូលរួមចំណែកធនធានដែលមានសម្រាប់ ការអភិវឌ្ឍន៍សាលារៀន ថែទាំ និងការអភិវឌ្ឍន៍វិស័យអប់រំ។

ដូចគ្នាដែរ នៅក្នុងបរិបទកម្ពុជា Save the Children Cambodia (2015), Clayton (2005), Pellini (2005, 2007) និង Bray (2001) បានកត់សម្គាល់ថាទម្រង់នៃ ការចូលរួម របស់សហគមន៍ ជាទូទៅកើតឡើងក្នុងការអប់រំ ដើម្បីបំពេញកង្វះហិរញ្ញវត្ថុនៅក្នុងសាលារៀន។ សហគមន៍រួមចំណែកធនធានដែលមានរបស់ពួកគេដូចជាថវិកា សម្ភារសំណង់ កម្លាំងពលកម្ម និងយ៉ាងហោចណាស់គំនិតសម្រាប់ការអភិវឌ្ឍន៍សាលារៀន។ ការគៀងគរធនធានត្រូវបានរាយការណ៍ដោយគណៈកម្មាធិការសាលាដូចជាសមាគមមាតាបិតាសិស្ស គ្រូបង្រៀន (Parent Teacher Association) ឬគណៈកម្មាការគ្រប់គ្រងសាលា (Dykstra & Kucita, 1997)។ គណៈកម្មាធិការគ្រប់គ្រងសាលាជួយសាលារៀនក្នុងការប្រមូលផ្តុំប្រជាជនក្នុងតំបន់ឱ្យចូលរួមសាងសង់សាលាតាមរយៈការរួមចំណែកដូចជាថវិកា សម្ភារៈ និងកម្លាំងពលកម្ម។ សង្គមកម្ពុជាមានឋានានុក្រមសង្គម ប្រជាជនគំរូ មេភូមិ ព្រះសង្ឃ និងអ្នកបួសដែលជាសមាជិកនៃគណៈកម្មការគ្រប់គ្រងសាលាត្រូវបានគេគោរពយ៉ាងខ្លាំងហើយពួកគេគឺ មានឥទ្ធិពលខ្លាំងណាស់ក្នុងការគៀងគរធនធានសម្រាប់ការអភិវឌ្ឍន៍សាលារៀន (Pellini, 2005)។

ការជំរុញសហគមន៍ សម្រាប់ការចូលរួមក្នុងសកម្មភាពអប់រំអាចមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងពីការជំរុញរបស់រដ្ឋាភិបាល និងទីភ្នាក់ងារអន្តរជាតិដែលគាំទ្រការចូលរួមរបស់សហគមន៍។ Bray (2003) អះអាងថាក្នុងករណីជាច្រើន ដែលសហគមន៍ជាអ្នកផ្តល់ធាតុចូលឱ្យដល់សាលារៀនដោយសារសកម្មភាពចូលរួមរបស់រដ្ឋាភិបាលតែម្នាងគឺមិនអាចសម្រេចគោលដៅទេ។ ធាតុចូលរបស់សហគមន៍ក្នុងកាលៈទេសៈបែបនេះ អាចត្រូវបានបែងចែកជាពីរក្រុម។ **ក្រុមមួយ**គឺជាស្ថានភាពដែល សហគមន៍ផ្តល់ធនធានបន្ថែមដល់ប្រព័ន្ធអប់រំរបស់រដ្ឋ និង**ក្រុមពីរ**គឺជាសាលារៀនដែលដំណើរការដោយសហគមន៍ក្រៅប្រព័ន្ធរដ្ឋ។ សំខាន់ជាងនេះទៅទៀត សមាជិកសហគមន៍សម្រេចចិត្តគាំទ្រសាលារៀនដោយសារតែពួកគេ

មើលឃើញពីសារៈសំខាន់នៃការអប់រំកូនៗរបស់ពួកគេ និងតួនាទីរបស់សាលាដើម្បីកំណត់អនាគតកូនៗរបស់ពួកគេ។ ឆន្ទៈនិងសេចក្តីប្រាថ្នារបស់ឪពុកម្តាយដែលចង់ឃើញអនាគតដ៏ល្អប្រសើររបស់កូនៗហើយជាកត្តាដ៏សំខាន់ដែលជំរុញឱ្យពួកគេចូលរួមក្នុងការអប់រំ។ ប្រភេទនៃការលើកទឹកចិត្តផ្នែកខាងក្នុងនេះគឺមានឥទ្ធិពលទៅលើការសម្រេចចិត្តចូលរួមក្នុងសកម្មភាពសាលាជាងកត្តាខាងក្រៅដូច ដែលបានពន្យល់ខាងលើ ។

## ២.៧ ភាពពាក់ព័ន្ធនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ

សាលារៀន គឺជាស្ថាប័នសង្គមសំខាន់មួយដែលត្រូវបានផ្សារភ្ជាប់ខាងក្នុងទៅនឹងសហគមន៍ប្រកបដោយសុខុមាលភាព និងការរីកចម្រើន (Dayaram, 2011)។ ការចូលរួមរបស់សហគមន៍ប្រកបដោយនិរន្តរភាព និងភាពរឹងមាំនៅក្នុងការគ្រប់គ្រងសាលារៀនក្នុងសហគមន៍អាចបង្កើនតម្លាភាព និងគណនេយ្យភាពក្នុងប្រព័ន្ធការអប់រំ និងលើកកម្ពស់ភាពជាម្ចាស់ ជាភ្នាក់ងារទទួលខុសត្រូវចំពោះការផ្លាស់ប្តូរជាវិជ្ជមាន។ ការអប់រំក៏ត្រូវបានគេដឹងថាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច។

ការបង្កើនការទទួលស្គាល់ពីតម្រូវការសម្រាប់សហគមន៍ ដើម្បីឱ្យភាគីចូលរួមនៅក្នុងការផ្លាស់ប្តូរដែលកំពុងជំរុញអ្នកបង្កើតគោលនយោបាយស្វែងរកវិធីសាស្ត្រ និងកម្មវិធីណាមួយដែលជំរុញគោលដៅផ្អែកលើតម្រូវការ និងការរំពឹងទុករបស់សហគមន៍។ Williams (1994) បានកំណត់គំរូបីនៃការភ្ជាប់ដទំនាក់ទំនងសហគមន៍ក្នុងការអប់រំ។ **គំរូទី១៖** ការអប់រំតាមសហគមន៍ប្រពៃណីគឺជា ការអប់រំដែលដំណើរការក្នុងស្រុកត្រូវបានបង្កប់យ៉ាងជ្រៅនៅក្នុងមូលដ្ឋានបទដ្ឋានសង្គម ហើយរដ្ឋាភិបាលមានតួនាទីតិចតួចបំផុត។ មនុស្សជំនាន់ចាស់ជាអ្នកចែករំលែកជំនាញដ៏សំខាន់ទៅឱ្យសមាជិកក្មេងៗក្នុងសហគមន៍។ នៅក្នុង**គំរូទីពីរ៖** រដ្ឋាភិបាលជាអ្នកផ្តល់សេវាអប់រំ ដែលជាគន្លឹះក្នុងការផ្តល់ការគ្រប់គ្រង និងកំណត់ស្តង់ដារនៃការអប់រំហើយសហគមន៍ គឺជាអ្នកទទួល(អកម្ម) ។ **គំរូទីបី៖** គឺគំរូនៃការសហការ។ ដូចនេះ ការចូលរួមបង្កើតជាយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពសម្រាប់ការសម្រេចបាននូវគោលបំណងដូចជា ការធ្វើឱ្យ

ប្រសើរឡើងនូវលទ្ធភាពទទួលបាន និងគុណភាពការបញ្ចេញយោបល់អំពីតម្រូវការ និងគោលបំណងជាក់លាក់របស់សហគមន៍។ ការអភិវឌ្ឍកម្មវិធីសិក្សាដោយសហការជាមួយគណៈកម្មការសាលារៀនដើម្បីកែលម្អចំណុចខ្វះខាត បង្កើតគណនេយ្យភាព និងធានានិរន្តរភាពនៃកម្មវិធីដែលត្រូវបានអនុវត្ត (Pailwar & Mahajan, 2005) គុណភាពនៃការអប់រំ៖ លទ្ធផលសិក្សាដែលជាគុណភាពនៃការអប់រំគឺវាស់វែងដោយអក្ខរកម្ម និងជំនាញលេខរបស់សិស្សក៏ជាប្រសិទ្ធភាពនៃសូចនាករចម្បងនៃប្រព័ន្ធអប់រំសាធារណៈ។

## ២.៨ ការស្រាវជ្រាវថ្មីៗនៃការចូលរួមសហគមន៍ក្នុងការអប់រំ

ប៉ុន្មានឆ្នាំចុងក្រោយនេះ មានការសិក្សាជាច្រើនដែលធ្វើឡើងលើការចូលរួមរបស់សហគមន៍ក្នុងការអប់រំនៅតាមទីតាំងផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា ជាឧទាហរណ៍ Save the Children Cambodia (2015) បានធ្វើការសិក្សាលើកម្មវិធីមួយដែលមានឈ្មោះថា កំណែទម្រង់ថវិកា (Base Budget Reform) និង ការចូលរួមរបស់សហគមន៍ក្នុងការអប់រំបឋមសិក្សានៅកម្ពុជា។ **ងួន** (2012) បានធ្វើសិក្សាលើការចូលរួមរបស់មាតាបិតាសិស្សក្នុងការអប់រំ ហើយ Pak (2012) បានសិក្សាភាពជាដៃគូរវាងសាលារៀន គ្រួសារ និងសហគមន៍។ ការសិក្សាទាំងនេះផ្តោតលើការចូលរួមរបស់សហគមន៍ជាពិសេសភាគីពាក់ព័ន្ធនៅក្នុងវិស័យអប់រំនៅកម្ពុជា ចំណែកឯការសិក្សានេះផ្តោតជារួមលើសហគមន៍ទាំងអស់។ ទោះបីជាអង្គការ Save the Children Cambodia បានធ្វើការសិក្សាដោយសង្ខេបស្រដៀងនឹងខ្ញុំផ្ទាល់ក៏ដោយ ការសិក្សារបស់ពួកគេត្រូវបានអនុវត្តយ៉ាងច្រើនជាមួយមន្ត្រីរដ្ឋាភិបាល គ្រូបង្រៀន និងភាគីពាក់ព័ន្ធអង្គការក្រៅរដ្ឋាភិបាល និងមិនមានការចូលរួមពីឪពុកម្តាយ និងសមាជិកសហគមន៍។ គោលបំណងនៃការសិក្សារបស់ពួកគេគឺដើម្បីវាយតម្លៃវឌ្ឍនភាព និងបញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំនៅកម្រិតបឋមសិក្សាដោយប្រើវិធីសាស្ត្រគុណភាព។

យោងតាមការសិក្សារបស់អង្គការ Save the Children Cambodia ការចូលរួមពីសហគមន៍ចែកចេញជាពីរប្រភេទ៖ ការចូលរួមដោយផ្ទាល់ និងដោយប្រយោល។ **ទីមួយ៖**សហគមន៍ (ជាពិសេស ឪពុកម្តាយ) បានចូលរួមតាមរយៈការចូលរួមក្នុងពិធីបើកបវេសនការ ការចុះហត្ថលេខាលើ កំណត់ត្រាសិក្សា

ប្រចាំខែរបស់សិស្ស រួមចំណែកធនធានសម្រាប់ការអភិវឌ្ឍសាលារៀន និងផ្ដល់ការបង្រៀនឯកជនឱ្យកូនរបស់ពួកគេ។ **ទីពីរ៖** សហគមន៍បានចូលរួមដោយផ្ទាល់ក្នុងការអប់រំតាមរយៈគណៈកម្មការគ្រប់គ្រងសាលាដែលជាអ្នកតំណាងរបស់ពួកគេ។ គណៈកម្មការគ្រប់គ្រងសាលាបានចូលរួមក្នុងការប្រមូល និងលើកទឹកចិត្តកុមារឱ្យទៅសាលារៀន គៀងគរធនធានសហគមន៍ជួយក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងជានាសុវត្ថិភាពកុមារនៅក្នុងសាលារៀន និងសហគមន៍។ ការសិក្សារបស់ពួកគេក៏បានរកឃើញបញ្ហាប្រឈមនៃការចូលរួមមួយចំនួនផងដែរដូចជា គណៈកម្មការគ្រប់គ្រងសាលាដែលខ្វះសមត្ថភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុដែលរារាំងពួកគេក្នុងការសម្រេចចិត្តអំពីការគ្រប់គ្រងថវិកាសាលា។ តម្លាភាពក្នុងការចែករំលែកព័ត៌មានអំពីផែនការថវិកា ការដោះស្រាយបញ្ហាទាក់ទងនឹងការបង្រៀនដែលគ្មានប្រសិទ្ធភាព និងមុខងាររបស់គណៈកម្មការគ្រប់គ្រងសាលា ។

ទោះបីជាការសិក្សារបស់ពួកគេបានកំណត់ដំណើរការ និងបញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍នៅក្នុងការអប់រំការសិក្សាមិនរួមបញ្ចូលទស្សនៈរបស់ឪពុកម្ដាយ និងសមាជិកសហគមន៍ទេ។ វាក៏មិនបានស្វែងយល់ពីទម្រង់នៃការចូលរួមផ្សេងទៀតដូចជាទំនាក់ទំនង ការចិញ្ចឹមបីបាច់ថែរក្សា ការរៀនសូត្រនៅផ្ទះ ការស្ម័គ្រចិត្ត និងសហការជាដើម។ លើសពីនេះ ការសិក្សានេះមានការផ្ដោតអារម្មណ៍អំពីវិធីដែលក្រុមសហគមន៍ចូលរួមជាជាងទំនាក់ទំនង រវាងសាលារៀន និងសហគមន៍ដែលការសិក្សានេះមានគោលបំណង។ ការសិក្សាខ្នាតធំថ្មីមួយទៀតត្រូវបានធ្វើឡើងដោយ Ngoun (2012) ដើម្បីកំណត់ការចូលរួមឪពុកម្ដាយក្នុងការសិក្សារបស់កុមារនៅអនុវិទ្យាល័យនៅប្រទេសកម្ពុជា។ ទោះយ៉ាងណាក៏ដោយការសិក្សាស្រាវជ្រាវមិនបានគ្របដណ្ដប់ការចូលរួមរបស់ប្រជាជនក្នុងសហគមន៍នោះទេ វាផ្ដោតតែលើការចូលរួមរបស់មាតាបិតាសិស្ស។ ការសិក្សាបានរកឃើញថា ការចូលរួមរបស់មាតាបិតាក្នុងវិស័យអប់រំបីប្រភេទ៖ (១)ការរួមចំណែករបស់មាតាបិតាសិស្សដល់សាលារៀន (២)ការចូលរួមនៅតាមសាលា និង(៣)ការចូលរួមនៅផ្ទះ។ មាតាបិតាសិស្សរួមចំណែកទាក់ទងនឹងការរួមចំណែកជាថវិកា សម្ភារៈ និងកម្លាំងពលកម្មដើម្បីឆ្លើយតបទៅនឹងការសំណូមពររបស់សាលា។ ការចូលរួមនៅតាមសាលា គឺជាការចូលរួមរបស់មាតាបិតាសិស្សនៅក្នុងព្រឹត្តិការណ៍សាលា ការប្រជុំ និងការពិគ្រោះយោបល់ជាមួយសាលា។ ការ

ចូលរួមនៅផ្ទះគឺការចូលរួមរបស់ឪពុកម្តាយក្នុងការបញ្ជូនកូនទៅសាលារៀន ការពិនិត្យមើលកិច្ចការផ្ទះរបស់កុមារ។ ការចូលរួមនៅផ្ទះគឺនិយាយជាមួយកុមារអំពីវឌ្ឍនភាពនៃការសិក្សារបស់ពួកគេដោយធានាថាកុមារមានភាពសមស្របបរិយាកាសសិក្សា និងលើកទឹកចិត្តកុមារឱ្យសិក្សាពេញមួយជីវិត។ ការសិក្សាបន្ថែមដែលធ្វើឡើងដោយ Pak (2012) គឺស្តីពីការចូលរួមរបស់សហគមន៍ក្នុងការអប់រំដោយផ្តោតតែលើបណ្តាញទំនាក់ទំនងដែលប្រើប្រាស់ដោយសហគមន៍ និងភាគីពាក់ព័ន្ធអប់រំប៉ុណ្ណោះដើម្បីសិក្សាឈ្វេងយល់ពីទំនាក់ទំនងនៃការរៀនសូត្ររបស់កុមារ។ Pak បានរកឃើញថាការអនុវត្តភាពជាដៃគូរវាងសាលារៀន គ្រួសារ និងសហគមន៍គឺមិនទាន់ទទួលបានលទ្ធផលនៃការចូលរួមរបស់សហគមន៍ក្នុងគោលនយោបាយសាលាកុមារមេត្រីខ្ពស់នៅឡើយ។ Pak បានស្នើការស្រាវជ្រាវបន្ថែមលើទម្រង់ផ្សេងទៀតនៃសហគមន៍ និងការចូលរួមរបស់មាតាបិតាសិស្សនៅក្នុងការរៀនសូត្ររបស់កុមារ។ ការសិក្សាស្រាវជ្រាវរបស់ខ្ញុំឆ្លើយតបទៅនឹងសំណូមពរនេះក្នុងការស្វែងយល់អំពីទម្រង់នៃការចូលរួមសហគមន៍ក្នុងការអប់រំ។

## ២.៩ ការចូលរួមរបស់សហគមន៍ក្នុងគោលនយោបាយអប់រំនៅប្រទេសកម្ពុជា

ឯកសារគោលនយោបាយអប់រំ មានសារៈសំខាន់ណាស់ក្នុងការយល់ដឹងពីគោលគំនិតយល់ឃើញក្នុងបរិបទគោលនយោបាយសំខាន់ជាងការស្វែងយល់ពីអត្ថន័យ នៃការចូលរួមរបស់សហគមន៍ក្នុងការកំណត់ជាក់លាក់មួយ។ របៀបដែលសហគមន៍ចូលរួមក្នុងការអប់រំនៅក្នុងកំណែទម្រង់គោលនយោបាយអប់រំដែលល្បី និងថ្មី៖ សាលារៀនបណ្តាញ(CS) និងគោលនយោបាយរបស់សាលាកុមារមេត្រី (CFS)និង សាលាជំនាន់ថ្មី(NGS)។

### ២.៩.១ គោលនយោបាយសាលាបណ្តាញ និងការចូលរួមរបស់សហគមន៍

បន្ទាប់ពីស្ថិរភាពនយោបាយ និងសន្តិភាពប្រទេសកម្ពុជាត្រូវបានស្តារឡើងវិញនៅដើមទស្សវត្សរ៍ឆ្នាំ១៩៩០ ព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្តើមកែលម្អវិស័យអប់រំក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់របស់ប្រទេសខ្លួន។ ក្នុងអំឡុងពេលនោះការអប់រំទាមទារឱ្យមានទាំងគោលនយោបាយសាលា និងការចូលរួមរបស់សហគមន៍។ ឧទាហរណ៍ ថ្នាក់រៀន អគារសិក្សា និងសម្ភារសិក្សា និងបង្រៀនមាន ការផ្គត់

ផ្តល់រយៈពេលខ្លី។ បុគ្គលិកបង្រៀនជាពិសេសអ្នកដែលធ្វើការក្នុងឆ្នាំ**១៩៧៩** មានគុណវុឌ្ឍិទាប និងបទពិសោធន៍តិចតួចក្នុងការបង្រៀន។ ជាការឆ្លើយតបទៅនឹងបញ្ហាបែបនេះក្នុងឆ្នាំ**១៩៩៣** ដោយគិតគូរពីលទ្ធផល និងទទួលបានបទពិសោធន៍នៃប្រទេសនានាក្នុង និងក្រៅតំបន់ជាពិសេសប្រទេសដែលទើបតែចប់ពីសង្គ្រាមក្នុងការអនុវត្តកម្មវិធីសាលាបណ្តាញក្រោយពីបានសិក្សាមួយរយៈដោយយកចិត្តទុកដាក់ ។

ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចកែសម្រួលកម្មវិធីអភិវឌ្ឍន៍សាលារៀនជាក្រុមសម្រាប់ការសាកល្បងនៅក្នុងសាលារៀននីមួយៗរបស់ខ្លួន។ ការព្យាយាមលើកកម្ពស់បរិមាណ និងគុណភាពនៃការអប់រំទាក់ទងនឹងបរិបទភូមិសាស្ត្រ និងសេដ្ឋកិច្ចសង្គមប្រទេសកម្ពុជា។ អ្នកបើកយន្តហោះនៅឆ្នាំ**១៩៩៣** គឺគាំទ្រដោយ UNICEF ក្នុងខេត្តចំនួនបួន និងដោយ Save the Children Norway (SCN) (ពីមុនត្រូវបានគេស្គាល់ថា Redd Barna) នៅក្នុងខេត្ត/ក្រុងចំនួនបី។ ផ្អែកលើលទ្ធផលវិជ្ជមាននៃកម្មវិធីសាកល្បង ក្រសួងអប់រំ យុវជន និងកីឡាក្នុងឆ្នាំ**១៩៩៥** បានបង្កើតសាលាបណ្តាញមួយ។ គោលនយោបាយត្រូវដាក់ឱ្យប្រើប្រាស់ទូទាំងប្រទេសដោយកំណត់ថា ក្រុមសាលារៀនមួយនៅក្នុងស្រុកមួយរួមបញ្ចូលគ្នាក្នុងចំណោមសាលារៀនដែលមានទីតាំងនៅជិត និងងាយស្រួលសម្រាប់ទំនាក់ទំនងទៅវិញទៅមកដោយមិនគិតពីភាពខុសគ្នា (MoEYS, 2000, p. 8) សាលាបណ្តាញមានសាលាស្នូល និងសាលាបណ្តាញចាប់ពីប្រាំទៅប្រាំមួយសាលាក្នុងមួយក្រុមអាស្រ័យលើចំនួនសរុបរបស់សាលា និងភូមិសាស្ត្រ។ សមាជិកសហគមន៍បានសម្រេចចិត្តគាំទ្រសាលា ដោយសារតែពួកគេមើលឃើញពីសារៈសំខាន់លើការអប់រំកូនៗរបស់ខ្លួន និងតួនាទីរបស់សាលាចូលរួមដើម្បីកំណត់អនាគតកូនរបស់ពួកគេ។ ឆន្ទៈ និងសេចក្តីប្រាថ្នារបស់ឪពុកម្តាយចង់ឃើញកូនៗមានអនាគតដ៏ល្អប្រសើរជាកត្តាសំខាន់ ដែលជំរុញឱ្យសហគមន៍ចូលរួមក្នុងការអប់រំ។ កត្តានៃការលើកទឹកចិត្តខាងក្នុងនេះគឺមានឥទ្ធិពលលើការសម្រេចចិត្តចូលរួមក្នុងសកម្មភាពសាលាជាជាងកត្តាខាងក្រៅដូចដែលបានពន្យល់ខាងលើ។ ចំនួនប្រជាជន និងទីតាំងភូមិសាស្ត្រនៃសាលារៀនទាក់ទងនឹងសហគមន៍ ការចូលរួមជាគោលបំណងមួយក្នុងចំណោមគោលបំណងទាំងប្រាំបីរបស់សាលាបណ្តាញគឺ ដើម្បីប្រមូលផ្តុំសហគមន៍ដើម្បីចូលរួមយ៉ាងសកម្មក្នុងវិស័យអប់រំ (MoEYS, 2000, p. 13)។ គោលការណ៍ណែនាំនៃសាលាបណ្តាញរបស់ MoEYS (2000) គឺសង្កត់ធ្ងន់

លើសារៈសំខាន់នៃការចូលរួមរបស់សហគមន៍ផងដែរ។ ការចូលរួមសម្រាប់ការអភិវឌ្ឍន៍សាលារៀនជាក្រុមប្រកបដោយជោគជ័យដោយកែលម្អទំនាក់ទំនងរវាងសាលារៀនបណ្ដាញ និងសហគមន៍មូលដ្ឋានដូចខាងក្រោម៖ សាលាបណ្ដាញត្រូវតែមានទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានដើម្បី៖

- ធ្វើឱ្យសហគមន៍យល់ដឹង និងទទួលយក មានទំនួលខុសត្រូវក្នុងការអប់រំ
- ផ្សព្វផ្សាយព័ត៌មានដល់សហគមន៍អំពីអ្វីពួកគេមានអ្វីដែលពួកគេបានធ្វើ អ្វីដែលពួកគេកំពុងធ្វើ និងអ្វីដែលពួកគេគ្រោងនឹងធ្វើនៅពេលខាងមុខ
- ប្រមូលផ្តុំសហគមន៍ឱ្យចូលរួម និងគាំទ្រសាលារៀនទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកស្មារតី
- ផ្សព្វផ្សាយលទ្ធផលសិក្សារបស់សិស្សានុសិស្សដើម្បីឱ្យឪពុកម្ដាយដឹងនិងជួយលើកទឹកចិត្ត កូនរៀនបន្ថែម ហើយនឹងមិនបង្ខំកូនទេ។
- ធ្វើឱ្យសហគមន៍យល់ដឹងអំពីផលប្រយោជន៍រួម និងរបៀបសហការគ្នាទៅវិញទៅមក
- ផ្សព្វផ្សាយវិធីសាស្ត្រគ្រប់គ្រង សហគមន៍
- ប្រមូលព័ត៌មានអំពីតម្រូវការរបស់សហគមន៍សម្រាប់ការអប់រំ
- កែសម្រួលកម្មវិធីសិក្សាតាមតម្រូវការជាក់ស្តែងរបស់សហគមន៍
- គៀងគរសហគមន៍ឱ្យចូលរួមអនុវត្តជំរឿនកុមារ និងបញ្ជូនកូនទៅសាលារៀន
- ធានាដល់សហគមន៍ថាកុមារទទួលបានចំណេះដឹងសាកសមនឹងការរស់នៅរបស់ពួកគេ
- ផ្សព្វផ្សាយពាក្យស្លោក៖ «សាលារៀនសម្រាប់សហគមន៍ សហគមន៍គឺសម្រាប់សាលារៀន» គោលបំណងនាំយក សមិទ្ធិផលពិតប្រាកដសម្រាប់សង្គម(ទំព័រ ១៤-១៥)។ ទាក់ទងនឹងបញ្ហានេះ សាលាបណ្ដាញតំណាងឱ្យរចនាសម្ព័ន្ធអំណោយផលក្នុងការរៀបចំ ការចូលរួមរបស់សហគមន៍នៅក្នុងសាលារៀនដែលមានលក្ខណៈជាប្រពៃណីរបស់ប្រទេសកម្ពុជា។ ការរួមចំណែកបែបនេះត្រូវបានបង្ហាញដោយការសិក្សារបស់ Bray (1999) ដែលចង្អុលបង្ហាញ គ្រួសារបានរួមចំណែកក្នុងទម្រង់ផ្សេងៗគ្នា ៧៧ភាគរយនៃការចំណាយសរុបសម្រាប់ការអប់រំបឋម។ ការសិក្សាតាមដានរបស់ Bray និង Bunly (2005) ក៏បញ្ជាក់ផងដែរ។ ការរួមចំណែករបស់គ្រួសារនៅតែ

ខ្ពស់រហូតដល់ ៥៦ភាគរយនៃការចំណាយសរុបនៃកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីបង្កើនការរួមចំណែករបស់ខ្លួន។

### ២.៩.២ គោលនយោបាយសាលាកុមារមេត្រី និងការចូលរួមរបស់សហគមន៍

ការកសាងសមិទ្ធិផលនៃកំណែទម្រង់សាលាបណ្តាញ និងកំណែទម្រង់អប់រំជាបន្តបន្ទាប់ផ្សេងទៀតរបស់ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ ២០០៥ បានអំពាវនាវឱ្យអង្គការ UNICEF, SCN អង្គការជាដៃគូនានានៅប្រទេសកម្ពុជាដើម្បីអភិវឌ្ឍការអប់រំនៅបឋមសិក្សា។ អង្គការ(KAPE) តំណាងខេត្តដែលកំពុងអនុវត្តកម្មវិធីសាកល្បងសាលាកុមារមេត្រី(CFS) និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់ដែលធ្វើការនៅក្នុងសាលាកុមារមេត្រី(CFS) ដើម្បីជួបប្រជុំគ្នាបង្កើតក្របខ័ណ្ឌសាលាកុមាមេត្រី (CFS )សម្រាប់ការអនុវត្តទូទាំងប្រទេស។ ឯកសារគោលនយោបាយបានកំណត់យ៉ាងច្បាស់នូវអ្វីដែលសាលាកុមារមេត្រី និងបង្ហាញនូវក្រេបខ័ណ្ឌរបស់ខ្លួនសម្រាប់ការលើកកម្ពស់គុណភាព នៃសាលាកុមាមេត្រីនៅក្នុងប្រទេស។ គោលបំណង CFS ត្រូវបានបកស្រាយថា «សាលាដែលទទួលស្គាល់ និងចិញ្ចឹមបីបាច់ថែរក្សា ការសម្រេចបាននូវសិទ្ធិជាមូលដ្ឋានរបស់កុមារ»។ សាលាកុមារមេត្រី(CFS )ធ្វើការជាមួយភាគីពាក់ព័ន្ធទាំងអស់ជាពិសេសមាតាបិតាសិស្ស អាណាព្យាបាលសិស្ស និងផ្តល់ការរួមចំណែកមានតម្លៃជាច្រើនដល់កុមារទាំងអស់បានទៅសាលារៀនបង្កើតបរិយាកាសសិក្សាសម្រាប់កុមារ និងគុណភាពសិក្សាប្រកបដោយប្រសិទ្ធភាពស្របតាមតម្រូវការបច្ចុប្បន្ន និងអនាគតរបស់កុមារ។ បរិយាកាសសិក្សារបស់ CFS គឺមានលក្ខណៈប្រកបដោយសមធម៌ តុល្យភាព សេរីភាព សាមគ្គីភាព អហិង្សា និងយកចិត្តទុកដាក់លើសុខភាពផ្លូវកាយផ្លូវចិត្ត និងអារម្មណ៍របស់កុមារ។ ទាំងនេះជាកត្តាជំរុញដល់ការអភិវឌ្ឍន៍ចំណេះដឹង ជំនាញ អាកប្បកិរិយា គុណតម្លៃ សីលធម៌ដើម្បីឱ្យកុមារអាចរស់នៅជាមួយគ្នាប្រកបដោយសុខដុមរមនា (MoEYS, 2007a, p.4)។ ក្របខ័ណ្ឌសាលាមេត្រីនៅកម្ពុជារួមមានប្រាំមួយសមាសភាគដូចបានបង្ហាញក្នុងតារាងខាងក្រោម៖

| | |
|---|---|
| សមាសភាគទី១ | កុមារទាំងអស់បានចូលរៀន |
| សមាសភាគទី២ | ការសិក្សាប្រកបដោយប្រសិទ្ធភាព |

| | |
|---|---|
| សមាសភាគទី៣ | សុខភាព សុវត្ថិភាព និងការការពារកុមារ |
| សមាសភាគទី៤ | ការឆ្លើយតបទៅនឹងយេនឌ័រ |
| សមាសភាគទី៥ | ការចូលរួមរបស់កុមារ គ្រួសារនិង សហគមន៍ |
| សមាសភាគទី៦ | ការគាំទ្រកម្មវិធីរបស់ប្រព័ន្ធអប់រំ |

(ប្រភពពី MoEYS, 2007a, p. 5)

ទាក់ទងនឹងការចូលរួមរបស់សហគមន៍ គោលនយោបាយទទួលស្គាល់តួនាទីសហគមន៍មូលដ្ឋាន បានចូលរួមដើម្បីជួយសាលារៀនដូចមានចែងខាងលើនៅក្នុងសមាសភាគទី៥ នៃក្របខ័ណ្ឌសាលាកុមារមេត្រី(CFS)ដែលមានគោលបំណងលើកម្ពស់ទំនាក់ទំនងសាលារៀន គ្រួសារ និងសហគមន៍ដើម្បីធ្វើឱ្យសាលារៀនក្លាយជាមជ្ឈមណ្ឌលអភិវឌ្ឍមួយរបស់សហគមន៍។ នោះគឺសហគមន៍ត្រូវបានគេរំពឹងថានឹងចូលរួមក្នុងសកម្មភាព និងព្រឹត្តិការណ៍ដូចជាការប្រមូលការងាររបស់កុមារបានផលិត និងការតាំងពិពណ៌សកម្មភាពសង្គម ដើម្បីផលប្រយោជន៍សហគមន៍ ក្រុមប្រឹក្សានិស្សិត និងយុទ្ធសាស្ត្រដែលសាលារៀនជួយគ្រួសារ និងសហគមន៍។ គោលនយោបាយនេះក៏បានគូសបញ្ជាក់ថា CFS មិនត្រឹមតែធ្វើឱ្យសាលាមានភាពទាក់ទាញ និងរួសរាយរាក់ទាក់ចំពោះសិស្សប៉ុណ្ណោះទេ ថែមទាំងជាតំណាងឱ្យសាលាដែលគាំទ្រដល់ការអភិវឌ្ឍន៍របស់កុមារ សាលា និងសហគមន៍ (MoEYS,2007a)។

សាលាកុមារមេត្រី គឺជាសាលាដែលទទួលស្គាល់ថាជួយគាំទ្រនូវលទ្ធផលសិក្សារបស់សិស្សដោយផ្អែកលើសិទ្ធិកុមារជាមូលដ្ឋាន។ សាលាកុមារមេត្រីសហការជាមួយភាគីពាក់ព័ន្ធ ពិសេសមាតាបិតាសិស្ស ឬអាណាព្យាបាលសិស្ស និងផ្តល់តម្លៃខ្ពស់ដល់ការងារអប់រំដោយខិតខំប្រឹងប្រែងចូលរួមចំណែកក្នុងការស្វែងរកកុមារឱ្យចូលរៀនគ្រប់គ្នា និងបង្កើតបរិស្ថានសិក្សាដ៏កក់ក្តៅសំដៅដល់កុមារទាំងនោះបានចូលរៀនប្រកបដោយគុណភាព និងប្រសិទ្ធភាពស្របតាមតម្រូវការជាក់ស្តែងរបស់ពួកគេ។ បរិស្ថានសិក្សាកុមារមេត្រីបង្ហាញនូវលក្ខណៈសមធម៌ សមភាព សេរីភាព សាមគ្គីភាព គ្មានអំពើហិង្សារួមទាំងសុខភាពរាងកាយ បញ្ញា និងផ្លូវចិត្ត ដែលជាកិច្ចជានាក្នុងការអភិវឌ្ឍកុមារឱ្យមានសមត្ថភាពប្រកបដោយចំណេះដឹង បំណិន ឥរិយាបថ តម្លៃ និងសីលធម៌ល្អដើម្បីឱ្យពួកគេចេះរួមរស់នៅជាមួយគ្នាក្នុងភាពសុខដុមរមនា។

សាលាកុមារសេត្រីជានិច្ចកាលមានភាពស្និទ្ធស្នាល នឹងស្រឡាញ់កុមារជួយគាំទ្រកុមារឱ្យមានការអភិវឌ្ឍ ព្រមទាំងមានមេត្រីភាពចំពោះសហគមន៍។

## ២.៩.៣ គោលនយោបាយសាលាជំនាន់ថ្មី (NG) និងការចូលរួមរបស់សហគមន៍

សាលារៀនជំនាន់ថ្មី គឺជាកម្មវិធីកំណែទម្រង់ប្រព័ន្ធអប់រំរបស់រាជរដ្ឋាភិបាលកម្ពុជាដែលជាមាគ៌ាអភិវឌ្ឍន៍ថ្មីមួយនៅក្នុងប្រព័ន្ធអប់រំនាពេលបច្ចុប្បន្នដែលជួយបង្កើតសាលារៀនសាធារណៈស្វយ័ត។ ការបង្កើតសាលាជំនាន់ថ្មីជាលំនាំបន្តពីកិច្ចខិតខំប្រឹងប្រែងនៃកម្មវិធីសាលាកុមារមេត្រី ដោយយកលំនាំតាមការអនុវត្តនៅក្នុងបណ្តាប្រទេសមួយចំនួន ដែលសាលារៀនសាធារណៈមួយចំនួនបានស្វ័យភាពយ៉ាងច្រើនពីរាជរដ្ឋាភិបាលដើម្បីជំរុញនវានុវត្តអប់រំ (MoEYS,2016)។ គំនិតសម្រាប់ការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំត្រូវផ្តួចផ្តើមឡើងដំបូងដោយអង្គការ KAPE ដែលជាអង្គការក្នុងស្រុកធំបំផុតដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្ពុជាហើយក្រោយអង្គការនេះត្រូវបានអនុម័ត និងត្រូវបានឧបត្ថម្ភថវិកាដោយក្រសួងអប់រំយុវជន និងកីឡា។ បន្ទាប់ពីមានប្រតិបត្តិការអស់រយៈពេល៣ឆ្នាំកន្លងមកទស្សនៈរបស់សហគមន៍ទៅលើគុណភាពអប់រំដែលយ៉ាងហោចណាស់នៅក្នុងសាលារៀនពីររបស់គម្រោងមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងនេះក្តី និរន្តភាពនៃគំរូនេះនៅតែជាបញ្ហាប្រឈមដោយសារតែថវិកា PB និងSIG មិនមានគ្រប់គ្រាន់សម្រាប់រក្សាស្តង់ដារ ដែលគម្រោងផ្តល់ឱ្យក៏វាក៏មិនមែនជាប្រភពប្រាក់ចំណូលដែលផ្តល់ឱ្យបានទៀងទាត់ និងមានភាពបត់បែនគ្រប់គ្រាន់នោះដែរ។ នៅក្នុងឆ្នាំ២០១៤ អង្គការខេបបានចាប់ផ្តើមការពិសោធន៍ដ៏ធំមួយនៅក្នុងសាលាអនុវត្តនៅក្នុងក្រុងកំពង់ចាមគឺសាលា Beacon ដើម្បីទ្រទ្រង់គំរូនេះដោយមានការគាំទ្រពីឪពុកម្តាយសិស្ស ដោយដាក់ចេញនូវការប្តេជ្ញាចិត្តខ្ពស់ក្នុងការលប់បំបាត់អំពើពុករលួយដែលបានរីករាលដាលក្នុងប្រព័ន្ធអប់រំ។ ការសន្យាទាំងនេះផ្សារភ្ជាប់ជាមួយស្តង់ដារអប់រំខ្ពស់ដែលបានរៀបចំជាមុនធ្វើជាបុរេលក្ខខណ្ឌចំពោះការបង់ថ្លៃសិក្សាដោយស្ម័គ្រចិត្ត សម្រាប់ឪពុកម្តាយដែលមានជីវភាពថ្នាក់កណ្តាល។ ការចរចាស្រដៀងគ្នានេះនឹងត្រូវយកទៅអនុវត្តសម្រាប់សាលាពីរទៀតរបស់គម្រោងដោយរង់ចាំលទ្ធផលនៃការសាកល្បងនៅក្នុងសាលាអនុវត្តជាមុនសិន។

គោលបំណងរបស់ NGS គឺការបង្កើតសាលារដ្ឋដែលរក្សាបាននូវស្តង់ដារនៃការអប់រំបានខ្ពង់ខ្ពស់បំផុតតាមរយៈការវិនិយោគថវិកាច្រើន។ NGS ផ្តោតទៅលើការពង្រឹងតម្លាភាព និងទទួលខុសត្រូវដោយការផ្លាស់ប្តូរវិធីគ្រប់គ្រងសាលា។ ប្រសិនបើមិនមានការទទួលខុសត្រូវក្នុងការគ្រប់គ្រងសាលារៀនទេនោះសម្ភារបរិក្ខារដូចជាបន្ទប់ពិសោធវិទ្យាសាស្ត្រនឹងមិនត្រូវបានប្រើប្រាស់ឱ្យអស់ពីសមត្ថភាពទេ ពីព្រោះគ្រូបង្រៀនរវល់តែស្វិតស្វាញក្នុងការបង្រៀនគួរយកលុយក្រៅម៉ោងវិញ និងមានភាពលម្អៀងទៅលើសិស្សរៀនគួរជាងសិស្សដែលមិនមានលុយរៀនគួរ។ សាលាជំនាន់ថ្មីព្យាយាមដោះស្រាយបញ្ហានេះដោយការលុបបំបាត់នៃចំណុចអវិជ្ជមានទាំងនេះ ( **ហង់ ជួនណារ៉ុន** ) គ្រូបង្រៀនត្រូវបានជ្រើសរើសយ៉ាងល្អិតល្អន់ និងទទួលបានអត្ថប្រយោជន៍ជាច្រើនដូចជាការផ្តល់អាហារូបករណ៍ ដើម្បីពង្រឹងគុណធម៌ក្នុងការបង្រៀន និងសុចរិតភាពព្រមទាំងប្រាក់លើកទឹកចិត្តបន្ថែម។ សាលារៀនជំនាន់ថ្មីក៏ត្រូវបានសាងសង់ឡើងដោយមានការចូលរួមពីឪពុកម្តាយរបស់សិស្សផងដែរ។ លោក **ផាន់ ប៊ុនណាត** នាយកប្រតិបត្តិរបស់ NGS បានថ្លែងថា៖ «ប្រសិនបើឪពុកម្តាយមិនមានអារម្មណ៍ថាសាលារៀននេះជាកម្មសិទ្ធិរបស់ពួកគេ ពួកគេនឹងមិនមានការយកចិត្តទុកដាក់ខ្លាំងនោះទេ»។ ឪពុកម្តាយឥឡូវនេះទទួលបន្ទុកមួយចំនួន ហើយពួកគាត់អាចតស៊ូស្វិតស្វាញដើម្បីជាប្រយោជន៍ដល់កូនៗរបស់គាត់ មនុស្សទាំងអស់ត្រូវតែមានការយល់ដឹង និងធ្វើការរួមគ្នា។

ដើម្បីពន្យល់អំពីទំនាក់ទំនងនេះលោក **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាបានមានប្រសាសន៍ថា៖ «សាលារៀនជំនាន់ថ្មីផ្តល់នូវគំរូវិធីសាស្ត្រគ្រប់គ្រងចម្រុះដែលអនុញ្ញាតឱ្យសហគមន៍មានឱកាសចូលរួមក្នុងការគ្រប់គ្រងសាលារដ្ឋ ហើយសាលារៀនអាចមានការបត់បែនក្នុងការអនុវត្តកម្មវិធីសិក្សាផងដែរ»។ ហេតុផលដែលក្រសួងអប់រំ យុវជននិងកីឡាសម្រេចចិត្តប្រគល់កម្មវិធីសាលាជំនាន់ថ្មីនេះទៅក្នុងដៃរបស់អង្គការ KAPE ព្រោះពួកគេបង្រៀនសិស្សអំពីជំនាញដែលត្រូវការចាំបាច់ក្នុងសតវត្សរ៍ទី២១ មិនមែនតែចំណេះដឹងទូទៅ និងអក្ខរកម្មនោះទេ ប៉ុន្តែក៏មានជំនាញ ICT និងជំនាញភាសាបរទេសផងដែរ។ ពួកគេក៏ត្រូវមានការយល់ដឹងពីជីវិតពិត ជំនាញក្នុងការប្រាស្រ័យទាក់ទង ការគិតស៊ីជម្រៅ ការដោះស្រាយបញ្ហា និងការទំនាក់ទំនង» (**ហង់ ជួនណារ៉ុន**)។ លោកបន្តថា កម្មវិធីសិក្សា និងការអនុវត្តកម្ម

វិធីសិក្សារបស់សាលារៀនជំនាន់ថ្មីធ្វើឡើងដោយកម្មវិធីសិក្សាស្តង់ដារខ្ពស់ និងស្តង់ដារគ្រូបង្រៀនខ្ពស់ ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់មាតាបិតាសិស្សផង និងគោលដៅនៃការអភិវឌ្ឍនសេដ្ឋកិច្ចជាតិផងដែរ។ ក្នុងការបង្កើតសាលាជំនាន់ថ្មីនេះតម្រូវឱ្យមានជាចាំបាច់នូវបន្ទប់កុំព្យូទ័រ និងបន្ទប់ពិសោធន៍ ដើម្បីជួយគាំទ្រដល់សិស្សក្នុងការសិក្សាស្វែងយល់លើផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ការសិក្សាដែលមានគុណភាព គឺត្រូវផ្សាភ្ជាប់ទ្រឹស្តី និងការអនុវត្តជាក់ស្តែងផងដើម្បីអាចឱ្យសិស្សមានចំណេះដឹងទូលំទូលាយ និងរឹងមាំ ។

សាលារៀនជំនាន់ថ្មីត្រូវការឱ្យមានការវិនិយោគច្រើន ដែលបច្ចុប្បន្នកម្ពុជាចំណាយថវិកាអស់១០លានដុល្លារហើយក្នុងរយៈពេល៧ឆ្នាំ លើតម្រូវការដ៏ច្រើនរបស់ថ្នាក់ជំនាន់ថ្មីពិសេសលើឧបករណ៍សិក្សាទំនើបៗ។ គំរូកម្មវិធីសាលារៀនជំនាន់ថ្មីបានបង្កើតបាននូវលក្ខខណ្ឌដើម្បីទទួលបានជោគជ័យសំដៅជានាការវិនិយោគលើវិស័យអប់រំប្រកបដោយប្រសិទ្ធភាពក្នុងសាលារៀនជាច្រើន។ ការដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃទទួលស្គាល់សាលារៀនជំនាន់ថ្មីដែលធានាស្តង់ដាខ្ពស់នៃអភិបាលកិច្ចល្អរួមមាន តម្លាភាព គណនេយ្យភាព និងការចូលរួមបង្កើតបានជាកម្លាំងទាក់ទាញការវិនិយោគថ្មីៗក្នុងវិស័យអប់រំដែលការគ្រប់គ្រងអប់រំបែបនេះពុំធ្លាប់មានទេក្នុងវិស័យអប់រំសាធារណៈ។ កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបង្កើតសាលារៀនជំនាន់ថ្មីនឹងទាក់ទាញការវិនិយោគ ក្នុងកម្រិតខ្ពស់ជាងមុនហើយការវិនិយោគទាំងនោះភាគច្រើននឹងទទួលបានពីវិស័យឯកជន។

សាលាជំនាន់ថ្មី គឺជាកម្មវិធីកំណែទម្រង់ប្រព័ន្ធអប់រំរបស់រដរដ្ឋាភិបាលកម្ពុជាដែលជាមាគ៌ាអភិវឌ្ឍថ្មីមួយនៅក្នុងប្រព័ន្ធអប់រំនាពេលបច្ចុប្បន្នដែលជួយបង្កើតសាលារៀនសាធារណៈស្វយ័ត។ គម្រោងនេះមានបំណងជួយសកម្មភាពកុមារមេត្រីក្នុងការដោះស្រាយបញ្ហាពុំរ៉ែក្នុងប្រព័ន្ធសាលារៀនរដ្ឋ ដែលធ្វើឱ្យគុណភាពអប់រំចុះខ្សោយ ធ្វើឱ្យសាលាមានអភិបាលកិច្ចល្អ មាតាបិតាសិស្សមានទំនុកចិត្តថាកូនៗរបស់ពួកគាត់ទទួលបានការអប់រំដែលប្រកបដោយគុណភាព និងអាចសមត្ថភាពបំពេញតម្រូវការទីផ្សារការងារនោះនឹងធ្វើឱ្យសហគមន៍រីកចម្រើន ក៏ដូចសង្គមជាតិទាំងមូលមានការអភិវឌ្ឍជឿនលឿនទៅមុខ។

**សេចក្តីសន្និដ្ឋាន**

ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍន៍សហគមន៍ គឺជាដំណើរការរួមនៃមូលដ្ឋានមនុស្សដែលចូលរួមក្នុងការសម្រេចចិត្តដោយចាប់ផ្តើមពីការកំណត់បញ្ហាក្នុងតំបន់ការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ។ នៅក្នុងបរិបទនៃការអប់រំ ការចូលរួមរបស់សហគមន៍គឺជាការចូលរួមរបស់សមាជិកសហគមន៍ និងឪពុកម្តាយដែលគាំទ្រកុមាររៀននៅសាលានិងក្នុងសហគមន៍។ សមាជិកសហគមន៍ និងឪពុកម្តាយអាចចូលរួមក្នុងការអប់រំក្នុងទម្រង់ជាច្រើនដែលបែងចែកជាប្រាំមួយប្រភេទសំខាន់ៗ (Epstein, 2006) ហើយកម្រិត និងឥទ្ធិពលនៃអ្នកចូលរួមប្រែប្រួលអាស្រ័យលើរបៀបដែលពួកគេ។ ការចូលរួមៈ ការចូលរួមក្លែងបន្លំ ឬការចូលរួមពិតប្រាកដ (Bray, 2001)។

ការសិក្សាមួយចំនួនបានបញ្ជាក់ថាការចូលរួមរបស់សហគមន៍ក្នុងការអប់រំផ្តល់ អត្ថប្រយោជន៍យ៉ាងច្រើនចំពោះការសិក្សារបស់កុមារ។ មានការសិក្សាជាច្រើនដែលបានធ្វើឡើងនៅក្នុងប្រធានបទនេះក្នុងបរិបទផ្សេងៗគ្នា។ នៅក្នុងបរិបទកម្ពុជាការសិក្សាជាច្រើនត្រូវបានធ្វើឡើងនៅក្នុងការអប់រំក្នុងរយៈពេលដប់ឆ្នាំចុងក្រោយដូចជា Bray (2001), Pellini (2007), Clayton (2005), Dy (2004) និង Collins (2009) ។ ទោះយ៉ាងណាក៏ដោយ មានការសិក្សាមួយចំនួនដែលធ្វើឡើងនៅក្នុងសហគមន៍ស្តីពីការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្ពុជា (ង៉ួន, 2012; Save the Children, 2015; Pak, 2012)។ ទោះបីជាការសិក្សាទាំងនេះបានរកឃើញទម្រង់ផ្សេងៗនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំក៏ដោយ ក៏ប្រភេទមួយចំនួននៃការចូលរួមដែលគួរតែត្រូវបានស្រាវជ្រាវមិនត្រូវបានរុករក។ ទាំងនេះរួមបញ្ចូលការសួរអ្វីដែលទម្រង់ផ្សេងទៀតនៃការចូលរួមរបស់សហគមន៍ ដែលអាចនឹងកើតឡើងនៅក្នុងសាលាបឋមសិក្សាកម្ពុជា។

ដូច្នេះហើយ ការសិក្សារបស់ខ្ញុំគឺធ្វើឡើងដើម្បីបំពេញបន្ថែមលើទ្រឹស្តីខាងលើក្នុងការរួមចំណែកផ្តល់ជាចំណេះដឹងស្តីពីការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅប្រទេសកម្ពុជា។ ដើម្បីបំពេញចន្លោះនៅក្នុងទ្រឹស្តីការសិក្សារបស់ខ្ញុំមានគោលបំណងស្វែងយល់ពីទម្រង់ និងការលើទឹកចិត្តនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ និងហេតុផលរបស់សហគមន៍ចូលរួមក្នុងការអប់រំ។ ការសិក្សានេះបានរួមបញ្ចូល

គ្មានូវក្របខ័ណ្ឌការចូលរួមរបស់ Epstein និង Bray ក្របខណ្ឌដើម្បីស្វែងយល់ពីការចូលរួមរបស់ក្រុមគ្រួសារ សហគមន៍ និងសាលារៀន។ វិធីសាស្ត្រនៃការប្រមូលទិន្នន័យដើម្បីបង្កើតចំណេះដឹងនេះនឹងត្រូវបានពិពណ៌នានៅក្នុងជំពូកបន្ទាប់។

# ជំពូកទី៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ «**ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង**» ត្រូវបានប្រព្រឹត្តទៅលើសាលាបឋមសិក្សាចំនួន១៣ ស្ថិតនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀងដោយពិភាក្សានូវអ្វីដែលបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ និងសំណួរសម្ភាសន៍របស់ជាតុសំណាករួមមាន៖ នាយក គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលា មាតាបិតាសិស្ស និងព្រះចៅអធិការវត្ត។ កម្មវិធី SPSS & Microsoft Excel ត្រូវបានប្រើសម្រាប់បញ្ចូលទិន្នន័យ វិភាគ និងសង់តារាង ក្រាប បន្ទាប់មកធ្វើការបកស្រាយដោយយកទិន្នន័យចេញពីកម្មវិធីទាំងនេះដើម្បីឈ្វេងយល់ពីទម្រង់ និងកត្តាជំរុញនៃការចូលរួម និងបញ្ហាប្រឈមនានារបស់សហគមន៍ក្នុងវិស័យអប់រំ។

## ៣.១- គម្រោងស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះប្រើប្រាស់ទាំងវិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ៖

**១) វិធីសាស្ត្របរិមាណវិស័យ** (Quantitative Research Design) ប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យពី គ្រូបង្រៀន និងសិស្សានុសិស្ស។ ការរៀបចំកម្រងសំណួរគឺចែកចេញជា៤ផ្នែកគឺ៖ ១)ព័ត៌មានទូទៅ ២)សូចនាករសម្រាប់វាស់វែងទៅលើទម្រង់ និងកត្តាជំរុញនៃការចូលរួម ៣)សូចនាករសម្រាប់វាស់វែងទៅលើបញ្ហាប្រឈមរបស់សហគមន៍ក្នុងការចូលរួមក្នុងការអប់រំ។

**២) វិធីសាស្ត្រគុណវិស័យ** (Qualitative Research Design) ប្រើប្រាស់កម្រងសំណួរសម្រាប់សម្ភាសន៍ ពីអ្នកចូលរួមទិន្នន័យគុណវិស័យរួមមាន៖១)នាយក/នាយិកា ២)គណៈកម្មការគ្រប់គ្រងសាលា និង៣)ព្រះចៅអធិការវត្ត។ ការរៀបចំសំណួរសម្ភាសន៍ គឺផ្សារភ្ជាប់សូចនាករដែលបានប្រើប្រាស់ក្នុងការប្រមូលទិន្នន័យបរិមាណវិស័យផងដែរដើម្បីផ្ទៀងផ្ទាត់រវាងលទ្ធផលដែលទទួលបាន និងទស្សនៈនៃការយល់ឃើញគំនិតសំខាន់ៗដើម្បីលើកយកមកពិភាក្សា។

**តារាង៣.១៖ គម្រោងស្រាវជ្រាវរៀបរាប់ពីវិធីសាស្ត្រតាមបរិមាណវិស័យ និងគុណវិស័យ៖**

| គោលបំណង | ឧបករណ៍ស្រាវជ្រាវ | សំណាកគំរូ | ការវិភាគទិន្នន័យ |
|---|---|---|---|
| **ទម្រង់និងការលើកទឹកចិត្តនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ** | បរិមាណវិស័យ៖ប្រើប្រាស់កម្រងសំណួរ (Questionnaires) | សរុបៈ ១៦១នាក់<br>-ឪពុកម្តាយ និងសមាជិកគ្រួសារ(២៨នាក់)គ្រូបង្រៀន១៣៣នាក់ | -កម្រិតចង្អុលបង្ហាញពីទាបបំផុត (១) ទៅខ្ពស់បំផុត (៥)<br>-ភាគរយ(%) គម្លាតមធ្យម (Mean) គម្លាតស្តង់ដា (Standard Deviation) |
| | គុណវិស័យ៖ប្រើប្រាស់សំណួរក្នុងការសម្ភាស (Interview protocol) | -នាយកសាលា(០៥នាក់)<br>-គណៈកម្មការទ្រទ្រង់សាលា(០២នាក់)<br>- ព្រះចៅអធិការវត្ត(០២នាក់) | -ការបកស្រាយខ្លឹមសារ(Transcript)<br>-ការទាញយកពាក្យគន្លឹះ(Coding) បកស្រាយអត្ថន័យរួម (Themes) |
| **បញ្ហាប្រឈមក្នុងការចូលរួមរបស់សហគមន៍ក្នុងការអប់រំ** | បរិមាណវិស័យ៖ប្រើប្រាស់កម្រងសំណួរ (Questionnaires) | -ឪពុកម្តាយ និងសមាជិកគ្រួសារ(២៨នាក់) គ្រូបង្រៀន១៣៣នាក់ | -កម្រិតចង្អុលបង្ហាញពីទាបបំផុត (១) ទៅខ្ពស់បំផុត (៥)<br>-ភាគរយ(%) គម្លាតមធ្យម (Mean) គម្លាតស្តង់ដា (Standard Deviation) |
| | គុណវិស័យ៖ប្រើប្រាស់សំណួរក្នុងការសម្ភាសន៍(Interview protocol) | សរុបៈ ០៩នាក់<br>-នាយកសាលា(០៥នាក់)<br>-គណៈកម្មការទ្រទ្រង់សាលា(០២នាក់)<br>ព្រះចៅអធិការវត្ត(០២អង្គ) | -ការបកស្រាយខ្លឹមសារ(Transcript)<br>-ការទាញយកពាក្យគន្លឹះ(Coding)<br>-បកស្រាយអត្ថន័យរួម(Themes) |

## ៣.២- ការប្រមូលទិន្នន័យ

មុនពេលផ្តល់កម្រងសំណួរដល់អ្នកចូលរួមផ្តល់ព័ត៌មាន ជាដំបូងអ្នកស្រាវជ្រាវបានទទួលលិខិតលេៈ ៤០៨២ អយក.វជអ ចុះថ្ងៃទី១០ខែកក្កដា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពីការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។ បន្ទាប់មកអ្នកស្រាវជ្រាវបានយកលិខិតនេះទៅប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀងដើម្បីសុំលិខិតអនុញ្ញាតចុះប្រមូលទិន្នន័យស្រាវជ្រាវ ក្រោយពីបានការអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារួចមក អ្នកស្រាវជ្រាវក៏បានយកលិខិនោះទៅប្រគល់ជូនគណៈគ្រប់គ្រងសាលាគោលដៅទាំង១៣សាលា ដើម្បីសុំការអនុញ្ញាតក្នុងការចុះប្រមូលទិន្នន័យដោយប្រើប្រាស់កម្រងសំណួរលើសំណាក(គ្រូបង្រៀននិងមាតាបិតាសិស្ស)ក្នុងការបំពេញទិន្នន័យ និងសម្ភាសន៍លើសំណាក (នាយក និងគណៈគ្រប់គ្រងសាលារៀន ) ក្នុងការផ្តល់ព័ត៌មាន។អ្នកស្រាវជ្រាវក៏បានយកលិខិនោះទៅប្រគល់ជូនព្រះចៅអធិការវត្តដើម្បីសុំការអនុញ្ញាតធ្វើការសម្ភាសន៍ព្រះអង្គ។

## ៣ .៣- ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំជាលក្ខណៈបរិមាណវិស័យ និងគុណវិស័យដែលមានការចូលរួមពីភាគីពាក់ព័ន្ធដូចជា នាយក គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន មាតាបិតាសិស្ស និងព្រះសង្ឃ។ ចំពោះឧបករណ៍ស្រាវជ្រាវអ្នកសិក្សាស្រាវជ្រាវ បានរៀបចំបង្កើតជាកម្រងសំណួរដែលមានលក្ខណៈពហុជ្រើសរើស និងសំណួរទម្រង់បើក។

ផ្នែកបរិមាណវិស័យ អ្នកស្រាវជ្រាវ បានប្រើប្រាស់សំណួរពហុជ្រើសរើសនៅក្នុងទម្រង់កម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតបក្នុងកម្រិតពហុចម្លើយ។ កម្រិតចង្អុលបង្ហាញត្រូវបានបំពេញតាមរយៈសូចនាករកម្រងសំណួរដោយផ្ទាល់ លើប្រធានបទដែលបានសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានចម្លើយពហុជ្រើសរើស (Likert Scale)។

ចម្លើយពហុជ្រើសរើសគឺប្រើដើម្បីវាស់វែងសូចនាករវាយតម្លៃលើទម្រង់នៃការចូលរួម និងកត្តាដែលជំរុញឱ្យសហគមន៍ចូលរួមក្នុងការអប់រំព្រមទាំងឧបសគ្គរបស់សហគមន៍ចូលរួមក្នុងសហគមន៍។

### ៣.៣.១ កម្រងសំណួរ

កម្រងសំណួរត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវដោយសំយោគចូលគ្នារវាងសូចនាករនៃទម្រង់ការចូលរួមរបស់សហគមន៍កាតលើកទឹកចិត្ត និងបញ្ហាប្រឈមក្នុងការចូលរួមក្នុងវិស័យអប់រំ។ កម្រងសំណួរគឺកម្រងសំណួរសម្រាប់ឪពុកម្ដាយចំនួន២៨នាក់ និងគ្រូបង្រៀន១៣៣នាក់ ដើម្បីប្រមូលបានទិន្នន័យនេះ ហើយប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។

**កម្រងសំណួរសម្រាប់ ឪពុកម្ដាយ**

កម្រងសំណួរសម្រាប់សមាជិកគ្រួសារ គឺប្រើសម្រាប់ប្រមូលទិន្នន័យពីឪពុកម្ដាយ និងសមាជិកគ្រួសារចំនួន២៨នាក់ មកពីគ្រួសាររបស់សិស្សនៃសាលាបឋមសិក្សាទាំង១២នៅតាមសហគមន៍នីមួយៗដោយបែងចែកចេញជាបីផ្នែកគឺៈ

**ផ្នែកទី១ៈ** ព័ត៌មានទូទៅមាន៧សំណួរៈ(១)អ្នកចូលរួម (២)ភេទ (៣)អាយុ (៤)កម្រិតវប្បធម៌ (៥)មុខរបរ (៦)អាស័យដ្ឋានបច្ចុប្បន្ន (៧)សមាជិកគ្រួសារដែលកំពុងសិក្សានៅសាលាបឋមសិក្សា

**ផ្នែកទី២ៈ** សំណួរទាក់ទងនឹងទម្រង់នៃការចូលរួមរបស់មាតាបិតាសិស្សក្នុងការអប់រំផ្ដោតលើសូចនាករការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំទាញបានជាសូចនាករគន្លឹះចំនួន២គឺ(១)ទម្រង់ និង(២)ការលើកទឹកចិត្តដោយការសិក្សាស្រាវជ្រាវក្នុងផ្នែកនេះមាន១៥សំណួរ

**ផ្នែកទី៣ៈ**បញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំដោយការសិក្សាស្រាវជ្រាវក្នុងផ្នែកនេះមាន០២សំណួរ។

**កម្រងសំណួរសម្រាប់គ្រូបង្រៀន**

កម្រងសំណួរសម្រាប់គ្រូបង្រៀនគឺប្រើសម្រាប់ប្រមូលទិន្នន័យពីគ្រូបង្រៀនចំនួន១៣៣នាក់ មកពីសាលាបឋមសិក្សាទាំង១៣នៅតាមសហគមន៍នីមួយៗដោយបែងចែកចេញជាបីផ្នែកគឺៈ

**ផ្នែកទី១ៈ** ព័ត៌មានទូទៅមាន៧សំណួរៈ (១)អ្នកចូលរួម(២)ភេទ(៣)អាយុ(៤)កម្រិតវប្បធម៌(៥)បទពិសោធការងារ(៦)អាស័យដ្ឋានបច្ចុប្បន្ន(៧)កំពុងបង្រៀននៅសាលាបឋមសិក្សា

**ផ្នែកទី២ៈ**សំណួរទាក់ទងនឹងៈទម្រង់នៃការចូលរួមរបស់គ្រូបង្រៀនក្នុងការអប់រំផ្តោតលើសូចនាករការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំទាញបានជាសូចនាករគន្លឹះចំនួន២គឺ(១)ទម្រង់និង(២)ការលើកទឹកចិត្ត ដោយការសិក្សាស្រាវជ្រាវក្នុងផ្នែកនេះមាន១៤សំណួរ

**ផ្នែកទី៣ៈ**បញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំដោយការសិក្សាស្រាវជ្រាវក្នុងផ្នែកនេះមាន០២សំណួរ។

### ៣.៣.២ ការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ

ដើម្បីឱ្យលទ្ធផលនៃការស្រាវជ្រាវ កាន់តែមានសង្គតិភាព និងឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សាទិន្នន័យគុណវិស័យត្រូវបានរៀបចំប្រមូលបន្ថែម ដើម្បីផ្ទៀងផ្ទាត់ទៅលើលទ្ធផលនៃមធ្យមភាពិន្ទុដែលទទួលបានពីទិន្នន័យបរិមាណវិស័យ និងបានឆ្លងកាត់ការត្រួតពិនិត្យ និងវាយតម្លៃពីគ្រូដឹកនាំ។ អ្នកស្រាវជ្រាវបានរៀបចំការសម្ភាសន៍ (semi-structured interview) ជាមួយអ្នកចូលរួម។ សំណួរសម្ភាសន៍មានទម្រង់ជាសំណួរបើក ដើម្បីសួរទៅភាគីអ្នកចូលរួមសម្ភាសន៍ ផ្តល់ទិន្នន័យ តាមរយៈបទពិសោធន៍បើកកិច្ចពិភាក្សា និងវិភាគស៊ីជម្រៅទៅលើបញ្ហាដែលបានកើតមានឡើងលើប្រធានបទដែលយកមកសិក្សា។ ការសម្ភាសន៍នេះគឺប្រើប្រាស់ភាសាខ្មែរ ជាមួយគ្នានេះដែរអ្នកស្រាវជ្រាវបានប្រើប្រាស់ការសង្កេត (Observation protocol) ក្នុងពេលធ្វើការសម្ភាសផងដែរដោយចុះទៅផ្ទាល់តាមសាលាគោលដៅដើម្បីដកស្រង់យកនូវព័ត៌មានសំខាន់តាមគោលបំណងរបស់ប្រធានបទ។

## ៣.៤- ការជ្រើសរើសសំណាក

ភាគសំណាកសម្រាប់ការស្រាវជ្រាវនេះរួមមាន នាយក/នាយិកាចំនួន០៥នាក់ គ្រូបង្រៀនចំនួន ១៣៣នាក់ គណៈកម្មការគ្រប់គ្រងសាលាចំនួន០២នាក់ មាតាបិតាសិស្សចំនួន២៨នាក់ និងព្រះចៅអធិការវត្តចំនួន ០២អង្គ ដែលបានជ្រើសរើសចេញពីសាលាបឋមសិក្សា និងសហគមន៍ចំនួន១៣ ក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង។ មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវរើសយកភាគសំណាកទាំង១៣ សាលា គឺដើម្បីយកមកធ្វើការសិក្សាឈ្វេងយល់ពីទម្រង់ការលើកទឹកចិត្តក្នុងការចូលរួម និងបញ្ហាប្រឈមនានារបស់សហគមន៍ក្នុងការចូលរួមនៅតាមសាលារៀនបឋមសិក្សាក្នុងក្រុងស្វាយរៀង។

### ៣.៤.១ ការជ្រើសរើសភាគសំណាកបរិមាណវិស័យ

នៅក្នុងសាលាបឋមសិក្សាទាំង១៣ ដែលបានជ្រើសរើសនេះសម្រាប់រើសយកសំណាកស្រាវជ្រាវតាមរបៀបកំណត់សំណាកស្រាវជ្រាវរបស់លោក Krecie & Morgan (1970)។ តាមរយៈវិធីនេះអ្នកស្រាវជ្រាវកំណត់យក មាតាបិតាសិស្ស និងគ្រូបង្រៀនតាមសាលានីមួយៗទាំងអស់ធ្វើជាសំណាកសាកល ហើយកំណត់យកសំណាកស្រាវជ្រាវស្មើនឹងសំណាកសាកលនោះកម្រិតជឿជាក់៩៩% និងកម្រិតលម្អៀង ១% ។

រូបមន្តគណនាភាគសំណាក

តាមរូបមន្ត Krejcie and Morgan, 1970

$$n = \frac{x^2Np(1-p)}{e^2(N-1)+x^2p(1-p)}$$

n= ទំហំសំណាក (sample size)

N= សំណាកសរុប (population size)

e= សំណាក (acceptable sampling error) គឺ 0.05

$x^2$= 3.841 (ភាពជឿជាក់ 95%)

p= 0.5 (proportion of population)

ដោយកំណត់យកភាពជឿជាក់ ៩៥%គ្រូបង្រៀនបឋមសិក្សាក្នុង ក្រុងស្វាយរៀងសរុបមានចំនួន ២៤១នាក់ និង មាតាបិតាសិស្សចំនួន ៤០នាក់

តាមរូបមន្តយើងបាន $n = \frac{3.841*281*0.5(1-0.5)}{(0.05)^2(281-1)+3.841*0.5(1-0.5)}$= 161នាក់

**តារាង ៣.៤ ការជ្រើសរើសសំណាកតាមបរិមាណវិស័យ**

| ល.រ | ក្រុមគោលដៅ | ចំនួនអ្នកចូលរួម |
|---|---|---|
| ១ | ឪពុកម្តាយ | ២៨ |
| ២ | គ្រូបង្រៀន | ១៣៣ |
| | សរុបរួម | ១៦១ |

ប្រភព៖ ( Krecie & Morgan,1970 )

### ៣.៤.២ ការជ្រើសរើសសំណាកតាមគុណវិស័យ

ការជ្រើសរើសសំណាកតាមគុណវិស័យ ត្រូវបានជ្រើរើសចេញពីអង្គភាពផ្សេងគ្នាដូចខាងក្រោម៖

**តារាង៣.៤.២ អ្នកចូលរួមសម្ភាសន៍**

| អ្នកចូលរួម | នាយកសាលា | គណៈកម្មការSSC | ព្រះចៅអធិការវត្ត |
|---|---|---|---|
| ប.ព្រះសីហនុ | ១ | 0 | 0 |
| ប.២ធ្នូ | ១ | 0 | ១ |
| ប.កន្ទុយរ៉ែ | ១ | 0 | 0 |
| ប.ចេក | 0 | 0 | 0 |
| ប.ចុងព្រែក | 0 | 0 | 0 |
| ប.៧មករា | 0 | 0 | 0 |
| ប.គយត្របែក | 0 | 0 | ១ |
| ប.ជម្លូព្រឹក្សា | ១ | ១ | 0 |
| ប.ស្វាយតឿ | 0 | 0 | 0 |
| ប.ព្រះទន្លេ | 0 | 0 | 0 |

| | | | |
|---|---|---|---|
| ប.អកនាគ | ១ | ១ | ០ |
| ប.ក្រសាំងជ្រុំ | ០ | ០ | ០ |
| ប.សាមគ្គី | ០ | ០ | ០ |
| សរុប | ០៥ | ០២ | ០២ |

## ៣.៥- ការវិភាគទិន្នន័យ

ចំនួនសំណាក៥ប្រភេទដែលត្រូវបានចុះប្រមូលទិន្នន័យគឺ៖ ១)នាយក/នាយិកា ដែលទទួលបានតាមរយៈកម្រងសំណួរសម្ភាសន៍ ២)គណៈកម្មការគ្រប់គ្រងសាលាទទួលបានតាមរយៈកម្រងសំណួរសម្ភាសន៍ ៣)ព្រះចៅអធិការវត្តទទួលបានតាមរយៈកម្រងសំណួរសម្ភាសន៍ និង ៤)គ្រូបង្រៀនទទួលបានតាមរយៈកម្រងសំណួរពហុជ្រើសរើស និង ៥)មាតាបិតាសិស្សទទួលបានតាមរយៈកម្រងសំណួរពហុជ្រើសរើស។

### ៣.៥.១ ការវិភាគទិន្នន័យតាមបរិមាណវិស័យ

កម្រងសំណួរដែលប្រមូលបានពីក្រុមគោលដៅ ក្នុងការផ្តល់ទិន្នន័យត្រូវបានយកមករៀបចំដើម្បីជាមូលដ្ឋានក្នុងការវិភាគទិន្នន័យបរិមាណវិស័យ។ ការវិភាគទិន្នន័យនេះផ្តោតសំខាន់ទៅលើ៖ ១)ភាគរយ (%) ២)មធ្យមភាគពិន្ទុ (Mean) និង ៣)គម្លាតស្តង់ដា (Standard Deviation) ។ សំណួរស្រាវជ្រាវទី១ គឺវិភាគទៅលើកម្រងសំណួរដែលផ្តោតសំខាន់ទៅលើសូចនាករគន្លឹះទម្រង់ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ និងសំណួរស្រាវជ្រាវទី២ គឺធ្វើការវិភាគដើម្បីធ្វើការឆ្លុះបញ្ចាំងលើបញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរដែលមានលក្ខណៈជាពហុជ្រើសរើសទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗក្នុងទម្រង់បិទ និងការផ្តល់មតិយោបល់សម្រាប់ស្វែងរកទិន្នន័យជាធាតុចូលបន្ថែម។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ Microsoft Excel ដើម្បីសិក្សាសង់ក្រាបអំពីសកម្មភាពនៃការចូលរួមរបស់សហគមន៍ និងបញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង។

### ៣.៥.២ ការវិភាគទិន្នន័យតាមគុណវិស័យ

ក្រោយពីបានប្រមូលទិន្នន័យតាមរយៈសម្ភាសន៍រួចមក ទិន្នន័យគុណវិស័យត្រូវបានយកមករៀបចំវិភាគទៅតាមនីតិវិធីច្បាស់លាស់ដោយការចាប់បណ្តុំ នៃពាក្យលើអថេរគោលតាមប្រភេទនៃសំណួរនីមួយៗ និងឆ្លើយតបទៅនឹងគោលគំនិតចម្បងៗពីអ្នកផ្តល់ទិន្នន័យ។ អ្នកស្រាវជ្រាវបានកត់ត្រាទស្សនៈ និងបទពិសោធដែលអ្នកចូលរួមសម្ភាសន៍បានផ្តល់ឱ្យ ហើយទិន្នន័យដែលបានមកនោះដែរ អ្នកស្រាវជ្រាវមានការគិតដោយប្រុងប្រយ័ត្នដើម្បីវិភាគក្នុងការកំណត់គោលគំនិតសំខាន់ (Themes)។ អ្នកស្រាវជ្រាវបានកត់ត្រាទិន្នន័យពីការធ្វើសម្ភាសន៍ទៅតាមផ្នែកនៃសំណួរស្រាវជ្រាវ។ ការរៀបចំត្រូវបានអនុវត្តទៅតាមជំហានដូចជា៖ ១)រៀបចំទៅលើទិន្នន័យប្រមូលបានតាមរយៈការថតចម្លងបទសម្ភាសន៍ ការបកប្រែទិន្នន័យ ការកត់ត្រាព័ត៌មានលម្អិត និងការកំណត់ខ្លឹមសារ (Transcript) ២)កំណត់ក្របខណ្ឌនៃការវិភាគទិន្នន័យដោយធ្វើការដាក់កូដទិន្នន័យក្នុងគម្រោងវិភាគ ដាក់សញ្ញា និងកំណត់ទិន្នន័យ (Coding arid Consolidation) ៣)សំយោគក្របខណ្ឌនៃគោលគំនិតរួម (Themes) តាមរយៈការវិភាគពិពណ៌នាដោយផ្អែកលើក្របខណ្ឌ (Content analysis) ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវសកម្មភាពនៃការចូលរួមរបស់សហគមន៍និងបញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង។

### ៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវបានប្រកាន់ខ្ជាប់នូវគោលការណ៍ និងក្រមសីលធម៌វិជ្ជាជីវៈក្នុងការចុះប្រមូលទិន្នន័យ នៅតាមក្រុមគោលដៅដែលបានកំណត់នៅក្នុងការស្រាវជ្រាវប្រធានបទ។ ការចុះប្រមូលទិន្នន័យសម្រាប់ការសិក្សាទទួលបានលិខិតឧទ្ទេសនាម សម្រាប់បំពេញបេសកកម្មត្រូវបានអនុញ្ញាតដោយវិទ្យាស្ថានជាតិអប់រំ។ លិខិតនេះត្រូវបានប្រគល់ជូនទៅតាមអង្គភាពពាក់ព័ន្ធមុននឹងចាប់ផ្តើមធ្វើការប្រមូលទិន្នន័យ។ ការចុះប្រមូលទិន្នន័យ គឺអ្នកសិក្សាស្រាវជ្រាវបានប្រាប់ពីគោលបំណងច្បាស់លាស់ និងរក្សាការសម្ងាត់នៃការផ្តល់ទិន្នន័យលើកម្រងសំណួរក៏ដូចជាសំណួរសម្ភាសន៍។ ទិន្នន័យដែលផ្តល់តាមបរិមាណវិ

ស័យ និងគុណវិស័យនេះ គឺសម្រាប់ប្រើប្រាស់ក្នុងគោលបំណងនៃការសិក្សាស្រាវជ្រាវលើ ប្រធានបទនេះ តែប៉ុណ្ណោះ។ ការផ្តល់ទិន្នន័យពីក្រុមគោលដៅគឺក្នុងលក្ខខណ្ឌឯកភាពជាបុគ្គល និងពេញចិត្តមានការចូលរួមទាំងអស់គ្នាក្នុងការសហការគ្នា មិនមានការបង្ខិតបង្ខំ និងផ្តល់ព័ត៌មានដោយឈរលើភាពពិតប្រាកដ និងបទពិសោធន៍ជាក់ស្តែង ទៅលើការងារអប់រំ។

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

ជំពូកនេះបង្ហាញពីការរកឃើញនៃការប្រមូលទិន្នន័យ ដើម្បីស្វែងរកចំលើយនៃសំណួរស្រាវជ្រាវក្នុងការសិក្សានេះ ដែលទាក់ទងនឹងទម្រង់នៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំដែលកំពុងកើតឡើងនៅក្នុងសាលាបឋមសិក្សាក្នុងខេត្តស្វាយរៀង។ ទិន្នន័យដែលទទួលបានពីបរិមាណវិស័យ និងគុណវិស័យនឹងត្រូវធ្វើការបកស្រាយ និងការពិភាក្សាដោយផ្តោតទៅលើទស្សនៈនិងបទពិសោធន៍អនុវត្តគោលនយោបាយអប់រំនេះ ដែលបានមកពីនាយកសាលា គ្រូបង្រៀន មាតាបិតាសិស្ស គណៈកម្មការទ្រទ្រង់សាលា អាជ្ញាធរ និងព្រះសង្ឃ។ ប្រធានបទសិក្សាសក្រាវជ្រាវនេះពី «ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង» ត្រូវបានលើកយកមកវិភាគ និងសំយោគស្របតាមគោលបំណងនៃការសិក្សាស្រាវជ្រាវលើពីរចំនុចគឺ៖ ១)សិក្សាស្វែងយល់ពីទម្រង់នៃការចូលរួមរបស់សហគមន៍ និង ២)សិក្សាស្វែងយល់ពីបញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សា ក្នុងខេត្តស្វាយរៀង។

អ្នកស្រាវជ្រាវនឹងធ្វើការវិភាគទៅលើលទ្ធផលស្រាវជ្រាវ ដែលបានមកទៅតាមផ្នែកនីមួយៗនៃទម្រង់ស្រាវជ្រាវបែបបរិមាណវិស័យ និងគុណវិស័យ។ សម្រាប់លទ្ធផលស្រាវជ្រាវបែបបរិមាណវិស័យ អ្នកស្រាវជ្រាវនឹងប្រើប្រាស់កម្មវិធីកុំព្យូទ័រ (SPSS) ដើម្បីវិភាគលើលទ្ធផលដែលទទួលបានតាមរយៈកម្រងសំណួរដែលប្រមូលបានពីលោកគ្រូ-អ្នកគ្រូដែលបង្រៀននៅតាមសាលាបឋមសិក្សា និងមាតាបិតាសិស្ស និងសមាជិកគ្រួសារសិស្ស។ រីឯលទ្ធផលស្រាវជ្រាវបែបគុណវិស័យ ដែលទទួលបានតាមរយៈការសម្ភាសន៍ចេញពីអ្នកចូលរួម (រួមមាននាយកសាលា គណៈកម្មការទ្រទ្រង់សាលា អាជ្ញាធរ និង ព្រះសង្ឃ) អ្នកស្រាវជ្រាវបានធ្វើចំណាត់ថ្នាក់ (Classify) នៃប្រភេទចម្លើយហើយធ្វើការតំរៀប (Coding) លើមតិយោបល់ដែលដូចគ្នា ឬស្រដៀងគ្នាដើម្បីទាញសេចក្តីសន្និដ្ឋានរួមមួយ។ លទ្ធផលដែលទទួលបានពីការសម្ភាសន៍នឹងទៅបំពេញបន្ថែមលើអ្វីដែលបានរកឃើញតាមរយៈកម្រងសំណួរ ឱ្យកាន់តែមានភាពច្បាស់

លាស់ជាពិសេសបានឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាំងពីរផ្នែកខាងលើឱ្យកាន់តែស៊ីជម្រៅ និងមានភាពជឿជាក់ខ្ពស់។

## ៤.១ ទិន្នន័យព័ត៌មានទូទៅ

### ៤.១.១ ព័ត៌មានទូទៅរបស់គ្រូ

### តារាង៤.១.១ព័ត៌មានទូទៅរបស់គ្រូបង្រៀន

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | ៦៦ | ៤៩.៦% |
| | | ស្រី | ៦៧ | ៥០.៤% |
| | | សរុប | ១៣៣ | ១០០% |
| ២ | អាយុ | ២០ទៅ៣០ឆ្នាំ | ៩ | ៦.៧% |
| | | ៣១ទៅ៤០ឆ្នាំ | ៣០ | ២២.៦% |
| | | ៤១ឆ្នាំឡើង | ៩៤ | ៧០.៧% |
| | | សរុប | ១៣៣ | ១០០% |
| ៣ | កម្រិតវប្បធម៌ | បឋមសិក្សា | ៤ | ៣% |
| | | ទុតិយភូមិ | ១០១ | ៧៥.៩% |
| | | បរិញ្ញាបត្រ | ២៧ | ២០.៣% |
| | | ខ្ពស់ជាងបរិញ្ញាបត្រ | ១ | ០.៨% |
| | | សរុប | ១៣៣ | ១០០% |
| ៤ | បទពិសោធការងារ | តិចជាង២ឆ្នាំ | ០ | ០% |
| | | ២ដល់៥ឆ្នាំ | ២ | ១.៥% |
| | | ៥ដល់១០ឆ្នាំ | ១១ | ៨.៣% |
| | | ១១ដល់១៥ឆ្នាំ | ១៥ | ១១.៣% |
| | | លើសពី១៥ឆ្នាំ | ១០៥ | ៧៨.៩% |
| | | សរុប | ១៣៣ | ១០០% |
| ៥ | អាស័យដ្ឋានបច្ចុប្បន្ន | ស្វាយរៀង | ៣៥ | ២៦.៣% |
| | | ព្រៃឆ្លាក់ | ២១ | ១៥.៨% |
| | | ពោធិតាហោ | ១២ | ៩% |
| | | គយត្របែក | ៣ | ២.៣% |

| | | | | |
|---|---|---|---|---|
| | | បេក | ២៧ | ២០.៣% |
| | | ស្វាយតឿ | ១១ | ៨.៣% |
| | | សង្ស៊ែរ | ១៨ | ១៣.៥% |
| | | ផ្សេងៗ | ៦ | ៤.៥% |
| | | សរុប | ១៣៣ | ១00% |
| ៦ | កំពុងបង្រៀននៅបឋមសិក្សា | ព្រះសីហនុ | ២៥ | ១៨.៨% |
| | | ២ធ្នូ | ១៥ | ១១.៣% |
| | | បេក | ១០ | ៧.៥% |
| | | កន្ទុយរ៉ៃ | ១៧ | ១២.៨% |
| | | គយត្របែក | ៦ | ៤.៥% |
| | | ៧មករា | ៩ | ៦.៨% |
| | | ជម្ពូព្រឹក្សា | ១០ | ៧.៥% |
| | | ស្វាយតឿ | ៦ | ៤.៥% |
| | | សាមគ្គី | ៨ | ៦.៥% |
| | | ព្រះទន្លេ | ៦ | ៤.៥% |
| | | ក្រសាំងជ្រុំ | ៦ | ៤.៥% |
| | | ពន្លាអកនាគ | ៨ | ៦% |
| | | ចុងព្រែក | ៧ | ៥.៣% |
| | | សរុប | ១៣៣ | ១00% |

តាមទិន្នន័យបានទទួលពីគ្រូបង្រៀននៅបឋមសិក្សាដែលបង្ហាញថាលោកគ្រូមាន៤៩.៦% និងអ្នកគ្រូមាន៥០.៤%។ គ្រូបង្រៀន៧០.៧%មានអាយុលើសពី៤១ឆ្នាំ ២២.៦%មានចន្លោះអាយុពី៣១ឆ្នាំដល់ ៤០ឆ្នាំ និងមានអាយុចន្លោះពី២០ឆ្នាំ ដល់៣០ឆ្នាំ ៦.៨%។ គ្រូបង្រៀនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រមានចំនួន២០.៣%និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន០.៨% បញ្ចប់ថ្នាក់ទី១២ចំនួន ៧៥.៩% និងបញ្ចប់ត្រឹមថ្នាក់បឋមសិក្សាមានចំនួន ៣%។ផ្អែកលើទិន្នន័យខាងលើអាចបញ្ជាក់បានថាបុគ្គលិកអប់រំទូទាំងក្រុងស្វាយរៀងត្រូវបានលើកទឹកចិត្តឱ្យទទួលបានការបណ្តុះបណ្តាលឬបន្តការសិក្សា លើកម្រិតជំនាញឯកទេស ឬជំនាញវិជ្ជាជីវៈថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក៏ដូចជាបរិញ្ញាបត្រដើម្បីលើកកម្ពស់សមត្ថភាព បំណិនឥរិយាបថរបស់បុគ្គលិកឱ្យមានភាពសមស្របទៅតាមបរិបទនៃការអប់រំសតវត្សទី២១នេះ។ គ្រូបង្រៀន

មានបទពិសោធលើសពី១៥ឆ្នាំមាន៧៨.៩% ចន្លោះពី១១ឆ្នាំ ដល់១៥ឆ្នាំ មាន១១.៣% ចន្លោះពី៥ឆ្នាំ ដល់១០ឆ្នាំមាន៨.៣% និងចន្លោះពី២ឆ្នាំ ដល់៥ឆ្នាំមាន១.៥%។ គ្រូដែលមានបទពិសោធច្រើនព្រមទាំងអាចចែករំលែកបទពិសោធទៅកាន់សាលាផ្សេង និងចូលរួមសកម្មភាពនានានៅក្នុងសហគមន៍ឬសង្គម ថែមកៀគរសហគមន៍ចូលរួមអភិវឌ្ឍន៍សាលាកឱ្យកាន់តែប្រសើរ។ ដូចនេះយើងអាចវាយតម្លៃបានថាបទពិសោធរបស់បុគ្គលិកអប់រំផ្ទុះបញ្ចាំងជាមួយការងារ និងទំនាក់ទំនងជាមួយសហគមន៍។ គ្រូបង្រៀនដែលមានអាស័យដ្ឋានបច្ចុប្បន្ននៅស្វាយរៀងមាន២៦.៣% ព្រៃឆ្លាក់មាន១៥.៨% ពោធិតាហោ៩% គយត្របែក២.៣% ចេក២០.៣% ស្វាយតឿ៨.៣% សង្ឃ័រ១៣.៥% និងមានអាស័យដ្ឋានមកពីកន្លែងផ្សេងៗមាន៤.៥%។ គ្រូបង្រៀនដែលកំពុងបម្រើការនៅសាលាបឋមសិក្សាព្រះសីហនុមាន១៨.៨% សាលាបឋមសិក្សា២ធ្នូមាន១១.៣% សាលាបឋមសិក្សាចេកមាន៧.៥% សាលាបឋមសិក្សាកន្ទុយរ៉ៃមាន ១២.៨% សាលាបឋមសិក្សាគយត្របែកមាន៤.៥% សាលាបឋមសិក្សា៧មករាមាន៦.៨% សាលាបឋមសិក្សាជម្ពូព្រឹក្សាមាន៧.៥% សាលាបឋមសិក្សាស្វាយតឿមាន៤.៥% សាលាបឋមសិក្សាសាមគ្គីមាន៦% សាលាបឋមសិក្សាព្រះទន្លេមាន៤.៥% សាលាបឋមសិក្សាក្រសាំងជ្រំមាន៤.៥% សាលាបឋមសិក្សាពន្លាអកនាគមាន៦% និងសាលាបឋមសិក្សាចុងព្រៃកមាន៥.៣%។ ផ្អែកលើទិន្នន័យខាងលើអាចបញ្ជាក់បានថាសាលារៀនទូទាំងក្រុងស្វាយរៀងត្រូវបានផ្សារភ្ជាប់ជាមួយសហគមន៍ដោយមានទំនាក់ទំនងល្អជាមួយគ្នា និងកៀគរប្រេកព និងធនធានសហគមន៍ឱ្យចូលរួមទ្រទ្រង់សាលាទាំងមូល។ទឡ្ហីករណ៍ខាងលើក៏ជាប់ពាក់ព័ន្ធជាមួយកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការពង្រឹងគុណវុឌ្ឍគ្រូឱ្យស្របនឹងស្តង់ដាគ្រូបង្រៀននៅក្នុងបណ្តាប្រទេសនានាក្នុងតបន់។ ជាងនេះទៅទៀតដើម្បីឱ្យបុគ្គលិកអប់រំទាំងអស់មានសមត្ថភាពក្នុងការដឹកនាំគ្រប់គ្រងនិងមានទំនាក់ទំនងល្អជាមួយសហគមន៍ក្នុងការអភិវឌ្ឍការអប់រំប្រកបដោយនិរន្តភាព។

### ៤.១.២ ព័ត៌មានទូទៅរបស់មាតាបិតាសិស្ស

**តារាង៤.១.២ ព័ត៌មានទូទៅរបស់មាតាបិតាសិស្ស**

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | ១១ | ៣៩.៣% |
| | | ស្រី | ១៧ | ៦០.៧% |
| | | សរុប | ២៨ | ១០០% |
| ២ | អាយុ | ២០ឆ្នាំ ទៅ ៣០ឆ្នាំ | ២ | ៧.២% |
| | | ៣១ ទៅ ៤០ឆ្នាំ | ១៧ | ៦០.៧% |
| | | ៤១ឆ្នាំឡើង | ៩ | ៣២.១% |
| | | សរុប | ២៨ | ១០០% |
| ៣ | កម្រិតវប្បធម៌ | បឋមសិក្សា | ៩ | ៣២.១% |
| | | ទុតិយភូមិ | ១៧ | ៦០.៧% |
| | | បរិញ្ញាបត្រ | ២ | ៧.២% |
| | | ខ្ពស់ជាងបរិញ្ញាបត្រ | ០ | ០.០% |
| | | សរុប | ២៨ | ១០០% |
| ៤ | មុខរបរ | កសិករ | ៦ | ២១.៤% |
| | | អ្នកលក់ដូរ | ៨ | ២៨.៦% |
| | | គ្រូបង្រៀន | ២ | ៧.១% |
| | | កម្មករ | ៥ | ១៧.៩% |
| | | ផ្សេងៗ | ៧ | ២៥% |
| | | សរុប | ២៨ | ១០០% |
| ៥ | អាស័យដ្ឋានបច្ចុប្បន្ន | ស្វាយរៀង | ១៤ | ៥០% |
| | | ព្រៃឆ្លាក់ | ២ | ៧.១% |
| | | ពោធិតាហោ | ១ | ៣.៦% |
| | | គយត្របែក | ៣ | ១០.៧% |
| | | ចេក | ៤ | ១៤.៤% |
| | | ស្វាយតឿ | ២ | ៧.១% |
| | | សង្ឃ័រ | ២ | ៧.១% |
| | | សរុប | ២៨ | ១០០% |
| ៧ | កូនកំពុងសិក្សានៅ | ព្រះសីហនុ | ៧ | ២៥% |
| | | ២ធ្នូ | ៦ | ២១.៤% |
| | | ចេក | ១ | ៣.៦% |
| | | គយត្របែក | ៣ | ១០.៧% |

| | | | | |
|---|---|---|---|---|
| | | ជម្ពូព្រឹក្សា | ៣ | ១០.៧% |
| | | សាមគ្គី | ១ | ៣.៦% |
| | | ក្រសាំងជ្រំ | ២ | ៧.១% |
| | | ចុងព្រែក | ៥ | ១៧.៩% |
| | | សរុប | ២៨ | ១00% |

តាមទិន្នន័យបានទទួលពីមាតាបិតាសិស្សរបស់សិស្សនៅបឋមសិក្សាដែលបង្ហាញថាឪពុកមាន ១១នាក់ ស្មើនឹង៣៩.៣% និងម្តាយមាន១៧នាក់ ស្មើនឹង៦០.៧%។ ឪពុកម្តាយមាន០៩នាក់ ស្មើនឹង ៣២.១% ដែលមានអាយុលើសពី៤១ឆ្នាំ ចន្លោះអាយុពី៣១ឆ្នាំដល់៤០ឆ្នាំមាន១៧នាក់ ស្មើនឹង៦០.៧% និងមានអាយុចន្លោះពី២០ឆ្នាំដល់៣០ឆ្នាំមាន០២នាក់ ស្មើនឹង៧.២%។ ឪពុកម្តាយបានបញ្ចប់ថ្នាក់បរិញ្ញាបត្រមានចំនួន០២នាក់ ស្មើនឹង៧.២% បញ្ចប់ថ្នាក់ទី១២ចំនួន១៧នាក់ ស្មើនឹង៦០.៧% និងបញ្ចប់ត្រឹមថ្នាក់បឋមសិក្សាមានចំនួន០៩នាក់ ស្មើនឹង៣២.១%។ ឪពុកម្តាយដែលមាន មុខរបរជាកសិករចំនួន០៦នាក់ ស្មើនឹង២១.៤% ជាអ្នកលក់ដូរមាន០៨នាក់ ស្មើនឹង២៨.៦% ជាគ្រូបង្រៀនមាន០២នាក់ ស្មើនឹង៧.១% ជាកម្មករមាន០៥នាក់ ស្មើនឹង១៧.៩% និងមានមុខរបរផ្សេងៗមាន០៧នាក់ ស្មើនឹង ២៥%។ ឪពុកម្តាយដែលមានអាស័យដ្ឋានបច្ចុប្បន្ននៅសង្កាត់ចេកមាន០៤នាក់ ស្មើនឹង១៤.៣% ព្រៃធ្លាក់ ស្វាយតឿ និង សង្ឃ័រមាន០២នាក់ដូចគ្នា ស្មើនឹង៧.១% ពោធិតាហោមាន០១នាក់ ស្មើនឹង៣.៦% គយត្របែកមាន១០.៧% និងស្វាយរៀងមាន១៤នាក់ ស្មើនឹង៥០%។ កូនៗដែលកំពុងសិក្សានៅសាលាបឋមសិក្សាព្រះសីហនុមាន០៧នាក់ ស្មើនឹង២៥% សាលាបឋមសិក្សា២ធ្នូមាន០៦នាក់ ស្មើនឹង ២១.៤% សាលាបឋមសិក្សាចេកមាន០១នាក់ ស្មើនឹង៣.៦% សាលាបឋមសិក្សាគយត្របែក និង សាលាបឋមសិក្សាជម្ពូព្រឹក្សាមាន០៣នាក់ ស្មើនឹង១០.៧% សាលាបឋមសិក្សាសាមគ្គីមាន០១នាក់ ស្មើនឹង ៣.៦% សាលាបឋមសិក្សាក្រសាំងជ្រំមាន០២នាក់ ស្មើនឹង៧.១% និងសាលាបឋមសិក្សាចុងព្រែកមាន ០៥នាក់ ស្មើនឹង១៧.៩%។

## ៤.២ ទម្រង់នៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ

### ៤.២.១ ការវិភាគលម្អិតទៅទម្រង់នៃការចូលរួមមាតាបិតាសិស្សតាមសមាសភាពនីមួយៗ

#### ៤.២.១.១ ការវិភាគលម្អិតទៅទម្រង់នៃការចូលរួមមាតាបិតាសិស្សតាមបរិមាណវិស័យ

**សំណួរទី១៖ តើការអប់រំមានសារៈសំខាន់យ៉ាងណា?**

| | ប្រេងកង់ Frequency | ភាគរយ Percent | ភាគរយត្រឹមត្រូវ Valid Percent | ភាគរយរួម Cumulative Percent |
|---|---|---|---|---|
| សំខាន់ | 5 | 17.9 | 17.9 | 17.9 |
| សំខាន់បំផុត | 23 | 82.1 | 82.1 | 100.0 |
| សរុប | 28 | 100.0 | 100.0 | |

**យោងលើលទ្ធផលបង្ហាញ**

| លទ្ធផលនៃសំណួរទី១ | ចំនួន | Minimum | Maximum | Mean | Std. Deviation | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|
| | 28 | 4.00 | 5.00 | 4.82 | 0.39 | ល្អណាស់ |
| Valid N ( list wise ) | 28 | | | | | |

**រូបភាពក្រាបសំណួរទី១**



តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវមានបង្ហាញថា ការអប់រំមានសារៈសំខាន់ក្នុងកម្រិត «ល្អណាស់» (មធ្យមភាគ=៤.៨២ គម្លាតស្តង់ដារ =០.៣៩) នេះបញ្ជាក់បានថាមាតាបិតាសិស្សបានយល់និងឱ្យតម្លៃទៅលើការអប់រំថាពិតជាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះកូនៗរបស់ពួកគាត់ ដែលក្នុងចំណោមមាតាបិតាសិស្ស២៨នាក់មាន២៣នាក់ដែលត្រូវជា៨២.១%យល់ថាការអប់រំគឺសំខាន់ខ្លាំងបំផុត និងមាតាបិតាសិស្ស៥នាក់ដែលត្រូវជា១៧.៩%យល់ថាការអប់រំសំខាន់ ។

**តារាង៤.២.១.១៖ទម្រង់នៃការចូលរួមរបស់មាតាបិតាសិស្ស**

| ល.រ | ទម្រង់នៃការចូលរួម | បរិយាយ | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | ការចូលរួមក្នុងការអប់រំ | បញ្ជូនកុមារទៅសាលា | 23 | 82.1% |
| | | លើកទឹកចិត្ត(រង្វាន់)កុមារឱ្យសិក្សា | 15 | 53.6% |
| | | ផ្សព្វផ្សាយព័ត៌មានអប់រំ | 1 | 3.6% |
| | | ផ្សេងៗ | 1 | 3.6% |
| ២ | គាំទ្រកុមាររៀននៅផ្ទះ | បង្រៀនកុមារ | 13 | 46.4% |
| | | លើកទឹកចិត្តកុមារឱ្យសិក្សា | 11 | 39.3% |
| | | ពិនិត្យមើលសៀវភៅកត់ត្រារបស់កុមារ | 14 | 50.0% |
| | | ផ្សេងៗ | 5 | 17.9% |
| ៣ | បានទៅសាលារៀនញឹកញាប់ | រៀងរាល់ថ្ងៃ | 16 | 57.1% |
| | | ច្រើនដងក្នុងមួយសប្តាហ៍ | 5 | 17.9% |
| | | ពេលដែលមានការអញ្ជើញ | 5 | 17.9% |
| | | ម្តងក្នុងមួយសប្តាហ៍ | 3 | 10.7% |
| | | មិនដែល | 1 | 3.6% |
| ៤ | ហេតុផលក្នុងការទៅសាលារៀន | ចុះឈ្មោះកុមារ | 7 | 25.0% |
| | | ជួបជាមួយលោកគ្រូ អ្នកគ្រូ | 11 | 39.3% |
| | | នាំកុមារទៅសាលា | 13 | 46.4% |
| | | ផ្សេងៗ | 9 | 32.1% |
| ៥ | ប្រាស្រ័យទាក់ទងជាមួយសាលា | ទៅសាលារៀន | 11 | 39.3% |
| | | ចូលរួមប្រជុំ | 4 | 14.3% |
| | | ការហៅទូរសព្ទ | 14 | 50.0% |
| | | មានការអញ្ជើញ | 7 | 25.0% |

| | | | | |
|---|---|---|---|---|
| | | ផ្សេងៗ | 4 | 14.3% |
| ៦ | សាលាជាកម្មសិទ្ធិរួម ទាំងអស់គ្នា | រដ្ឋាភិបាល | 13 | 46.4% |
| | | គ្រូ | 1 | 3.6% |
| | | យើងទាំងអស់គ្នា | 15 | 53.6% |
| | | នាយកសាលា | 2 | 7.1% |
| | | ផ្សេងៗ | 2 | 7.1% |
| ៧ | ចូលរួមចំណែកក្នុងការ អប់រំ/ការអភិវឌ្ឍន៍ សាលារៀន | បរិច្ចាកថវិកា | 21 | 75.0% |
| | | បរិច្ចាកកម្លាំង | 2 | 7.1% |
| | | បរិច្ចាកសម្ភារៈ | 4 | 14.3% |
| | | ជួយថែរក្សាសាលា | 3 | 10.7% |
| | | ផ្សេងៗ | 4 | 14.3% |
| ៨ | ចូលរួមក្នុងសកម្មភាព របស់សាលារៀន | ចូលរួមប្រជុំ | 12 | 42.9% |
| | | បរិច្ចាកថវិកា សម្ភារៈ កម្លាំង | 13 | 46.4% |
| | | ចូលរួមបើកបវេសនកាល | 10 | 35.7% |
| | | ផ្សេងៗ | 0 | 0% |

តាមតារាង៤.២.១.១ខាងលើបានបង្ហាញពីទម្រង់នៃការចូលរួមរបស់ឪពុកម្តាយក្នុងការអប់រំដែលទទួលបានលទ្ធផលនៃការវិភាគក្នុងសូចនាករនីមួយៗធៀបជាមួយនឹងចំនួនសំណាកសរុប២៨នាក់ អ្នកស្រាវជ្រាវបានកំណត់ទម្រង់នៃទម្រង់នៃការចូលរួមរបស់ឪពុកម្តាយជាបីប្រភេទ ដើម្បីងាយស្រួលក្នុងការវិភាគ គឺ៖ **ប្រភេទទម្រង់ចូលរួមទី១**គឺ ការចូលរួមសកម្មភាពអប់រំនៅផ្ទះដោយផ្ទាល់ (សូចនាករទី១ និងទី២) **ប្រភេទទម្រង់ចូលរួមទី២** គឺ ការចូលរួមតាមសាលារៀនដោយផ្ទាល់( សូចនាករទី ២រហូតដល់ទី ៦) និង **ប្រភេទទម្រង់ចូលរួមទី៣** គឺ ការចូលរួមឧបត្ថម្ភដល់សាលា ដោយផ្ទាល់ ( សូចនាករទី៧ និង ទី៨ )។

**ប្រភេទទម្រង់ចូលរួមទី១៖ ការចូលរួមសកម្មភាពអប់រំនៅផ្ទះ**

ទម្រង់នៃការចូលរួមសកម្មភាពអប់រំនៅផ្ទះរបស់មាតាបិតាសិស្សមាន ការចូលរួមក្នុងការអប់រំដោយការបញ្ជូនកូនទៅសាលារៀន មានចំនួន២៣នាក់ ស្មើនឹង៨២.១% ចូលរួមលើកទឹកចិត្តកូនក្នុងការសិក្សាចំនួន១៥នាក់ត្រូវជា៥៣.៦% ផ្សព្វផ្សាយព័ត៌មានអប់រំមានចំនួន០១នាក់ ស្មើនឹង៣.១% និង

ទិន្នន័យផ្សេងៗចំនួន០១នាក់ ស្មើនឹង៣.៦%។ ការគាំទ្រកុមាររៀននៅផ្ទះ គឺបង្រៀនកុមារ១៣នាក់ស្មើនឹង៤៦.៤% ការពិនិត្យតាមដ្ឋានសៀវភៅកត់ត្រារបស់កូនមានចំនួន១៤នាក់ ស្មើនឹង៥០% ការលើកទឹកចិត្តកុមារឱ្យខិតខំរៀនសូត្រ១១នាក់ត្រូវនឹង៣៩.៣% និងផ្សេងៗមានចំនួន០៥នាក់ ស្មើនឹង១៧.៩% ។ តាមលទ្ធផលបានបង្ហាញថាទម្រង់នៃការចូលរួមសកម្មភាពអប់រំនៅផ្ទះរបស់មាតាបិតាសិស្សការបញ្ជូនកូនទៅសាលាមានភាគរយខ្ពស់ជាងគេរហូតដល់៨២.១% ដែលក្នុងនោះកាតចូលរួមលើកទឹកចិត្តកុមារឱ្យខិតខំរៀនសូត្រមាន៥៣.៦% និង សកម្មភាពគាំទ្រការរៀននៅផ្ទះរបស់កុមារដោយតាមដានសៀវភៅកត់ត្រារបស់ពួកគេមាន៥០%។ នេះបញ្ជាក់ថាមាតាបិតាសិស្សយល់ពីសារៈសំខាន់នៃការអប់រំ និង ផ្ដល់តម្លៃខ្ពស់ចំពោះការសិក្សារបស់កុមារ។




*រូបភាពប្រភេទទម្រង់ចូលរួមទី១៖ក្រាបទម្រង់នៃការចូលរួមនៅផ្ទះរបស់មាតាបិតាសិស្ស*

## ប្រភេទទម្រង់ចូលរួមទី២៖ ការចូលរួមនៅតាមសាលារៀនរបស់មាតាបិតាសិស្ស

ទម្រង់នៃការចូលរួមនៅតាមសាលារបស់មាតាបិតាសិស្ស មានការចូលរួមក្នុងសកម្មភាពរបស់សាលារៀនគឺការចូលរួមក្នុងការស្វែងរកថវិកា សម្ភារៈ កម្លាំងមានចំនួន១២នាក់ស្មើនឹង៤២.៩% ការចូលរួមប្រជុំមានចំនួន១៣នាក់ ស្មើនឹង៤៦.៤% ការចូលរួមបើកបវេសនកាលមានចំនួន១០នាក់ ស្មើនឹង៣៥.៧%។ ការទៅសាលារៀនជារៀងរាល់ថ្ងៃចំនួន១៦នាក់ត្រូវនឹង៥៧.១% ច្រើនដងក្នុងមួយសប្ដាហ៍ចំនួន០៥នាក់ស្មើនឹង១៧.៩% ពេលដែលមានការអញ្ជើញចំនួន០៥នាក់ត្រូវនឹង១៧.៩% ម្ដងក្នុងមួយស

ប្ដាហ៍មាន០៣នាក់ស្មើនឹង១០.៧% មិនដែលមាន០១នាក់ ត្រូវនឹង៣.៦%។ ការទៅសាលារៀនដើម្បីចុះឈ្មោះកុមារមានចំនួន០៧នាក់ស្មើនឹង២៥% ការជួបជាមួយលោកគ្រូ អ្នកគ្រូមាន១១នាក់ត្រូវនឹង៣៩.៣% ការនាំកុមារទៅសាលាមាន១៣នាក់ស្មើនឹង៤៦.៤% និងផ្សេងៗ០៩នាក់ស្មើនឹង៣២.១%។ ការប្រាស្រ័យទាក់ទងជាមួយសាលាគឺទៅសាលារៀនមានចំនួន១១នាក់ ស្មើនឹង៣៩.៣%ចូលរួមប្រជុំមានបួននាក់ស្មើនឹង១៤.៣% ការហៅទូរសព្ទមាន១៤នាក់ស្មើនឹង ៥០% មានការអញ្ជើញមាន០៧នាក់ស្មើនឹង២៥% និងផ្សេងៗមាន០៤នាក់ស្មើនឹង១៤.៣%។ ការចាត់ទុកសាលាជាកម្មសិទ្ធិរបស់ រាជរដ្ឋាភិបាលមានចំនួន១៣នាក់ ស្មើនឹង៤៦.៤% គ្រូបង្រៀនមាន០១នាក់ ស្មើនឹង៣.៦% យើងទាំងអស់គ្នាមានចំនួន១៥នាក់ ស្មើនឹង៥៣.៦% នាយកសាលាមានចំនួន០២នាក់ ស្មើនឹង៧.១% និងផ្សេងៗមានចំនួន០២នាក់ ស្មើនឹង៧.១% ។ តាមលទ្ធផលបានបង្ហាញទម្រង់នៃការចូលរួមនៅតាមសាលារបស់មាតាបិតាសិស្សគឺមានភាគរយប្រហាក់ប្រហែលគ្នាក្នុងនោះការចូលរួមក្នុងការស្វែងរកថវិកា សម្ភារៈ កម្លាំងមាន៤២.៩% ការចូលរួមប្រជុំ និងការនាំកុមារទៅសាលាមានភាគរយស្មើគ្នាគឺ៤៦.៤% ការប្រាស្រ័យទាក់ទងជាមួយសាលាដោយការហៅទូរសព្ទមាន៥០% ការទៅសាលារៀនជារៀងរាល់ថ្ងៃមាន៥៧.១%។ នេះបញ្ជាក់ថាមាតាបិតាសិស្សបានចូលរួមសកម្មភាពរបស់សាលារៀន និងព្រឹត្តការណ៍ផ្សេងដែលរៀបចំដោយសាលា ហើយមានទំនាក់ទំនងល្អជាមួយសាលារៀនផងដែរ។

*រូបភាពប្រភេទទម្រង់ចូលរួមទី២៖ក្រោបការចូលរួមនៅតាមសាលារៀនរបស់មាតាបិតាសិស្ស*




**ប្រភេទទម្រង់ចូលរួមទី៣៖ ការចូលរួមឧបត្ថម្ភដល់សាលារៀនរបស់មាតាបិតាសិស្ស**

ការចូលរួមឧបត្ថម្ភដល់សាលារៀនរបស់មាតាបិតាសិស្សមាន ការចូលរួមចំណែកក្នុងការអប់រំក៏ដូចជាការអភិវឌ្ឍន៍សាលារៀនដោយបរិច្ចាកថវិកាមានចំនួន២១នាក់ ស្មើនឹង៧៥% បរិច្ចាកកម្លាំងមានចំនួន០២នាក់ ស្មើនឹង៧.១% បរិច្ចាកសម្ភារៈមានចំនួន០៤នាក់ស្មើនឹង១៤.៣% ការជួយថែរក្សាសាលាមានចំនួន០៣នាក់ស្មើនឹង១០.៧% និងផ្សេងៗមានចំនួន០៤នាក់ស្មើនឹង១៤.៣% ។ តាមលទ្ធផលបានបង្ហាញថាការចូលរួមឧបត្ថម្ភដល់សាលារៀនរបស់មាតាបិតាសិស្ស សូចនាករដែលមានភាគរយខ្ពស់ជាងគេគឺ ការចូលរួមចំណែកក្នុងការអប់រំក៏ដូចជាការអភិវឌ្ឍន៍សាលារៀនដោយបរិច្ចាកថវិកាមាន៧៥%។ នេះបញ្ជាក់ថាមាតាបិតាភាគច្រើនចូលរួមឧបត្ថម្ភជាថវិកាដល់សាលារៀនក្នុងការអភិវឌ្ឍ និងបំពេញតម្រូវការរបស់សាលារៀន។




*រូបភាពប្រភេទទម្រង់ចូលរួមទី២៖ ក្រាបការចូលរួមឧបត្ថម្ភដល់សាលារបស់មាតាបិតាសិស្ស*

សាលារៀននិងសហគមន៍មានទំនាក់ទំនងគ្នាទៅវិញទៅមកដូចដែលបានបង្ហាញ មាតាបិតាសិស្សទៅសាលាក្នុងគោលបំណងជាច្រើនដូចជាការចុះឈ្មោះកុមារឱ្យចូលរៀន ជួបជាមួយលោកគ្រូអ្នកគ្រូ និងនាំកុមារទៅសាលារៀន ថាមាតាបិតាសិស្សទៅសាលារៀនដើម្បីជូនកូនទៅសាលា និងបានទំនាក់ទំនងជាមួយគ្រូបង្រៀនរបស់កូនៗ។ សាលារៀននិងមាតាបិតាសិស្សត្រូវមានទំនាក់ទំនងគ្នាជាប្រចាំដើម្បីទទួលព័ត៌មាននានាអំពីការសិក្សារៀនសូត្ររបស់កុមារ។ ទាំងនេះបញ្ជាក់ថាមាតាបិតាសិស្សយល់ថាសាលាជារបស់ពួកយើងទាំងអស់គ្នាមានភាគរយច្រើន ដែលបង្ហាញថាពួកគាត់ចាត់ទុកសាលាជារបស់ទ្រព្យរួម ដូចនេះត្រូវរួមគ្នាថែរក្សានិងអភិវឌ្ឍឱ្យកាន់តែប្រសើរ។ ដើម្បីឱ្យការអប់រំក៏ដូចជាសាលារៀនមានការអភិវឌ្ឍសហគមន៍ត្រូវចូលរួមចំណែក ដោយមិនអាចខ្វះបាន។ ការចូលរួមរបស់សហគមន៍មានច្រើនទម្រង់ខុសៗគ្នាដូចជាការចូលរួមដោយបរិច្ចាកថវិកា ថែទាំសាលារៀន បរិច្ចាកសម្ភារៈ ចូលរួមចំណែកជួយជាកម្លាំងក្នុងការធ្វើការងារនិងការចូលរួមផ្សេងៗទៀត។

ដូចនេះលទ្ធផលវាយតម្លៃ បានបង្ហាញថាមាតាបិតាសិស្សពិតជាយកចិត្តទុកដាក់ចំពោះការអប់រំរបស់កូនៗព្រមទាំងចូលរួមយ៉ាងផុសផុលក្នុងវិស័យអប់រំ។ តាមរយៈលទ្ធផលខាងលើអាចបញ្ជាក់បានថាសកម្មភាពជាច្រើនដែលមាតាបិតាសិស្សបានផ្តល់ការគាំទ្រដល់ការសិក្សារបស់កូនរៀននៅផ្ទះដូចជាជួយ

បង្រៀន លើកទឹកចិត្ត ពិនិត្យសម្ភារសិក្សា ពិនិត្យតាមដានលទ្ធផលការសិក្សារបស់កុមារ និងទូន្មានកុមារឱ្យផ្តោតអារម្មណ៍លើសិក្សា ខិតខំរៀនដើម្បីអានាគត។ មាតាបិតាសិស្សភាគច្រើនបានទៅសាលារៀនជារៀងរាល់ថ្ងៃ ក្នុងគោលបំណងជូនកូនទៅ និងទទួលកូនពីសាលា។ មាតាបិតាសិស្សមួយចំនួនទៀតទៅសាលាច្រើនដងក្នុងមួយសប្តាហ៍ដើម្បីសាកសួរព័ត៌មានអំពីការសិក្សារបស់កូន ប៉ុន្តែមាតាបិតាសិស្សខ្លះទៀតទៅសាលាម្តងក្នុងមួយសប្តាហ៍ និងមិនដែលសោះដោយសារពួកគាត់រវល់។ មាតាបិតាសិស្សបានទៅសាលារៀនដែលកូនពួកគាត់កំពុងរៀនរាល់ពេល ដែលមានការអញ្ជើញឱ្យចូលរួមក្នុងព្រឹត្តការណ៍សំខាន់របស់សាលាដូចជាបើកបវេសនកាលឆ្នាំសិក្សាថ្មី ពិធីចែករង្វាន់សិស្សពូកែជាដើម។

### ៤.២.១.២ ការវិភាគលម្អិតទៅទម្រង់នៃការចូលរួមមាតាបិតាសិស្សតាមបែបគុណវិស័យ

តាមព័ត៌មានដែលទទួលបានពីក្រុមអ្នកចូលរួមសំខាន់ទាំងប្រាំបានលើកឡើងពីទម្រង់នៃការចូលរួមរបស់សហគមន៍ជាពិសេសមាតាបិតាសិស្សមានបីប្រភេទដែលប្រភេទទម្រង់ចូលរួមទីពីរ ការរួមចំណែកដល់សាលារៀនជាថវិកាមានចំនួនច្រើនគឺ៧៥% ដែលឪពុកម្តាយ និងសមាជិកសហគមន៍ផ្សេងទៀតបានបរិច្ចាកសម្រាប់សាលារៀន។ ខណៈពេលដែលការអប់រំនៅតាមបឋមសិក្សាសាធារណៈនៅក្នុងប្រទេសកម្ពុជាគឺមិនគិតថ្លៃ តាមជាក់ស្តែង រដ្ឋាភិបាលជាអ្នកផ្តល់ប្រាក់បៀវត្សរ៍គ្រូបង្រៀន ហើយថវិកាមូលនិធិដំណើរការសាលារៀន(SOF)មិនអាចរ៉ាប់រងលើការចំណាយដូចជាការជួសជុលធំៗ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលមានតម្លៃថ្លៃផ្សេងទៀតទេ។ ដូច្នេះឪពុកម្តាយតែងតែត្រូវបានស្នើសុំឱ្យចូលរួមបរិច្ចាកថវិកាដើម្បីរ៉ាប់រងការចំណាយរបស់សាលា គ្រប់ករណីទាំងអស់ដែលបានរាយការណ៍នៅក្នុងការសិក្សានេះចំនួនថវិកាដែលបានបរិច្ចាកគឺជាការស្ម័គ្រចិត្តដូចដែលគណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស)ម្នាក់បាននិយាយថា៖

*«.....យើងធ្វើវិភាគទានតាមសមត្ថភាពរបស់ពួកយើង មានប៉ុនណាចូលរួមតាមហ្នឹង...»*

*«...បើកបវេសនកាល ផ្តល់ថវិកាសម្រាប់កសាងសាលា» (គ.គ.ស#1,2)*

ហើយត្រូវបានចូលរួមតាមរយៈមធ្យោបាយផ្សេងៗ ពិធីបុណ្យបែបប្រពៃណីសាសនា ការប្រជុំ និងព្រឹត្តិការណ៍សាលារៀនផ្សេងៗ។ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋដែលប្រជាជននៅកម្ពុជាគោរព

ប្រតិបត្តិ សាលារៀន និងព្រះសង្ឃធ្វើការរួមគ្នាក្នុងការអែងាសប្រាក់ពីអ្នកភូមិដើម្បីជួយសាលា។ ឧទាហរណ៍ព្រះសង្ឃឬពុទ្ធសាសនិកផ្សព្វផ្សាយដល់អ្នកភូមិក្នុងការរួមចំណែកក្នុងទម្រង់ណាមួយ ដើម្បីជួយសាលាក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ បុណ្យចូលឆ្នាំខ្មែរ បុណ្យផ្កា បុណ្យកឋិនជាដើម។ ព្រះចៅអធិការវត្តមួយអង្គបានមានសង្ឃដីកាថា៖

*«...ព្រះសង្ឃបានបរិច្ចាកថវិកាសម្រាប់ជួលគ្រូបង្រៀនសិស្សនិងផ្គត់ផ្គង់អាហារបីពេលសម្រាប់សិស្សនិងនិស្សិត ពេលខ្លះសម្រាប់ព្យាបាលជំងឺថែមទៀតផង»*។

*«...ការចូលរួមបរិច្ចាកជាដី សម្ភារៈ ថវិកា គំនិត គៀរគពុទ្ធបរិស័ទមកធ្វើតុនិងបន្ទប់សម្រាប់សិក្សា ដាក់ហិបសប្បុរសជំមនៃអង្គការនៅក្នុងវត្ត» (#Monk1,2)*

គណៈកម្មការទ្រទ្រង់សាលាដែលត្រូវបានសម្ភាសទទួលស្គាល់ថា សាលាត្រូវការហិរញ្ញវត្ថុ ធនធាន ហើយពួកគេចង់ជួយដល់សាលា ដូចដែល គណៈកម្មការគ្រប់គ្រងសាលាម្នាក់បានពន្យល់ថា៖

*«តាមរយៈមាតាបិតាសិស្សឬសិស្ស បានឱ្យដឹងថា សាលាខ្វះខាតថវិកាដើម្បីធ្វើអ្វីមួយដូច្នេះពួកគេបរិច្ចាគប្រាក់ខ្លះដើម្បីជួយសាលា...»* (គ.គ.ស#1)។

*«...ខ្ញុំបានប្រាប់ឪពុកម្ដាយសិស្សថាសាលាខ្វះថវិកាខ្លះដើម្បីជួសជុលសាលាដូច្នេះសូមមាតាបិតាសិស្សទាំងអស់បរិច្ចាគថវិកាជួយដល់សាលា។»*

*«...ការចូលរួមរបស់សហគមន៍មានច្រើនទាំងគំនិតយោបល់ ថវិកា សម្ភារៈ និងកម្លាំងផងដែរដូចជាសម្ភារៈដូចជាសូឡាបភ្លឺសាលា ជូនរង្វាន់សម្រាប់សិស្ស(សៀវភៅ ប៊ិក ...) ផ្ដល់កង្ហា ទូរដាក់សម្ភារៈតាមបន្ទប់ អាល់កុល ម៉ាស់ ម៉ាស៊ីនវាស់កម្ដៅ...ផ្ដល់ថវិកាសម្រាប់ចាក់ដី និងផ្ដល់សម្ភារៈការិយាល័យមានកុំព្យូទ័រជាដើម»* (Principal#1)

## ៤.២.២ ការវិភាគទៅលើកត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សចូលរួមក្នុងការអប់រំ

### ៤.២.២.១ ការវិភាគលម្អិតទៅលើកត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សចូលរួមក្នុងការអប់រំ

**តាមបែបបរិមាណវិស័យ**

តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបាននបង្ហាញថាការរួមចំណែកធនធានក្នុងការអប់រំមានសារៈសំខាន់ក្នុងកម្រិត «ល្អ » (មធ្យមភាគពិន្ទុ=៤.១៤ និងមានគម្លាតស្តង់ដារ=០.៥៩ ) នេះបញ្ជាក់បានថាមាតាបិតាសិស្សបានយល់ថាការចូលរួមបរិច្ចាកជាធនធាន ពិតជាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍសាលាក៏ដូចការសិក្សាកូនៗរបស់ពួកគាត់ដែលក្នុងចំណោមមាតាបិតាសិស្ស២៨នាក់មាន០៣នាក់ដែលស្មើនឹង១០.៧% យល់ថាការចូលរួមបរិច្ចាកធនធានគឺសំខាន់ និងក្នុងចំនោមមាតាបិតាសិស្សដែលបានចូលរួមទាំងអស់មានមាតាបិតាសិស្សចំនួ១៨នាក់ដែលត្រូវជា៦៤.៣% ដែលយល់ថាការអប់រំ

| **សំណួរទី១០៖** តើអ្នកគិតថាការរួមចំណែកធនធានមានសារៈសំខាន់ឬទេ? | | | | |
|---|---|---|---|---|
| **កម្រិតចង្អុលបង្ហាញ** | **ប្រេកង់** Frequency | **ភាគរយ** Percent | **ភាគរយត្រឹមត្រូវ** Valid Percent | **ភាគរយរួម** Cumulative Percent |
| សំខាន់ | 3 | 10.7 | 10.7 | 10.7 |
| សំខាន់ជាង | 18 | 64.3 | 64.3 | 75.0 |
| សំខាន់បំផុត | 7 | 25.0 | 25.0 | 100.0 |
| សរុប | 28 | 100.0 | 100.0 | |

| លទ្ធផលនៃសំណួរទី១០ | ចំនួន | Minimum | Maximum | Mean | Std. Deviation | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|
| | 28 នាក់ | 3.00 | 5.00 | 4.1429 | 0.59 | ល្អ |
| សរុប | 28នាក់ | | | | | |

សំខាន់ខ្លាំង និងសំខាន់ខ្លាំងបំផុតមានចំនួន ០៧ នាក់ស្មើនឹង២៥% ។




*រូបភាព៖ ក្រាបសំណួរទី១០*

តារាងខាងក្រោមបង្ហាញពីកត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សក្នុងការចូលរួមក្នុងការអប់រំ

**តារាង៤.២.២.១៖ កត្តាលើកទឹកចិត្តក្នុងការចូលរួមក្នុងការអប់រំ**

| ល.រ | ការលើកទឹកចិត្តក្នុងការចូលរួមក្នុងការអប់រំ | បរិយាយ | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | កត្តាលើកទឹកចិត្តក្នុងការចូលរួមក្នុងការអប់រំ | សម្រាប់ការអប់រំរបស់កុមារ | 13 | 6.9% |
| | | សម្រាប់អនាគតរបស់កុមារ | 19 | 67.9% |
| | | សម្រាប់អភិវឌ្ឍសាលា | 4 | 14.3% |
| | | កាត់បន្ថយអនាធិបតេយ្យ | 1 | 3.6% |
| | | ផ្សេងៗ | 1 | 3.6% |
| ២ | ការចូលរួមស្វែងរកថវិកាសម្រាប់ឧបត្ថម្ភដល់សាលារៀន | បុណ្យផ្កា | 6 | 21.4% |
| | | បុណ្យកឋិន | 5 | 17.9% |
| | | បុណ្យសាលា | 19 | 67.9% |
| | | បុណ្យវង្គាសបច្ច័យ | 4 | 14.3% |
| | | ផ្សេងៗ | 5 | 17.9% |
| ៣ | ការចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗដែលរៀបចំដោយសាលា | ពិព័ណស្នាដៃសិស្ស | 2 | 7.1% |
| | | ទស្សនកិច្ចសិក្សា | 2 | 7.1% |
| | | ការប្រកួតកីឡា | 12 | 42.9% |
| | | ពិធីចែករង្វាន់សិស្សពូកែ | 10 | 35.7% |
| | | ផ្សេងៗ | 8 | 28.6% |
| ៤ | | ចាត់ទុកសាលាជាសម្បត្តិរួម | 14 | 50% |

| | | | | |
|---|---|---|---|---|
| | ការចូលរួមថែរក្សាទ្រព្យសម្បត្តិរបស់សាលារៀន | ជួសជុល | 1 | 3.6% |
| | | ជួយថែរក្សានិងការពារ | 17 | 60.7% |
| | | ផ្សេងៗ | 3 | 10.7% |
| ៥ | ការចូលរួមផ្ដល់នូវមូលដ្ឋានសម្ភារៈដើម្បីបម្រើឱ្យការរៀននិងបង្រៀនដល់សាលារៀន | សម្ភារៈពិសោធន៍ | 7 | 25.0% |
| | | សម្ភារៈសម្រាប់សិក្សា | 18 | 64.3% |
| | | សម្ភារៈសម្រាប់ឧបទ្ទេស | 2 | 7.1% |
| | | ផ្សេងៗ | 6 | 21.4% |

តារាង៤.២.២.១ ខាងលើបានបង្ហាញពីការលើកទឹកចិត្តក្នុងការចូលរួមរបស់ឪពុកម្ដាយក្នុងការអប់រំដែលទទួលបានលទ្ធផលនៃការវិភាគក្នុងសូចនាករនីមួយៗធៀបជាមួយនឹងចំនួនសំណាកសរុប ២៨ នាក់ អ្នកស្រាវជ្រាវបានកំណត់កត្តាជំរុញលើកទឹកចិត្តនៃការចូលរួមរបស់ឪពុកម្ដាយជាពីរកត្តា ដើម្បីងាយស្រួលក្នុងការវិភាគ គឺ៖ (១)កត្តាជំរុញលើកទឹកចិត្តពីខាងក្នុង (សូចនាករទី១) កត្តាជំរុញលើកទឹកចិត្តពីខាងក្រៅ ដោយផ្ដុំសូចនាករទី២ រហូតដល់ សូចនាករទី៥។

**(១)កត្តាជំរុញលើកទឹកចិត្តពីខាងក្នុង**

កត្តាជំរុញលើកទឹកចិត្តពីខាងក្នុងនៃការចូលរួមក្នុងការអប់រំរបស់មាតាបិតា គឺសម្រាប់ការអប់រំរបស់កុមារមានចំនួ១៣នាក់ ស្មើនឹង៤៦.៤% សម្រាប់អនាគតរបស់កុមារមានចំនួន១៩នាក់ ស្មើនឹង ៦៧.៩% សម្រាប់អភិវឌ្ឍសាលាមាន០៤នាក់ ត្រូវនឹង១៤.៣% កាត់បន្ថយអនាធិបតេយ្យមាន០១នាក់ ស្មើនឹង៣.៦% ផ្សេងៗមានចំនួន០១នាក់ ស្មើនឹង៣.៦% ។

**(២)កត្តាជំរុញលើកទឹកចិត្តពីខាងក្រៅ**

កត្តាដែលជំរុញលើកទឹកចិត្តពីក្រៅ មានការចូលរួមស្វែងរកថវិកាសម្រាប់ឧបត្ថម្ភដល់សាលារៀនដោយធ្វើបុណ្យផ្កាមានចំនួន៦នាក់ស្មើនឹង២១.៤% បុណ្យកឋិនមានចំនួន៥នាក់ស្មើនឹង១៧.៩%បុណ្យសាលាមានចំនួន១៩នាក់ស្មើនឹង៦៧.៩% បុណ្យវង្គាសបច្ច័យមាន៤នាក់ស្មើនឹង១៤.៣% ផ្សេងៗមាន៥នាក់ស្មើនឹង១៧.៩%។ ការចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗដែលរៀបចំដោយសាលាគឺពិព័ណស្នាដៃសិស្សមានចំនួន០២នាក់៧.១% ទស្សនកិច្ចសិក្សាមាន២នាក់ស្មើនឹង៧.១% ការប្រកួតកីឡាមាន១២នាក់ស្មើ

នឹង៤២.៩% ពិធីចែករង្វាន់សិស្សពូកែមានចំនួន១០នាក់ស្មើនឹង៣៥.៧% ផ្សេងៗមាន០៨នាក់ស្មើនឹង ២៨.៦%។ ការចូលរួមថែរក្សាទ្រព្យសម្បត្តិរបស់សាលារៀនដោយចាត់ទុកសាលាជាសម្បត្តិរួមមានចំនួន ១៤នាក់ ស្មើនឹង៥០%ជួសជុលមាន ០១នាក់ស្មើនឹង ៣.៦% ជួយថែរក្សានិងការពារមាន១៧នាក់ស្មើនឹង ៦០.៧% និងផ្សេងៗមាន៣នាក់ស្មើនឹង១០.៧%។ ការចូលរួមផ្តល់នូវមូលដ្ឋានសម្ភារៈដើម្បីបម្រើឱ្យការរៀននិងបង្រៀនដល់សាលារៀនគឺសម្ភារៈពិសោធន៍មានចំនួន៧នាក់ស្មើនឹង ២៥%សម្ភារៈសម្រាប់សិក្សាមាន១៨នាក់ស្មើនឹង ៦៤.៣% ផ្សេងៗមាន ០៦នាក់ស្មើនឹង ២១.៤%។

ដូចនេះយើងអាចសន្និដ្ឋានបានថាសហគមន៍ចូលរួមក្នុងការអប់រំដោយសារកត្តាជាច្រើនសម្រាប់អនាគតរបស់កុមារនិងអភិវឌ្ឍការអប់រំឱ្យកាន់តែប្រសើរដោយការចូលរួមស្វែងរកថវិកាសម្រាប់ឧបត្ថម្ភដល់សាលារៀននិងការចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗដែលរៀបចំដោយសាលាថែមទាំងចូលរួមថែរក្សាទ្រព្យសម្បត្តិរបស់សាលារៀន។ ការចូលរួមផ្តល់នូវមូលដ្ឋានសម្ភារៈដើម្បីបម្រើឱ្យការរៀននិងបង្រៀនដល់សាលារៀនអាចកើតឡើងបាននៅពេលដែលសហគមន៍មានការជឿជាក់លើសាលារៀន។

ដើម្បីកាន់តែងាយយល់ និងសម្គាល់ ក្រាប៤.២.៣.១ ខាងក្រោមបង្ហាញបន្ថែមអំពីកត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សចូលរួមក្នុងការអប់រំ។




*រូបភាព ៤.២.២.១៖ ក្រាបកត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សចូលរួមក្នុងការអប់រំ*

**៤.២.២.២ ការវិភាគលម្អិតទៅលើកត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សចូលរួមក្នុងការអប់រំ**

**តាមបែបគុណវិស័យ**

យោងតាមព័ត៌មានខាងលើការលើកទឹកចិត្តមាតាបិតាសិស្សក្នុងការចូលរួមក្នុងការអប់រំព្រោះមានការចាប់អារម្មណ៍ក្នុងការជួយដល់ការសិក្សារបស់កុមារ ចង់ឃើញកូនមានអនាគតបវរ ក្លាយជាពលរដ្ឋល្អ និងអ្នកដឹកនាំល្អក្នុងសហគមន៍ ចង់ឃើញសាលាមានភាពប្រសើរឡើង។ បំណងនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំគឺចង់ឱ្យកូនចៅជំនាន់ក្រោយដែលជាទំពាងស្នងពីពួកគាត់មានចំណេះដឹង ចំណេះធ្វើ បំណិន ជំនាញ។ ទិន្នន័យដែលទទួលបានពីការសម្ភាសន៍នាយកសាលាភាគច្រើនបានលើកឡើងថា៖

*«...សហគមន៍ចូលរួមជាមួយសាលាដើម្បីអនាគតកូនចៅជំនាន់ក្រោយ មានចិត្តល្អ កូនៗរបស់ពួកគាត់រៀននៅសាលាហ្នឹង ពួកគាត់ធ្លាប់រៀននៅសាលាហ្នឹងឃើញសាលាអភិវឌ្ឍន៍ក៏ចង់ចូលរួម មើលឃើញពីការខ្វះខាតរបស់សាលា»*

*«...សហគមន៍ចូលរួមជាមួយសាលាដោយសារចង់ធ្វើបុណ្យសាងកុសលដើម្បីជួបសំណាងល្អក្នុងជីវិត និងដើម្បីកូនចៅជំនាន់ក្រោយ» (Principal#1,2,3)*

សហគមន៍នឹងងាកមកចូលរួមជាមួយសាលារៀនកាន់តែច្រើន ដោយសារសាលារៀនមានតម្លាភាព មានទំនាក់ទំនងល្អជាមួយសហគមន៍ និងមានការអភិវឌ្ឍសាលាជាលំដាប់។ សាលាក៏មានធ្វើលិខិតថ្លែងអំណរគុណជូនសប្បុរសជនដែលបានចូលរួមដោយបរិច្ចាកធនធានផ្ទាល់ខ្លួនក្នុងការអភិវឌ្ឍសាលា។ ម្យ៉ាងវិញទៀតសាលាបានបង្ហោះជាសារថ្លែងអំណរគុណតាមបណ្ដាញសង្គមផងដែរ។ ទិន្នន័យដែលទទួលបានពីការសម្ភាសន៍នាយកសាលា៖

*«...ការធ្វើប័ណ្ណថ្លែងអំណរគុណ ឬបង្ហោះការថ្លែងអំណរគុណតាមផេកហ្វេសប៊ុកសាលារាល់ការជួយឧបត្ថម្ភរបស់មាតាបិតាសិស្ស» (Pricipal#2)*

ការធ្វើសេចក្ដីសម្រេចចិត្តចូលរួមក្នុងដំណើរការសាលារៀន គឺជាការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍ក្នុងការសម្រេចចិត្តជាមួយសាលាលើ អភិបាលកិច្ច សកម្មភាពសាលា និងការអភិវឌ្ឍន៍ការអប់រំតាមរយៈគណៈកម្មការសាលា។ នាយកសាលាពីររូប បានមានប្រសាសន៍ថា៖

*«...កាលណាការគ្រប់គ្រងនៅសាលាមានតម្លាភាព មានទំនាក់ទំនងល្អ រួសរាយរាក់ទាក់ បរិស្ថានសាលាស្អាត បន្ទប់ទឹកស្អាតគ្រប់គ្រាន់ ធ្វើឱ្យសហគមន៍ជឿជាក់ ពង្រឹងវិន័យគ្រូ» «...សហគមន៍ជួយឧបត្ថម្ភអ្វីគឺធ្វើឱ្យសហគមន៍ឃើញ គោរពពេលវេលាចូលរៀនម៉ោង៧ ចេញម៉ោង១១ សិស្សរៀនឆាប់ចេះ ដាក់កិច្ចការផ្ទះឱ្យសិស្សជារៀងរាល់ថ្ងៃ ជំរុញលើកទឹកចិត្តពួកគាត់ឱ្យកូនមករៀន» (Principal#4,5)*

ទិន្នន័យសម្ភាសន៍បង្ហាញថា សហគមន៍ក្នុងតំបន់ស្រាវជ្រាវបានចូលរួមក្នុងការសម្រេចចិត្តជ្រើសរើសគណៈកម្មការគ្រប់គ្រងសាលា (គ.គ.ស) រួមមាន អាជ្ញាធរមូលដ្ឋាន ព្រះចៅអធិការវត្ត គ្រូចូលនិវត្តន៍ ឪពុកម្តាយ។ ក្នុងនាមជាសមាជិកនៃ គណៈកម្មការគ្រប់គ្រងសាលារៀនទាំងនេះមានតួនាទី និងទំនួលខុសត្រូវក្នុងការសម្រេចចិត្តនៅក្នុងសាលាដែលពួកគេត្រូវបានជ្រើសរើសឱ្យធ្វើការ។ ផ្អែកលើគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ ២០១២) គណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវបានបង្កើតឡើងក្នុងគោលបំណងជាតំណាង ឪពុកម្តាយ និងសហគមន៍នៅក្នុងសាលារៀនដែលមានតួនាទីក្នុងការសម្រេចចិត្ត និងការគ្រប់គ្រងសាលារៀន។ ការសិក្សាបានរកឃើញថា គណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស) បានចូលរួមក្នុងការសម្រេចចិត្តនៅក្នុងសាលានិងការគ្រប់គ្រងការអប់រំ។ យោងតាមបទសម្ភាសន៍ជាមួយនាយកសាលា « គណៈកម្មការគ្រប់គ្រងសាលារៀនបានចូលរួមក្នុងការបង្កើតផែនការអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំ (SDPs) ការអនុវត្ត និងការត្រួតពិនិត្យSDPs» ។ នាយកសាលាម្នាក់បាននិយាយថា ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន របស់ខ្លួន ត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំផ្លូវការជាមួយគ្រូដើម្បីបង្កើតការអភិវឌ្ឍសាលាផែនការដើមឆ្នាំសិក្សា (Pricipal#2)។ ដោយសារតែសហគមន៍គឺជាប្រភពថវិកាសំខាន់សម្រាប់ការអភិវឌ្ឍន៍សាលារៀន (Pricipal#3) ការរកឃើញនេះបង្ហាញថាគំនិតរបស់សហគមន៍ត្រូវបានគោរព និងផ្តល់អាទិភាពសម្រាប់ការធ្វើផែនការអភិវឌ្ឍសាលារៀន និងការអប់រំ។ យោងតាមការអត្ថាធិប្បាយរបស់គណៈកម្មការទ្រទ្រង់សាលាបឋមពន្លា អកនាគ បានចែករំលែកនូវទំនួលខុសត្រូវ និងតួនាទីរបស់គាត់នៅក្នុង ការសម្រេចចិត្តសម្រាប់ការអភិវឌ្ឍន៍សាលារៀន និងការអប់រំ។ គណៈកម្មការគ្រប់គ្រងសាលារៀន បានបង្ហាញថា បានចូលរួមក្នុងការគ្រប់គ្រងសាលា ការប្រើ

ប្រាស់ថវិកា និងផែនការថវិកាដែលផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡាអង្គការក្រៅរដ្ឋាភិបាលដែលជាដៃគូអភិវឌ្ឍ ។ យោងតាមគោលការណ៍ណែនាំថវិការរបស់ក្រសួងអប់រំ យុវជន និងកីឡាសាលារៀនមិនអាចប្រើប្រាស់ជំនួយដោយមិនមានការទទួលស្គាល់ ឬការចូលរួមពីគណៈកម្មការគ្រប់គ្រងសាលារៀន និងរដ្ឋាភិបាលបានទេ (MoEYS, ២០២៣)។ សាលាទាំងអស់មានផែនការអភិវឌ្ឍន៍ និងផែនការថវិកាដែល ត្រូវបានធ្វើឡើងដោយមានការចូលរួមពីគ្រូ និងគណៈកម្មការគ្រប់គ្រងសាលារៀន (ផែនការអភិវឌ្ឍន៍សាលារៀន ២០២២-២០២៣) ព្រះសង្ឃមួយអង្គបានមានពុទ្ធដីកាពីការចូលរួមក្នុងផែនការថវិកា និងការរៃអង្គាសថវិកាឱ្យសាលាដោយបែងចែកថវិការសម្រាប់ផែនការអភិវឌ្ឍន៍ និងអនុញ្ញាតឱ្យដាក់ហិបកសាងនៅក្នុងវត្តរាល់ពេលបុណ្យទាន(Monk#1)។

### ៤.២.៣ ការវិភាគលម្អិតទម្រង់ចូលរួមរបស់គ្រូបង្រៀនតាមសមាសភាពនីមួយៗ

#### ៤.២.៣ .១ ការវិភាគលម្អិតទៅលើទម្រង់ចូលរួមរបស់គ្រូបង្រៀតាមបែបបរិមាណវិស័យ

| **សំណួរទី១៖ តើ ទំនាក់ទំនងរវាងគ្រូបង្រៀន និងសហគមន៍មានសារៈសំខាន់ដែរឬទេ?** | | | | |
|---|---|---|---|---|
| **កម្រិតចង្អុលបង្ហាញ** | **ប្រេកង់** Frequency | **ភាគរយ** Percent | **ភាគរយត្រឹមត្រូវ** Valid Percent | **ភាគរយសរុប** Cumulative Percent |
| មិនសំខាន់ | 1 | 0.8 | 0.8 | 0.8 |
| សំខាន់ខ្លះ | 3 | 2.3 | 2.3 | 3.0 |
| សំខាន់ | 37 | 27.8 | 27.8 | 30.8 |
| សំខាន់ខ្លាំង | 92 | 69.2 | 69.2 | 100.0 |
| សរុប | 133 | 100.0 | 100.0 | |

| លទ្ធផលនៃសំណួរទី១ | ចំនួន | Minimum | Maximum | Mean | Std. Deviation | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|
| | 133នាក់ | 1.00 | 5.00 | 4.64 | 0.60 | ល្អណាស់ |
| សរុប | 133នាក់ | | | | | |

*រូបភាពក្រាបសំណួរទី១*




តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវមានបង្ហាញថាទំនាក់ទំនងរវាងមាតាបិតាសិស្សនិងសាលារៀនមានសារៈសំខាន់ក្នុងកម្រិត«ល្អ »(មធ្យមភាគពិន្ទុ=៤.៦៤ និងមានគម្លាតស្តង់ដារ=0.៦០)នេះបញ្ជាក់ថាសារៈសំខាន់នៃទំនាក់ទំនងរវាងគ្រូបង្រៀន សហគមន៍ពិតជាមានភាពជឿជាក់ខ្លាំង។ បានថាគ្រូបង្រៀនបានយល់ថាទំនាក់ទំនងរវាងសាលាជាមួយសហគមន៍ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការអភិវឌ្ឍសាលាក៏ដូចការសិក្សាកុមារដែលក្នុងចំណោមគ្រូបង្រៀន១៣៣នាក់មាន ៩២នាក់ ដែលត្រូវជា ៦៩.២%% យល់ថាទំនាក់ទំនងរវាងសាលាជាមួយសហគមន៍ពិតជាសំខាន់ខ្លាំងណាស់ និងគ្រូបង្រៀនចំនួន ៣៧នាក់ ដែលត្រូវជា ២៧.៨% យល់ថាការអប់រំសំខាន់ និងយល់ថាការអប់រំមិនសំខាន់ មានចំនួន ០១នាក់ ស្មើនឹង0.៨% ។

**តារាងទី៤.២.៤.១៖ទម្រង់នៃការចូលរួមរបស់គ្រូបង្រៀន**

| ល.រ | ទម្រង់នៃការចូលរួម | បរិយាយ | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | ប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយនិងសមាជិកសហគមន៍ | ជួបនៅផ្ទះ | 31 | 23.3% |
| | | ចូលរួមប្រជុំ | 38 | 28.6% |
| | | ហៅទូរសព្ទ | 75 | 56.4% |
| | | ពេលមានការអញ្ជើញ | 42 | 31.6% |
| | | ផ្សេងៗ | 10 | 7.5% |

| | | | | |
|---|---|---|---|---|
| ២ | សហគមន៍ចូលរួមក្នុងសកម្មភាពសាលា | ចូលរួមប្រជុំ | 73 | 54.9% |
| | | ណែនាំសាលាអំពីសកម្មភាព/ផែនការដាក់លាក់ | 6 | 4.5% |
| | | ធ្វើការសម្រេចចិត្តលើសកម្មភាពរបស់សាលា | 13 | 9.8% |
| | | ចូលរួមចំណែកថវិកា សម្ភារៈ កម្លាំងពលកម្ម... | 75 | 56.4% |
| | | ផ្សេងៗ | 13 | 9.8% |
| ៣ | បានទៅសាលារៀនញឹកញាប់ | មាតាបិតាសិស្ស | 56 | 42.1% |
| | | អាជ្ញាធរ | 4 | 3.0% |
| | | NGOs | 38 | 28.6% |
| | | SSCs | 79 | 59.4% |
| | | ផ្សេងៗ | 2 | 1.5% |
| ៤ | ការចូលរួមថែរក្សាទ្រព្យសម្បត្តិរបស់សាលារៀន | ចាត់ទុកទ្រព្យសម្បត្តិសាលាជាសម្បត្តិរួម | 80 | 60.2% |
| | | ជួសជុល | 17 | 12.8% |
| | | យាម | 24 | 18% |
| | | ជួយថែរក្សានិងការពារមាន | 72 | 54.1% |
| | | ផ្សេងៗ | 7 | 5.3% |
| ៥ | ចូលរួមក្នុងសកម្មភាពរបស់សាលារៀន | ចូលរួមកិច្ចប្រជុំជាមួយសហគមន៍ | 57 | 42.9% |
| | | ណែនាំអំពីសកម្មភាព/ផែនការសាលា | 32 | 24.1% |
| | | ធ្វើការសម្រេចចិត្តលើសកម្មភាពរបស់សាលា | 13 | 9.8% |
| | | ផ្សព្វផ្សាយព័ត៌មានអប់រំ | 31 | 23.3% |
| | | ផ្តល់ព័ត៌មានអំពីការសិក្សារបស់សិស្ស | 61 | 45.9% |
| | | ផ្សេងៗ | 3 | 2.3% |
| ៦ | សកម្មភាពក្រៅសាលាដែលជួយឱ្យសិស្សក្លាយជាពលរដ្ឋល្អ | បង្រៀនកុមារ | 83 | 62.4% |
| | | បង្រៀនរបាំចម្រៀងភ្លេងនិងសម្តែង(ក្លឹបវប្បធម៌សិល្បៈ) | 10 | 7.5% |
| | | បង្រៀនកីឡាដល់កុមារ(ក្លឹបកីឡា) | 23 | 17.3% |
| | | បំផុសគំនិតឱ្យកុមារចូលចិត្តចិត្តហាត់ប្រាណលេងកីឡា | 60 | 45.1% |
| | | ផ្សេងៗ | 11 | 8.3% |
| ៧ | ហេតុផលក្នុងការទំនាក់ទំនងជាមួយ | ផ្តល់ព័ត៌មាន | 54 | 40.6% |
| | | វាយតម្លៃការសិក្សារបស់សិស្ស | 28 | 21.1% |
| | | សហការ | 29 | 21.8% |

| | | | | |
|---|---|---|---|---|
| | ឪពុកម្តាយរបស់សិស្ស | តាមដានការសិក្សានៅផ្ទះរបស់សិស្ស | 87 | 65.4% |
| | | ផ្សេងៗ | 2 | 1.5% |
| ៨ | ចូលរួមជាមួយសហគមន៍ស្វែងរកថវិកាសម្រាប់ឧបត្ថម្ភដល់សាលារៀនដោយវិធី | បុណ្យផ្កា | 37 | 27.8% |
| | | បុណ្យកឋិន | 8 | 6.0% |
| | | បុណ្យសាលា | 81 | 60.9% |
| | | បុណ្យអង្គាសបច្ច័យ | 12 | 9.0% |
| | | ផ្សេងៗ | 29 | 21.8% |

តារាង៤.២.៣.១ ខាងលើបានបង្ហាញពីទម្រង់នៃការចូលរួមរបស់គ្រូបង្រៀនក្នុងការអប់រំដែលទទួលបានលទ្ធផលនៃការវិភាគក្នុងសូចនាករនីមួយៗធៀបជាមួយនឹងចំនួនសំណាកសរុប១៣៣នាក់គឺះ អ្នកស្រាវជ្រាវបានកំណត់ទម្រង់នៃទម្រង់នៃការចូលរួមរបស់គ្រូបង្រៀនជាបីប្រភេទ ដើម្បីងាយស្រួលក្នុងការវិភាគ គឺះ ប្រភេទទម្រង់ចូលរួមទី១គឺ ការចូលរួមនៅតាមសាលារៀន ដោយផ្តុំ (សូចនាករទី១,ទី៣ និងទី៨) ប្រភេទទម្រង់ចូលរួមទី២គឺ ការចូលរួមឧបត្ថម្ភដល់សាលារៀនដោយផ្តុំ (សូចនាករទី២ និងទី៥ ) និង ប្រភេទទម្រង់ចូលរួមទី៣គឺ ការចូលរួមសកម្មភាពអប់រំនៅផ្ទះ ដោយផ្តុំ (សូចនាករទី៦ និង ទី៧ )។

**ប្រភេទទម្រង់ចូលរួម ទី១៖ ការចូលរួមនៅតាមសាលារៀន**

ទម្រង់នៃការចូលរួមនៅតាមសាលារបស់គ្រូបង្រៀនមានប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយ និងសមាជិកសហគមន៍ដោយជួបនៅផ្ទះមាន៣១នាក់ ស្មើនឹង២៣.៣% ការចូលរួមប្រជុំមានចំនួន៣៨នាក់ស្មើនឹង២៨.៦% ការហៅទូរសព្ទមានចំនួន៧៥នាក់ស្មើនឹង៥៦.៤% និងផ្សេងៗមា១០នាក់ស្មើនឹង៧.៥% ការចូលរួមប្រជុំជាមួយសហគមន៍មានចំនួន ៧៣នាក់ស្មើនឹង៥៤.៩% ការចូលរួមក្នុងសកម្មភាព/ផែនការរបស់សាលាមាន០៦នាក់ស្មើនឹង៤.៥% ការសម្រេចចិត្តលើសកម្មភាពរបស់សាលាមាន១៣នាក់ស្មើនឹង៩.៨%។ គ្រូបង្រៀនទាក់ទងជាមួយអ្នកដែលបានទៅសាលារៀនញឹកញាប់គឺ មាតាបិតាសិស្សមានចំនួ៥៦នាក់ ស្មើនឹង៤២.១% អាជ្ញាធរមាន០៤នាក់ ស្មើនឹង៣% អង្គការក្រៅរដ្ឋាភិបាលមានចំនួន៣៨នាក់២៨.៦% គណៈកម្មការទ្រទ្រង់សាលាមានចំនួន៧៩ នាក់ស្មើនឹង៥៩.៤% និងផ្សេងៗមានចំនួន

០២នាក់ ស្មើនឹង១.៥%។ ចូលរួមជាមួយសហគមន៍ស្វែងរកថវិកាសម្រាប់សាលាតាមរយៈកម្មពិធីបុណ្យផ្កាមានចំនួន៣៧នាក់ ស្មើនឹង២៧.៨% បុណ្យកឋិនមានចចំនួន០៨នាក់ ស្មើនឹង៦% បុណ្យសាលាមានចំនួន៨១នាក់ ស្មើនឹង៦០.៩% បុណ្យអង្គាសបច្ច័យមានចំនួន១២នាក់ ស្មើនឹង៩% និងផ្សេងៗមានចំនួន២៩នាក់ ស្មើនឹង២១.៨%។ តាមទិន្នន័យខាងលើបង្ហាញថាប្រភេទទម្រង់នៃការចូលរួមនៅតាមសាលារៀនរបស់គ្រូ គឺមានភាគរយប្រហាក់ប្រហែលគ្នាដែលក្នុងនោះ ការហៅទូរសព្ទមាន៥៦.៤% ការចូលរួមប្រជុំជាមួយសហគមន៍មាន៥៤.៩% គណៈកម្មការទ្រទ្រង់សាលាមាន៥៩.៤% បុណ្យសាលា ៦០.៩%។




*រូបភាពប្រភេទទម្រង់ចូលរួមទី១៖ ក្រាបទម្រង់នៃការចូលរួមនៅតាមសាលារបស់គ្រូបង្រៀន*

**ប្រភេទទម្រង់ចូលរួម ទី២៖ ការចូលរួមឧបត្ថម្ភដល់សាលារបស់គ្រូបង្រៀន**

ការចូលរួមឧបត្ថម្ភដល់សាលារៀនមានការចូលរួមចំណែកថវិកា សម្ភារៈ កម្លាំងពលកម្មមានចំនួន៧៥នាក់ ស្មើនឹង៥៦.៤% ការចូលរួមក្នុងសកម្មភាពបង្រៀនមាន១៣នាក់ស្មើនឹង៩.៨% និងផ្សេងៗមាន០៥នាក់ ស្មើនឹង៣.៨%។ ការចូលរួមក្នុងសកម្មភាពរបស់សាលារៀនជាមួយសហគមន៍មានចំនួន៥៧នាក់ ស្មើនឹង៤២.៩% ការណែនាំអំពីសកម្មភាព/ផែនការសាលាមានចំនួន ៣២នាក់ ស្មើនឹង២៤.១% ការធ្វើការសម្រេចចិត្តលើសកម្មភាពរបស់សាលាមានចំនួន១៣នាក់ ស្មើនឹង៩.៨% ផ្សព្វផ្សាយព័ត៌មានអប់រំមានចំនួន៣១នាក់ស្មើនឹង២៣.៣% ផ្តល់ព័ត៌មានអំពីការសិក្សារបស់សិស្សមា៦១នាក់ ស្មើនឹង ៤៥.៩% និងផ្សេងៗមាន០៣នាក់ស្មើនឹង២.៣% ។ ការចូលរួមថែរក្សាទ្រព្យសម្បត្តិរបស់សាលារៀនដោយចាត់ទុកទ្រព្យសម្បត្តិសាលាជាសម្បត្តិរួមមានចំនួន៨០នាក់ ស្មើនឹង៦០.២% ជួសជុលមាន១៧នាក់ស្មើនឹង

១២.៨% យាមមានចំនួន២៤នាក់ ស្មើនឹង១៨% ជួយថែរក្សានិងការពារមានចំនួន៧២នាក់ ស្មើនឹង ៥៤.១% និងផ្សេងៗមានចំនួន០៧នាក់ស្មើនឹង៥.៣%។ តាមលទ្ធផលវិភាគខាងលើបង្ហាញថាទម្រង់នៃការចូលរួមឧបត្ថម្ភដល់សាលារៀនរបស់គ្រូបង្រៀន សូចនាករដែលមានភាគរយខ្ពស់មិនសូវខុសគ្នាខ្លាំងទេ ដោយការចូលរួមចំណែកថវិកា សម្ភារៈ កម្លាំងពលកម្មមាន៥៦.៤% ការចូលរួមថែរក្សាទ្រព្យសម្បត្តិរបស់សាលារៀនដោយចាត់ទុកទ្រព្យសម្បត្តិសាលាជាសម្បត្តិរួមមាន៦០.២% ការចូលរួមក្នុងសកម្មភាពរបស់សាលារៀនជាមួយសហគមន៍មាន៤២.៩%។




*រូបភាពប្រភេទទម្រង់ចូលរួម ទី២៖ ក្រាបទម្រង់នៃការចូលរួមឧបត្ថម្ភដល់សាលារបស់គ្រូបង្រៀន*

**ប្រភេទទម្រង់ចូលរួម ទី៣៖ ការចូលរួមសកម្មភាពអប់រំនៅផ្ទះរបស់គ្រូ**

ទម្រង់នៃការចូលរួមសកម្មភាពនៅផ្ទះរបស់គ្រូបង្រៀនមានសកម្មភាពក្រៅសាលាដែលជួយឱ្យសិស្សក្លាយជាពលរដ្ឋល្អដោយបង្រៀនកុមារមាន៨៣នាក់ ស្មើនឹង៦២.៤% បង្រៀនរបាំចម្រៀងភ្លេងនិងសម្តែង(ក្លឹបវប្បធម៌សិល្បៈ) មាន១០នាក់ ស្មើនឹង៧.៥% បង្រៀនកីឡាដល់កុមារ(ក្លឹបកីឡា)មាន២៣នាក់ស្មើនឹង១៧.៣% បំផុសគំនិតឱ្យកុមារចូលចិត្តចិត្តហាត់ប្រាណលេងកីឡាមាន៦០នាក់ ៤៥.១% និងផ្សេងៗ ១១នាក់ ស្មើនឹង៨.៣% ។ គ្រូបង្រៀនទំនាក់ទំនងជាមួយមាតាបិតាសិស្សដើម្បី ផ្តល់ព័ត៌មានមានចំនួន៥៤នាក់ ស្មើនឹង៤០.៦% វាយតម្លៃការសិក្សារបស់សិស្សមានចំនួ២៨នាក់ ស្មើនឹង ២១.១% សហការគ្នា មានចំនួន២៩នាក់ស្មើនឹង២១.៨% តាមដានការសិក្សានៅផ្ទះរបស់សិស្សមានចំនួន៨៧នាក់ ស្មើនឹង៦៥.៤% និងផ្សេងៗមានចំនួន២នាក់ ស្មើនឹង១.៥%។ តាមលទ្ធផលបានបង្ហាញថា ទម្រង់នៃការចូល

រួមសកម្មភាពអប់រំនៅផ្ទះរបស់គ្រូចំពោះសូចនាករដែលមានភាគរយច្រើនជាងគេគឺ តាមដានការសិក្សានៅផ្ទះរបស់សិស្សមានចំនួន៦៥.៤%  និងសូចនាករដែលទទួលបានភាគរយច្រើនបន្ទាប់គឺ  សកម្មភាពក្រៅសាលាដែលជួយបង្រៀនឱ្យសិស្សក្លាយជាពលរដ្ឋល្អ មា៦២.៤%។




*រូបភាពប្រភេទទម្រង់ចូលរួមទី៣៖ ក្រាបការចូលរួមសកម្មភាពអប់រំនៅផ្ទះរបស់គ្រូ*

ដូចនេះនាយកសាលា លោកគ្រូ អ្នកគ្រូ ឪពុកម្តាយ (ឬមីង និងពូ ជីដូនជីតា) សិស្សានុសិស្ស និងសមាជិក  គណៈកម្មការគ្រប់គ្រងសាលារៀនបានចូលរួមក្នុងសាលាដោយជួបជាមួយគ្រូអំពីការសិក្សានៃកូនរបស់ពួកគេ។  ក្នុងករណីភាគច្រើននាយកសាលាហើយគ្រូបង្រៀនជាធម្មតាផ្តួចផ្តើមការប្រជុំដែលជាទូទៅដើម្បីពិភាក្សាអំពីបញ្ហាសាលា ដូចជាផែនការសោលារៀន  ជួសជុលអគារ របង និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត រៀបចំយុទ្ធនាការចុះឈ្មោះ  ការសម្តែងរបស់សិស្ស  និងតម្រូវការថវិកា។

### ៤.២.៣.២ ការវិភាគលម្អិតទៅលើទម្រង់ចូលរួមរបស់គ្រូបង្រៀតាមបែបបរិមាណវិស័យ

#### ទម្រង់នៃការចូលរួមរបស់គ្រូបង្រៀនក្នុងការអប់រំ

យោងតាម*នាយកសាលា  ដែលចូលរួមផ្តល់សម្ភាសន៍បានលើកឡើងថា  ពួកគាត់បានធ្វើការផ្សព្វផ្សាយដំណឹងទៅកាន់ គណៈកម្មការគ្រប់គ្រងសាលារៀន មាតាបិតាសិស្ស និង សហគមន៍អំពី តម្រូវការរបស់សាលា  និងផែនការអភិវឌ្ឍសាលា  ដើម្បីឱ្យសហគមន៍បានដឹង  និងចូលរួមកាន់តែច្រើនជាមួយសាលារៀន។ នាយក និង នាយិកា ទាំងប្រាំបានលើកឡើងថា៖*

*«...ផ្សព្វផ្សាយផែនការអភិវឌ្ឍសាលារៀន តម្រូវការរបស់សាលា ទំនាក់ទំនងល្អជាមួយសហគមន៍ ធ្វើអ្វីដែលសហគមន៍បានឧបត្ថម្ភឱ្យចេញជាលទ្ធផល»*

*«...ប្រជុំជាមួយគណៈកម្មការទ្រទ្រង់សាលាអំពីផែនការរបស់សាលារៀន និងបញ្ហាប្រឈម ផ្សព្វផ្សាយផែនការអភិវឌ្ឍសាលារៀនតាមរយៈសិស្ស ពេលបើកបវេសនកាល និងពេលបើកប្រាក់អាហារូបករណ៍ ព្រមទាំងអំពាវនាវសប្បុរសជនពេលមានបុណ្យទាននៅក្នុងសហគមន៍។»* (Principal#1,2,3,4,5)

ដើម្បីឱ្យព័ត៌មានកាន់តែស៊ីជម្រៅទៅលើទម្រង់នៃការចូលរួមរបស់គ្រូក្នុងការអប់រំ គណៈកម្មការគ្រប់គ្រងសាលារៀនពីររូបបានពន្យល់បន្ថែមថា៖

*«យើងចូលរួមកិច្ចប្រជុំសាលា ដើម្បីពិភាក្សា និងស្វែងរកដំណោះស្រាយ ដើម្បីដោះស្រាយបញ្ហាដែលសាលាប្រឈម... ក៏ដូចជាការអង្គាសប្រាក់ ពីឪពុកម្តាយ និងសប្បុរសជន ផ្សព្វផ្សាយពេលមានបុណ្យ ចូលរួមជាថវិកាតាមសទ្ធា ដើម្បីជួយសាលា ព្រោះវាជាសាលារបស់យើង»* ( គ.គ.ស #2) ។

*«........យើងអំពាវនាវឪពុកម្តាយឬសប្បុរសជននៅពេលណាយើងត្រូវការប្រាក់ដើម្បីជួសជុលសាលា.....»* (Pricipal#1,2,3,4,5)។

តាមរយៈការសម្ភាសន៍ នាយកសាលាម្នាក់បានលើកឡើងបន្ថែមទៀតថា៖

*«មាតាបិតាសិស្សមកសាលាដើម្បីយជួបជាមួយ នាយកដើម្បីពិភាក្សាអំពីវិធីដែលអាចធ្វើទៅបានក្នុងការទទួលបានមូលនិធិដើម្បីជួយសាងសង់សាលាអគារថ្មី បណ្ណាល័យ តារាងបាល់ បន្ទប់ទឹកស្អាតមានស្តង់ដាមួយ សម្រាប់កុមារ»* (Pricipal#3)។

សរុបជារួមមក ទម្រង់នៃការចូលរួមរបស់គ្រូបង្រៀនមានបីប្រភេទ ដែលប្រភេទនៃការចូលរួមទី១ គឺ ប្រភេទទម្រង់ចូលរួមទី១គឺ ការចូលរួមនៅតាមសាលារៀន ប្រភេទទម្រង់ចូលរួមទី២គឺ ការចូលរួមឧបត្ថម្ភដល់សាលារៀនដោយផ្ទាល់ និង **ប្រភេទទម្រង់ចូលរួម**ទី៣គឺ ការចូលរួមសកម្មភាពអប់រំនៅផ្ទះ ។ បន្ថែមពីលើការប្រជុំ ឪពុកម្តាយនិងសមាជិកសហគមន៍

ផ្សេងទៀតចូលរួមក្នុងការប្រជុំដែលមានការអញ្ជើញដោយសាលានាយកដើម្បីពិភាក្សា អំពីស្ថានភាពរបស់សាលារៀន លទ្ធផលសិក្សារបស់សិស្ស ឬសមិទ្ធផលថ្មីៗរបស់សិស្សជាទូទៅ។

### ៤.២.៤ ការវិភាគលម្អិតទៅលើ កត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀនចូលរួមក្នុងការអប់រំ

#### ៤.២.៤.១ការវិភាគលម្អិតលើកត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀនចូលរួមក្នុងការអប់រំ តាមបែបបរិមាណវិស័យ

តារាង ៤.២.៥.១កត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀនចូលរួមក្នុងការអប់រំ

| ល.រ | ការលើកទឹកចិត្តក្នុងការចូលរួមក្នុងការអប់រំ | បរិយាយ | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | ចូលរួមថែរក្សាទ្រព្យសម្បត្តិរបស់សាលារៀន | ចាត់ទុកទ្រព្យសម្បត្តិសាលាជាសម្បត្តិរួម | 80 | 60.2% |
| | | ជួសជុល | 17 | 12.8% |
| | | យាម | 24 | 18.0% |
| | | ជួយថែរក្សានិងការពារ | 72 | 54.1% |
| | | ផ្សេងៗ | 7 | 5.3% |
| ២ | ការលើកទឹកចិត្តអ្នកក្នុងការអប់រំកុមារ | សម្រាប់ការអប់រំរបស់កុមារ | 25 | 18.8% |
| | | ដើម្បីអភិវឌ្ឍសាលារៀន | 29 | 21.8% |
| | | ដើម្បីអនាគតរបស់កូនចៅជំនាន់ក្រោយ | 105 | 78.9% |
| | | ដើម្បីកាត់បន្ថយអនាធិបតេយ្យ | 16 | 12.0% |
| | | ផ្សេងៗ | 2 | 1.5% |
| ៣ | ដើម្បីឱ្យមាតាបិតាសិស្សមានទំនាក់ទំនងល្អជាមួយសាលាក្នុងការអប់រំ | មានអភិបាលកិច្ចល្អ(តម្លាភាព ទំនួលខុសត្រូវ ប្រសិទ្ធិភាព និងការចូលរួម) | 116 | 87.2% |
| | | មានវិមជ្ឈការក្នុងសាលារៀន | 19 | 14.3% |
| | | ផ្តល់ផលប្រយោជន៍គ្នាទៅវិញទៅមក | 23 | 17.3% |
| | | មានប្រជាធិបតេយ្យ | 9 | 6.8% |
| ៤ | ការផ្លាស់ប្តូរដែលបានកើតឡើងជាលទ្ធផលនៃការចូលរួមរបស់សហគមន៍ | ការអប់រំមានភាពប្រសើរឡើង | 67 | 50.4% |
| | | សហគមន៍មានការអភិវឌ្ឍ | 28 | 21.1% |
| | | កូនចៅបានសិក្សារៀនសូត្រគ្រប់គ្នា | 76 | 57.1% |
| | | ពលរដ្ឋមានការងារល្អ | 17 | 12.8% |

| | | | | |
|---|---|---|---|---|
| | | ផ្សេងៗ | 5 | 3.8% |
| ៥ | បានទទួលនូវមូលដ្ឋានសម្ភារៈដើម្បីបម្រើឱ្យការរៀននិងបង្រៀនពីសហគមន៍ | សម្ភារៈពិសោធន៍ | 24 | 18.0% |
| | | សម្ភារៈសម្រាប់សិក្សា | 91 | 68.4% |
| | | សម្ភារៈសម្រាប់ឧបទ្ទេស | 15 | 11.3% |
| | | ផ្សេងៗ | 34 | 25.6% |

តារាង**៤.២.៤.១** ខាងលើបានបង្ហាញពីការលើកទឹកចិត្តក្នុងការចូលរួមរបស់គ្រូបង្រៀនក្នុងការអប់រំដែលទទួលបានលទ្ធផលនៃការវិភាគក្នុងសូចនាករនីមួយៗធៀបជាមួយនឹងចំនួនសំណាកសរុប ១៣៣នាក់ អ្នកស្រាវជ្រាវបានកំណត់កត្តាជំរុញលើកទឹកចិត្តនៃការចូលរួមរបស់គ្រូបង្រៀនជាពីរកត្តាដើម្បីងាយស្រួលក្នុងការវិភាគ គឺៈ (១)កត្តាជំរុញលើកទឹកចិត្តពីខាងក្នុង (សូចនាករទី១ និងទី២) និងកត្តាជំរុញលើកទឹកចិត្តពីខាងក្រៅ ដោយផ្តុំសូចនាករទី៣ រហូតដល់ សូចនាករទី៥។

**(១)កត្តាជំរុញលើកទឹកចិត្តពីខាងក្នុង**

កត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀនដោយមានហេតុផលក្នុងការសម្រេចចិត្តចូលរួមគឺសម្រាប់ការអប់រំរបស់កុមារមានចំនួន៥៥នាក់ ស្មើនឹង៤១.៤% ដើម្បីអនាគតរបស់កូនចៅមានចំនួន ៦៥នាក់ ស្មើនឹង ៤៨.៩% ដើម្បីអភិវឌ្ឍសាលារៀន៦៦នាក់ស្មើនឹង៤៩.៦% ដើម្បីកាត់បន្ថយអនាធិបតេយ្យមាន៥នាក់ស្មើនឹង ៣.៨% និងផ្សេងៗមាន២នាក់ស្មើនឹង១.៥%។ កត្តាជំរុញលើកទឹកចិត្តដើម្បីការអប់រំកុមារគឺសម្រាប់ការសិក្សារបស់កុមារមានចំនួន ២៥នាក់ ស្មើនឹង១៨.៨% ដើម្បីផែនការអភិវឌ្ឍសាលារៀនមាន ២៩នាក់ ស្មើនឹង២១.៨% ដើម្បីអនាគតរបស់កូនចៅជំនាន់ក្រោយមានចំនួន១០៥នាក់ ស្មើនឹង៧៨.៩% ដើម្បីកាត់បន្ថយអនាធិបតេយ្យមាន១៦នាក់ ស្មើនឹង១២% និងផ្សេងៗមាន០២នាក់ ស្មើនឹង១.៥% ។ តាមលទ្ធផលបានបង្ហាញថាកត្តាដែលជំរុញលើកទឹកចិត្តគ្រូបង្រៀនពីខាងក្នុង ដែលសូចនាករទទួលបានភាគរយច្រើនជាងគេគឺ ដើម្បីអនាគតរបស់កូនចៅជំនាន់ក្រោយមានចំនួន ៧៨.៩% និង សូចនាករដែលទទួលបានភាគរយច្រើនបន្ទាប់គឺដើម្បីអភិវឌ្ឍសាលារៀនមានចំនួន៤៩.៦% និងដើម្បីអនាគតរបស់កូនចៅមានចំនួន ៤៨.៩%។

(២)កត្តាជំរុញលើកទឹកចិត្តពីខាងក្រៅ

**កត្តាដែលជំរុញលើកទឹកចិត្តគ្រូបង្រៀនពីខាងក្រៅ**មានកត្តាដែលធ្វើឱ្យមាតាបិតាសិស្សមានទំនាក់ទំនងល្អជាមួយសាលាក្នុងការអប់រំគឺមានអភិបាលកិច្ចល្អ(តម្លាភាព ទំនួលខុសត្រូវ ប្រសិទ្ធិភាព និងការចូលរួម) មានចំនួន១១៦នាក់ ស្មើនឹង៨៧.២% មានវិមជ្ឈការក្នុងសាលារៀនមាន១៩នាក់ ស្មើនឹង១៤.៣% ផ្តល់ផលប្រយោជន៍គ្នាទៅវិញទៅមកមាន២៣នាក់ ស្មើនឹង១៧.៣% មានប្រជាធិបតេយ្យមាន៩នាក់ ស្មើនឹង៦.៨%។ ការផ្លាស់ប្តូរដែលបានកើតឡើងជាលទ្ធផលនៃការចូលរួមរបស់សហគមន៍គឺការអប់រំមានភាពប្រសើរឡើងមាន៦៧នាក់ ស្មើនឹង៥០.៤% សហគមន៍មានការអភិវឌ្ឍមាន២៨នាក់ ស្មើនឹង២១.១% កូនចៅបានសិក្សារៀនសូត្រគ្រប់គ្នាមានចំនួន៧៦នាក់ ស្មើនឹង៥៧.១% ពលរដ្ឋមានការងារល្អមាន១៧នាក់ ស្មើនឹង១២.៨% និងផ្សេងៗមាន០៥នាក់ ស្មើនឹង៣.៨%។ ការទទួលនូវមូលដ្ឋានសម្ភារៈដើម្បីបម្រើឱ្យការរៀននិងបង្រៀនពីសហគមន៍គឺសម្ភារៈសម្រាប់ផលិតមាន២៤នាក់ ស្មើនឹង១៨% សម្ភារៈសម្រាប់សិក្សាមានចំនួន៩១នាក់ ស្មើនឹង៦៨.៤% សម្ភារៈសម្រាប់ពិសោធមាន១៥នាក់ ស្មើនឹង១១.៣% សម្ភារៈសម្រាប់ឧបទ្ទេសមានចំនួន៣៤នាក់ ស្មើនឹង២៥.៦% និងផ្សេងៗមានចំនួន០៨នាក់ ស្មើនឹង៦%។ តាមលទ្ធផលបានបង្ហាញថាកត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀនពីខាងក្រៅដែលមានភាគរយខ្ពស់ជាងគេគឺមានអភិបាលកិច្ចល្អ(តម្លាភាព ទំនួលខុសត្រូវ ប្រសិទ្ធិភាព និងការចូលរួម) មានចំនួន៨៧.២% សម្ភារៈសម្រាប់សិក្សាមាន៦៨.៤% កូនចៅបានសិក្សារៀនសូត្រគ្រប់គ្នាមានចំនួន៥៧.១%។

ដូចនេះលទ្ធផលវាយតម្លៃបង្ហាញបានថាគ្រូបង្រៀនការប្រាស្រ័យទាក់ទងគ្នា ការរៀននៅផ្ទះរបស់កុមារ ការសម្រេចចិត្ត និងការសហការគ្នាជាមួយសហគមន៍។ លើសពីនេះ ទម្រង់នៃការចូលរួមមួយទៀតគឺការរួមចំណែករបស់សហគមន៍ ដែលជាទូទៅបានកើតឡើងនៅក្នុងតំបន់ស្រាវជ្រាវគឺ ការបរិច្ចាគនេះរួមមានថវិកា សម្ភារៈ និងកម្លាំងពលកម្មសម្រាប់ ការអភិវឌ្ឍន៍សាលារៀន ហើយវាត្រូវបានចាត់ថ្នាក់ថាជាកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ និងមាតាបិតាសិស្ស ហើយគ្រូបង្រៀនចូលរួមក្នុងសកម្មភាពសាលាដោយចូលរួមប្រជុំ ការងារ ដែលជាតម្រូវការរបស់សាលា ។

ដើម្បីកាន់តែងាយយល់ និងសម្គាល់ ក្រាប **៤.២.៤.១**ខាងក្រោមបង្ហាញបន្ថែមអំពីកត្តាជំរុញលើកទឹកចិត្តមាតាបិតាសិស្សចូលរួមក្នុងការអប់រំ




*រូបភាព ៤.២.៤.១៖ ក្រាបកត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀនចូលរួមក្នុងការអប់រំ*

### ៤.២.៤.២ ការវិភាគលម្អិតទៅលើកត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀនចូលរួមក្នុងការអប់រំបែបគុណវិស័យ

យោងតាមរយៈការសម្ភាសន៍គណៈកម្មការគ្រប់គ្រងសាលារៀន មួយរូបបានឱ្យដឹងថា កត្តាជំរុញលើកទឹកចិត្តគ្រូបង្រៀនចូលរួមក្នុងការអប់រំ កើតឡើងក្នុងទម្រង់ផ្សេងៗ សហគមន៍ចូលរួមជាមួយសាលារៀនដោយធ្លាប់ជាសិស្សរៀននៅទីនេះ។ គណៈកម្មការគ្រប់គ្រងសាលារៀនម្នាក់បានលើកឡើងថា៖ «… *សប្បុរសជនធ្លាប់ជាសិស្សរៀននៅទីនេះ គ្រូយកចិត្តទុកដាក់ក្នុងការបង្រៀន សាលារៀនមានការអភិវឌ្ឍ មានទាំងបន្ទប់ទឹក ទឹកស្អាត»(គ.គ.ស #1)។*

*តាមរយៈព័ត៌មានដែលទទួលបានពីនាយកសាលានិងនាយិកាបានជម្រាបជូនផងដែរថា សាលារៀនមានទំនាក់ទំនងល្អជាមួយសហគមន៍ នឹងធ្វើឱ្យសហគមន៍មានទំនុកចិត្ត និងសម្រេចចិត្តចូលរួម ព្រមទាំងជួយតាមដាន វាយតម្លៃ ការអនុវត្តផែនការអភិវឌ្ឍសាលារៀនផងដែរ។ នាយកទី១,ទី២,ទី៣,ទី៤, និងទី៥ បានលើកឡើងថា៖*

*«...ខ្ញុំតែងមានទំនាក់ទំនងល្អជាមួយសហគមន៍ និងធ្វើឱ្យសហគមន៍ជឿជាក់ប្រជុំធ្វើផែនការអភិវឌ្ឍសាលា ៣ឆ្នាំ ៦ឆ្នាំ តាមដានការអនុវត្តដំណើរការសាលា កែលម្អសាលារៀន ប្រជុំវាយតម្លៃ។»*

*«...ខ្ញុំមានទំនាក់ទំនងល្អជាមួយអាជ្ញាធរ ភូមិ ឃុំ និងប្រជាពលរដ្ឋទូទៅ ធ្វើឱ្យបានសមិទ្ធិផលទាំងតូចទាំងធំ និងធ្វើយ៉ាងណាឱ្យសហគមន៍មានជំនឿទុកចិត្តមកលើសាលារៀន។ (Pricipal#1,2,3,4,5)*

ដូចនេះកត្តាដែលជំរុញលើកទឹកចិត្តឱ្យគ្រូបង្រៀនចូលរួមអប់រំកុមារព្រោះចាប់អារម្មណ៍ចង់ឃើញកុមារមានចំណេះដឹងទើបអាចធ្វើការងាបាន រួមចំណែកដល់ការអភិវឌ្ឍន៍សហគមន៍ហើយកុមារមួយចំនួនដែលបានបញ្ចប់ការសិក្សាពីសហគមន៍មានលទ្ធភាពទទួលបានការងារល្អដែលជាការរំពឹងទុករបស់ឪពុកម្តាយ។ តាមទិន្នន័យដែលទទួលបានពីការសម្ភាសន៍គណៈកម្មការគ្រប់គ្រងសាលារៀន កត្តាដែលលើកទឹកចិត្តពួកគាត់ឱ្យចូលរួមនោះគឺ៖ *«...ធ្លាប់រៀននៅទីនេះ គ្រូយកចិត្តទុកដាក់ក្នុងការបង្រៀន សាលារៀនមានការអភិវឌ្ឍ មានទាំងបន្ទប់ទឹក ទឹកស្អាត» (SSC#1)*

ហើយកត្តាសំខាន់ដែលជំរុញលើកទឹកចិត្តសហគមន៍ឱ្យចូលរួមកាន់តែច្រើនជាមួយសាលារៀន វាអាស្រ័យលើភាពជាអ្នកដឹកនាំរបស់នាយកសាលា ដែលគ្រប់គ្រងដឹកនាំប្រកបដោយតម្លាភាព មានទំនាក់ទំនងជាមួយសហគមន៍ និងធ្វើឱ្យសហគមន៍ជឿទុកចិត្ត។ តាមទិន្នន័យដែលទទួលបានការសម្ភាសន៍ជាមួយនាយកសាលាភាគច្រើនលើកឡើងថា៖

*«...មានតម្លាភាព មានទំនាក់ទំនងល្អ ធ្វើឱ្យសហគមន៍ជឿជាក់ ពង្រឹងវិន័យគ្រូ។»*

*«...សហគមន៍ចូលរួមជាមួយសាលាដោយសារអនាគតកូនចៅជំនាន់ក្រោយ មានចិត្តល្អ»*

*«...សហគមន៍ចូលរួមជាមួយសាលាដោយសារចង់ធ្វើបុណ្យសាងកុសលដើម្បីជួបសំណាងល្អក្នុងជីវិត និងដើម្បីកូនចៅជំនាន់ក្រោយ»*

ក្នុងការលើកទឹកចិត្តឱ្យសហគមន៍ចូលរួម ដោយនាយក/នាយិកាមានវិធីសាស្ត្រក្នុងការទាក់ទាញសហគមន៍។ តាមទិន្នន័យដែលទទួលបានពីការសម្ភាសន៍នាយកសាលានិងព្រះចៅអធិការវត្តភាគច្រើនលើកឡើងថា៖

> *«...ការធ្វើប័ណ្ណថ្លែងអំណរគុណ ឬបង្ហោះការថ្លែងអំណរគុណតាមផេកហ្វេសប៊ុកសាលារាល់ការជួយឧបត្ថម្ភរបស់ពួកគាត់ ពឹងពាក់លោកគ្រូអាចារ្យវត្តលបុណ្យទានពីការខ្វះខាតរបស់សាលា សហគមន៍ជួយឧបត្ថម្ភអ្វីគឺធ្វើ»*
>
> *«...មិនពិបាកទេក្នុងការគៀតសហគមន៍គឺសុំពីមាតាបិតាសិស្សដែលគាត់មកចាំទទួលសិស្សនៅសាលាសុំពួកគាត់ធ្វើអីគឺធ្វើឱ្យឃើញភ្លាម»(Pricipal#1,2,3,4,5)*
>
> *«...រក្សាទំនាក់ទំនង និងជួយសាលា និងចូលរួមជាមួយសហគមន៍ក្នុងការស្វែងរកជំនួយផ្សព្វផ្សាយយ៉ាងណាឱ្យដៃគូមានជំនឿចិត្តនិងចូលរួមជាមួយសាលា អ្វីដែលសំខាន់បំផុតគឺនាយកចេះរៀបចំចាត់ចែងថវិកាដែលសហគមន៍ចំណាយទៅហើយត្រូវចេញជាផ្លែផ្កា។» (Monk#1,2)*

យោងតាមព័ត៌មានដែលទទួលបានពីគណៈកម្មការទ្រទ្រង់សាលាម្នាក់បានពន្យល់ថា៖ *«យើងជួយអភិវឌ្ឍសាលាតាមលទ្ធភាពព្រោះយើងអត់មានលុយធ្វើអគារ ឬទិញសម្ភារៈដែលទំនើបនិងមានតម្លៃថ្លៃក៏ជួយដល់សាលា ក៏ខ្ញុំព្យាយាមទំនាក់ទំនងជាមួយអតីតសិស្សដែលមានលទ្ធភាព ឬសមាជិកសហគមន៍ដែលមានទ្រព្យឱ្យចូលរួមជួយសាលា...»* (គ.គ.ស#1,2)។ គណៈកម្មការគ្រប់គ្រងសាលារៀនបានឆ្លុះបញ្ចាំងពីគំនិតរបស់ឪពុកម្តាយជាច្រើននាក់ទៀត និង សមាជិកសហគមន៍៖ *«យើងចង់ឃើញការសាងសង់អគារសិក្សាថ្មី ដែលធ្វើយ៉ាងឆាប់រហ័សតាមអ្វីដែលនាយកសាលាបានស្នើសុំពួកគាត់ ដើម្បីឱ្យវាងាយស្រួលសម្រាប់ក្មេងតូចៗរបស់យើង បានសិក្សាក្នុងអគារដែលស្អាតមានទីធ្លាវត់លេង បរិស្ថានសាលារៀនស្អាតបរិសុទ្ធ...»* (គ.គ.ស#1,2)

### ៤.២.៥ ការវិភាគលម្អិតទៅលើឧបសគ្គនៃចូលរួមក្នុងការអប់រំ

#### ៤.២.៥.១ ការវិភាគលម្អិតទៅលើឧបសគ្គនៃចូលរួមក្នុងការអប់រំតាមបែបបរិមាណវិស័យ

**តារាងទី៤.២.៥.១៖ ឧបសគ្គនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ**

| | | មាតាបិតាសិស្ស | | គ្រូបង្រៀន | |
|---|---|---|---|---|---|
| ឧបសគ្គនៃការចូលរួម | បរិយាយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| | ជីវភាពក្រីក្រ | 11 | 39.3% | 45 | 33.8% |
| | រវល់ | 13 | 46.4% | 75 | 56.4% |
| | ផ្ទះនៅឆ្ងាយពីសាលា | 3 | 10.7% | 24 | 18.0% |
| | មិនមានចំណាប់អារម្មណ៍ | 2 | 7.1% | 17 | 12.8% |
| | ផ្សេងៗ | 3 | 10.7% | 8 | 6.0% |

តាមរយៈទិន្នន័យដែលទទួលបានបញ្ជាក់ថាគ្រួសារភាគច្រើនមានជីវភាពខ្វះខាតមានចំនួន ៣៩.៣%ហើយជាធម្មតាពួកគាត់ចាកចេញពីផ្ទះទៅធ្វើការនៅតាមរោងចក្រ កសិដ្ឋាន និងកន្លែងផ្សេងៗ ដែលទទួលបានប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារមិនគ្រប់គ្រាន់។ ចំណែកគ្រួសារដទៃទៀតមានការរវល់នឹងកិច្ចការ ប្រកបរបរចិញ្ចឹមជីវិតក្នុងនោះមានចំនួន៤៦.៤% ពួកគាត់ត្រូវចេញទៅធ្វើការតាំងពីព្រឹករហូតដល់ល្ងាចទើបត្រលប់មកវិញ។ ដោយសារចំណុចត្រង់នេះហើយទើបពួកគាត់ពុំមានពេលចូលរួមក្នុងការអប់រំ ព្រោះមកដល់ផ្ទះវិញពួកគាត់អស់កម្លាំង មិនបានបង្រៀនកូនបន្ថែមឬត្រួតពិនិត្យ តាមដានការសិក្សារបស់កូននៅផ្ទះ។

### ៤.២.៥.២ ការវិភាគលម្អិតទៅលើឧបសគ្គនៃចូលរួមក្នុងការអប់រំតាមបែបគុណវិស័យ

ទិន្នន័យដែលទទួលបានពីការសម្ភាសន៍ព្រះសង្ឃ និងនាយកសាលា ភាគច្រើនបានលើកឡើងថា ៖

*«...ការយល់ដឹងរបស់មាតាបិតាសិស្សអំពីតម្លៃនៃការសិក្សាជាពិសេសកូនស្រីរៀនយូរមិនងាយរកលុយមកផ្គត់ផ្គង់គ្រួសារ គ្រួសារមានការលំបាកមិនចង់ឱ្យកូនបន្តសិក្សាទៀត» (Monk#1)*

ម្យ៉ាងទៀតដោយសារការរវល់ទើបពួកគាត់មិនអាចចូលរួមសកម្មភាពផ្សេងៗដូចជាការចូលរួមប្រជុំ ការចូលរួមធ្វើផែកការអភិវឌ្ឍសាលានិងទំនាក់ទំនងជាមួយសាលារៀន។

*«...ពុំដែលបានប្រជុំជាមួយមាតាបិតាសិស្សព្រោះពួកគាត់រវល់ ទំនាក់ទំនងរវាងសាលានិងសហគមន៍នៅមានកម្រិត»*

*«...ឪពុកម្តាយចំណាកស្រុក ជីវភាពគ្រួសារសិស្សខ្វះខ្វះខាត ឪពុកម្តាយខ្លះអាចជួយត្រឹមជាកម្លាំងកាយកម្លាំងចិត្ត ឬជាថវិកាបន្តិចបន្តួចដោយសារសេដ្ឋកិច្ចគ្រួសារ»*

*«...ឪពុកម្តាយមួយចំនួនមិនទាន់យល់មិនជំរុញកូនឱ្យមករៀន ហើយគ្រួសារមួយចំនួនមានជីវភាពក្រីក្រ»*

*«...មានជីវភាពក្រីក្រ រវល់មិនបានចូលរួមប្រជុំ»*

*«...ដោយសារវិបត្តសេដ្ឋកិច្ចធ្វើឱ្យរោងចក្រមួយចំនួនត្រូវបិទទ្វារទើបមាតាបិតាសិស្សរបស់សិស្សមួយចំនួនត្រូវបាត់ចំណូលទើបមិនអាចចូលរួម...»។*

*(Principal#1,2,3,4,5)*

ទោះបីជានាយកសាលានិងគណៈកម្មការទ្រទ្រង់សាលាបានពណ៌នាអំពីការរួមចំណែកត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្តបែបនេះក៏ដោយ ក៏បង្កឧបសគ្គសម្រាប់ការចូលរួមរបស់សមាជិកសហគមន៍ដែលអាចរកប្រាក់ចំណូលបានតិចក្នុងមួយថ្ងៃ បើទោះបីជាពួកគេមានឆន្ទៈជួយសាលាក៏ដោយ។ នេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការឆ្លើយតបពីក្រុមSSCដូចដែលពួកគេភាគច្រើនបានពន្យល់ថា៖ *«...ឪពុកម្តាយខ្លះមិនអាចចូលរួមចំណែកជាថវិកាដើម្បីជួយសាលាដោយសារពួកគេមានជីវភាពក្រីក្រនិងដោយសារសេដ្ឋកិច្ចធ្លាក់ចុះ រោងចក្រមួយចំនួនបានបិទទ្វារ»* (Pricipal#3)។

គណៈកម្មការគ្រប់គ្រងសាលារៀនម្នាក់បានបន្ថែមថាក្រុមឪពុកម្តាយ បានបរិច្ចាគថវិកាដល់សាលាទៅតាមចំនួនដែលពួកគេអាចរកបាន។ យោងតាមព័ត៌មានដែលផ្តល់ដោយនាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀន និងព្រះសង្ឃ បានឱ្យដឹងថាមាតាបិតាសិស្សមួយចំនួនមិនបានចូលរួមក្នុងការអប់រំដោយសារកត្តាជីវភាព និងមានការរវល់ ហើយពួកគាត់ដទៃទៀតខ្វះមធ្យោបាយធ្វើដំណើរ ព្រមទាំង

គ្រួសារមានតែចាស់ជរាជាដើម *«...មានជីវភាពក្រីក្រ រវល់ គ្រួសារមានសមាជិកចាស់ជរា និងខ្វះមធ្យោបាយធ្វើដំណើរ»(គ.គ.ស#1)*

ដូចនេះវាពិបាកក្នុងការទទួលបានឪពុកម្តាយ និងសហគមន៍ដែលរស់នៅឆ្ងាយពីសាលារៀន ដើម្បីចូលរួមក្នុងសាលារៀន (បញ្ហានៃការទំនាក់ទំនង) ស្ថានភាពរស់នៅក្រីក្ររបស់ឪពុកម្តាយធ្វើឱ្យកុមារមករៀនមិនទៀងទាត់ អវត្តមានច្រើន និងនាំឱ្យពួកគេឈប់រៀន។ ទោះបីជាឪពុកម្តាយ យល់ថាការអប់រំមានសារៈសំខាន់សម្រាប់កូនៗរបស់ពួកគេក៏ដោយនៅតែពិបាកទាក់ទងឪពុកម្តាយ ដោយសារបណ្តាញខ្សោយ និងផ្លូវមិនល្អលក្ខខណ្ឌដើម្បីទៅដល់ផ្ទះរបស់សិស្ស។ គ្រួសារធ្វើចំណាកស្រុកញឹកញាប់ (ឪពុកម្តាយតែងតែនាំកូនមកជាមួយ នៅពេលដែលពួកគេផ្លាស់ទី) ពិបាកក្នុងការទំនាក់ទំនងតាមរយៈកំណត់ត្រាសិក្សារបស់សិស្សសម្រាប់ឪពុកម្តាយមិនចេះអក្សរជាដើម។

## ៤.៣. ទស្សនៈយល់ឃើញរបស់ក្រុមអ្នកចូលរួមអំពីការចូលរួមរបស់សហគមន៍ក្នុងការអប់រំ

ការស្រាវជ្រាវនេះគឺផ្អែកលើ ការយល់ដឹងផ្សេងៗគ្នានៃអ្នកចូលរួមស្រាវជ្រាវឈ្វេងយល់អំពីការចូលរួមរបស់សហគមន៍នៅក្នុងការអប់រំ។ ក្រុមអ្នកចូលរួមក្នុងការស្រាវជ្រាវទាំងនេះជួយក្នុងការស្វែងយល់ពីរបៀបដែលប្រជាជនក្នុងតំបន់បង្កើនការយល់ដឹងរបស់ពួកគេអំពីការចូលរួមក្នុងការអប់រំ។ ការបកស្រាយពន្យល់ថា៖

ទិន្នន័យបានពីការសម្ភាសន៍ និងកម្រងសំណួរបង្ហាញថា ក្រុមអ្នកចូលរួមនីមួយៗមានការយល់ឃើញផ្សេងៗគ្នាអំពីការចូលរួមរបស់សហគមន៍ក្នុងការអប់រំ។ ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធផ្នែកអប់រំនៅក្នុងការស្រាវជ្រាវនេះ គឺជាចំណុចសំខាន់ក្នុងការឆ្លើយនឹងសំណួរស្រាវជ្រាវព្រោះវាមានសារៈសំខាន់ក្នុងការកំណត់អត្តសញ្ញាណមនុស្សពាក់ព័ន្ធ ស្ថាប័នពាក់ព័ន្ធនឹងសាលារៀន និងការអប់រំ។ ពាក្យ «អ្នកពាក់ព័ន្ធផ្នែកអប់រំ» សំដៅលើប្រជាពលរដ្ឋ ស្ថាប័ន ឬអង្គការនានាដែលចូលរួមក្នុងទម្រង់ផ្សេងៗក្នុងវិស័យអប់រំ។ ទិន្នន័យដែលបានមកពីបទសម្ភាសន៍ នាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀន និងព្រះចៅអធិការវត្តគឺស្របគ្នានឹងទិន្នន័យបានពីការឆ្លើយតបក្នុងកម្រងសំណួរ មាតាបិតាសិស្ស និងគ្រូ

បង្រៀនដែលបានចូលរួមជាញឹកញាប់ក្នុងការអប់រំ។ ភាគីពាក់ព័ន្ធនៃការអប់រំដទៃទៀតត្រូវបានរាយការណ៍ថាមានការចូលរួមម្តងម្កាល។ អ្នកពាក់ព័ន្ធផ្នែកអប់រំនីមួយៗដែលបានចូលរួមនៅក្នុងសាលា និងការអប់រំដោយទម្រង់ខុសៗគ្នាដែលត្រូវបានពន្យល់បន្ថែមនៅពេលក្រោយនៅក្នុងជំពូកនេះ។

**តារាង៤.៣៖ ទស្សនៈរបស់អ្នកចូលរួមស្តីពីការចូលរួមសហគមន៍ក្នុងវិស័យអប់រំ**

| អ្នកចូលរួម | ទស្សនៈយល់ឃើញចំពោះការចូលរួមរបស់សហគមន៍ក្នុងការអប់រំ |
|---|---|
| នាយកសាលា | ការចូលរួមរបស់សហគមន៍ក្នុងការអប់រំ គឺជាដំណើរការមួយដែលពាក់ព័ន្ធនឹងឪពុកម្តាយ អាជ្ញាធរ និងអ្នកពាក់ព័ន្ធក្នុងវិស័យអប់រំ។ ការចូលរួមនេះកើតឡើងនៅក្នុងទម្រង់នៃគំនិត ប្រាក់ សម្ភារៈ និងការរួមចំណែកកម្លាំងពលកម្មសម្រាប់ការអភិវឌ្ឍន៍សាលារៀន។ |
| គ្រូបង្រៀន | ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ គឺជាការចូលរួមក្នុងការទទួលបានការអប់រំ ព័ត៌មានពីសាលារៀន និងការផ្សព្វផ្សាយនៅក្នុងសហគមន៍។សហគមន៍ ចូលរួមតាមរយៈការបញ្ជូនកូនរបស់ពួកគេទៅសាលារៀន និងការរួមចំណែកគំនិត លុយកាក់ និងសម្ភារៈនៅពេលណាដែលសាលាសុំជំនួយ។ |
| មាតាបិតាសិស្ស | ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ គឺជាការរួមចំណែកជាថវិកា សម្ភារៈកម្លាំងពលកម្ម និងគំនិតសម្រាប់ការកែលម្អសាលារៀន ដូចជាការសាងសង់សាលារៀន និងបញ្ជូនកុមារទៅសាលារៀន និងជួយកុមារឱ្យរៀននៅផ្ទះ |
| គណៈកម្មការគ្រប់គ្រងសាលារៀន | ការចូលរួមរបស់សហគមន៍ក្នុងការអប់រំ គឺជាដំណើរការនៃការទទួល និងការផ្សព្វផ្សាយព័ត៌មានអប់រំក្នុងសហគមន៍។ វាគឺជាដំណើរការនៃការប្រមូលធនធាន នៅក្នុងសហគមន៍សម្រាប់ការកែលម្អសាលារៀន។ ការចូលរួមរបស់មាតាបិតាសិស្សនិងសហគមន៍ក្នុងការអប់រំគឺជាការរួមចំណែកជាថវិកា សម្ភារៈ កម្លាំងពលកម្ម និងគំនិតសម្រាប់ការកែលម្អសាលារៀន ដូចជាការសាងសង់សាលារៀន និង បញ្ជូនកុមារទៅសាលារៀន និងជួយកុមារឱ្យរៀននៅផ្ទះ។ |
| អាជ្ញាធរមូលដ្ឋាន | ការចូលរួមរបស់សហគមន៍ក្នុងការអប់រំ គឺជាការចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មានអប់រំ និងតម្លៃនៃការអប់រំដល់អាជ្ញាធរមូលដ្ឋាន និងសហគមន៍តាមលំដាប់លំដោយ ដើម្បីឱ្យកុមារទទួលបានការអប់រំ។ សហគមន៍ចូលរួមតាមរយៈធនធាន ការរួមចំណែកដូចជាប្រាក់ និងកម្លាំងពលកម្មសម្រាប់ការអភិវឌ្ឍសាលារៀន និងការអប់រំ។ |
| ព្រះចៅអធិការ វត្ត | ការចូលរួមរបស់សហគមន៍ក្នុងការអប់រំ គឺជាការចូលរួមក្នុងការពិភាក្សាទៅ កំណត់ចំណុចកែលម្អរបស់សាលាសម្រាប់ការកែលម្អការរៀនសូត្ររបស់កុមារ។ |

## ៤.៤ ការសហការខាងសហគមន៍ជាមួយសាលារៀន

ទម្រង់នៃការចូលរួមនេះគឺទាក់ទងនឹងការសហការគ្នារបស់សាលាជាមួយភ្នាក់ងារនានា អាជីវកម្ម អង្គការ និងក្រុមផ្សេងទៀតដើម្បីចែករំលែកការទទួលខុសត្រូវសម្រាប់ការកែលម្អសាលារៀននិងការអប់រំ (Epstein, 1995) ។ ការសិក្សាបានរកឃើញអ្នកពាក់ព័ន្ធផ្នែកអប់រំផ្សេងៗគ្នា ចូលរួមក្នុងវិស័យអប់រំ និងការអភិវឌ្ឍសាលាតាមរយៈការងារសហការជាមួយ ភាគីពាក់ព័ន្ធនីមួយៗ ដែលចូលរួមក្នុងការអប់រំដោយផ្ទាល់ ឬដោយប្រយោល ឬទាំងពីរ។សកម្មភាពសហការ រវាងសាលារៀន និងសហគមន៍ត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម៖

**តារាង៤.៤.៦ការសហការរបស់សហគមន៍សម្រាប់ការអប់រំ**

| **អ្នកចូលរួម** | **បរិយាយ** | **ប្រភពព័ត៌មាន** |
|---|---|---|
| **១.**គម្រោចសាងសង់៖សាលានីមួយៗមានគម្រោងសាងសង់ខ្នាតតូចដូចជាជួសជុលសាលារៀននិបន្ទប់រៀនជារៀងរាល់ឆ្នាំ | | |
| គ្រូបង្រៀន,គណៈកម្មការទ្រទ្រង់សាលា | ការរៀអង្គាសថវិកាសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ | នាយកសាលានិងប្រធានគណៈកម្មកាទ្រទ្រង់សាលា |
| ឪពុកម្ដាយនិងសហគមន៍ | បរិច្ចាកថវិកា សម្ភារៈ និងកម្លាំងសម្រាប់ដំណើរការសាងសង់ | នាយកសាលា,ប្រធានគណៈកម្មកាទ្រទ្រង់សាលា និងឪពុកម្ដាយ |
| សប្បុរសជន | ផ្ដល់សម្ភារៈសាងសង់ដូចជា ឈើ ស៊ីម៉ង់ខ្សាច់ និងសម្ភារៈផ្សេងៗ | នាយកនិងគណៈកម្មការទ្រទ្រង់សាលា |
| **២.**យុទ្ធនាការអប់រំ៖សាលារៀនទាំងអស់បានធ្វើយុទ្ធនាការអប់រំជារៀងរាល់ឆ្នាំដើម្បីប្រមូលកុមារ(អាយុចាប់ពី៦ឆ្នាំ)ឱ្យចុះឈ្មោះចូលរៀន | | |
| គ្រូបង្រៀន,គណៈកម្មការគ្រប់គ្រងសាលារៀននិងអាជ្ញាធរ | ផ្សព្វផ្សាយព័ត៌មានអប់រំទៅសមគមន៍,ស្រង់ចំនួនកុមារដែលគ្រប់អាយុចូលសិក្សា,ប្រមូលកុមារកំព្រានិងក្រីក្រ,លើកចិត្តសហគមន៍ឱ្យបញ្ជូនកូនទៅសាលារៀន | នាយកនិងគណៈកម្មការទ្រទ្រង់សាលានិងអាជ្ញាធរ |

| ៣.ការកសាងសមត្ថភាព៖ គណៈកម្មការទ្រទ្រង់សាលានិងគ្រូបង្រៀន | | |
|---|---|---|
| គណៈកម្មការគ្រប់គ្រងសាលារៀននិងគ្រូបង្រៀន | បង្កើនសមត្ថភាព,សហការ,ភាពជាអ្នកដឹកនាំការគ្រប់គ្រងនិងទំនាក់ទំនងល្អ | នាយកសាលា |

តាមតារាង៤.៤ ដែលឆ្លុះបញ្ចាំងពីការងារសហការរវាងសហគមន៍ និងសាលារៀនលទ្ធផលស្រាវជ្រាវបានបង្ហាញថាទម្រង់ទូទៅបំផុតនៃការងារសហការរវាងសាលារៀន និងសហគមន៍គឺនៅក្នុងគម្រោងសាងសង់សម្រាប់ការកែលម្អសាលារៀន និងការកែលម្អបរិស្ថាន។ កិច្ចសម្ភាសន៍ជាមួយនាយកសាលាបង្ហាញថាសាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនបានធ្វើការរៃអង្គាសថវិកាសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដូចជា បណ្ណាល័យ របងសាលា កែលម្អបរិយាកាសសាលា និងជួសជុលសាលារៀន អគារ។ នាយកសាលាបានផ្តល់ការឆ្លើយតបស្រដៀងគ្នាដែលសាលារបស់ពួកគេបានធ្វើការរៃអង្គាសប្រាក់ដើម្បីស្វែងរកប្រាក់ ដើម្បីបំពេញកង្វះថវិកាសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ សមាជិកសហគមន៍ គ្រួសារ និងអង្គការក្រៅរដ្ឋាភិបាលត្រូវបានរកឃើញថាមានរួមចំណែកធនធាននៅក្នុងគម្រោងអភិវឌ្ឍន៍សាលារៀន (សូមមើលការរកឃើញអំពីទម្រង់ផ្សេងៗនៃការរួមចំណែកធនធាន)។ លើសពីនេះ សាលារៀន និងសហគមន៍ធ្វើការរួមគ្នាដើម្បីប្រមូលកុមារឱ្យចុះឈ្មោះចូលរៀនសាលារៀន។ តាមទិន្នន័យដែលទទួលបានពីការសម្ភាសន៍នាយកសាលា ភាគច្រើនលើកឡើងស្រដៀងគ្នាថា៖

*«...ទំនាក់ទំនងរវាងសហគមន៍និងសាលារៀន លក្ខណៈល្អប្រសើរ និងសហការគ្នា»*

«...មានទំនាក់ទំនងល្អជាមួយអជ្ញាធរ សប្បុរសជន និងមាតាបិតាសិស្សដែលមករង់ចាំទទួលកុមារចេញពីសាលារៀន»

«...រីករាយក្នុងការសហការជាមួយសាលា ពេលសាលាស្នើសុំពួកគាត់ មិនថាអញ្ជើញមកប្រជុំ បរិច្ចាកធនធានកនិងជួយផ្សព្វផ្សាយព័ត៌មានបន្ត»

*(Principal#1,2,3,4,5)*

សាលាបានធ្វើការប្រជុំ និងបង្កើតបណ្ដាញភូមិដើម្បីកំណត់អត្តសញ្ញាណគ្រួសារនិងចំនួនកុមារដែលមានអាយុចូលរៀននៅក្នុងសហគមន៍ (សម្ភាសន៍នាយក,០២/០៩/២០២៣) ។ បន្ទាប់ពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល (NGOs) គឺជា អ្នកគាំទ្រលេចធ្លោជាងគេ ទាក់ទងនឹងការរួមចំណែកជាសម្ភារៈសម្រាប់ការកែលម្អសាលារៀន និងការអប់រំ។ ក្នុងអំឡុងពេលនៃការស្រាវជ្រាវ សាលាបឋមសិក្សា បានទទួលការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលចំនួនពីរគឺអង្គការស្តារកម្ពុជា(Star Kampuchea) អង្គការស្អាត (Clear Cambodia) (Pricipal#2, បទសម្ភាសន៍, ០២/០៩/២០២៣) ។ អង្គការស្តារកម្ពុជា ជួយវង្វាយតម្លៃ ដាក់ពិន្ទុដល់សាលា។ អង្គការស្អាត(Clear Cambodia) ដែលជួយអភិវឌ្ឍក្នុងសហគមន៍ដោយលើកកម្ពស់គុណភាពទឹក អនាម័យ សុខភាពនិងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដោយប្រើបច្ចេកវិទ្យានិងការអប់រំសមស្រប។«...*ប្រជុំធ្វើផែនការអភិវឌ្ឍសាលា តាមដានការអនុវត្តដំណើរការសាលារៀន វង្វាយតម្លៃដាក់ពិន្ទុសាលារៀនតាមរយៈអង្គការស្តារកម្ពុជា*»(Pricipal#2)។

## ៤.៥ ការពិភាក្សារួមនៃហេតុផលនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ

បន្ថែមពីលើការពិពណ៌នាអំពីទម្រង់ផ្សេងៗគ្នារបស់សហគមន៍ចូលរួមក្នុងការអប់រំថា ហេតុអ្វីបានជាពួកគេចូលរួម?ពួកគេបានលើកឡើងពីកត្តាស្រដៀងគ្នា ដែលថាពួកគេចូលរួមក្នុងការសិក្សារបស់កូនៗរបស់ពួកគេដោយសារតែពួកគេមានជំនឿទុកចិត្តលើការអប់រំ និងបំណងប្រាថ្នាចង់ឃើញកូនរបស់ពួកគេទទួលបានជោគជ័យនិងរីកចម្រើន។ «យើងមានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការអប់រំកុមារៗរបស់យើង» នាយិកាម្នាក់បានបន្ថែមថា «មាតាបិតាសិស្សមិនចង់ឱ្យកូនៗនៅតែជា (កសិករ)ដូចពួកគេទេ»។ «ឪពុកម្តាយត្រូវបានលើកទឹកចិត្តក្នុងការរួមចំណែកពេលវេលា និងធនធានរបស់ពួកគេដល់សាលាពីព្រោះ «ការអប់រំគឺដូចជាពន្លឺ»។ នៅពេលដែលកុមារមានការអប់រំពួកគេនឹងមានសមត្ថភាពអាចជួយខ្លួនឯង គ្រួសាររបស់ពួកគេ និងសហគមន៍របស់ពួកគេ» (សម្ភាសន៍ជាមួយ SSC, ២០២៣)។ អ្នកចូលរួមក្នុងក្រុមស្ទើរទាំងអស់ក៏បានកត់សម្គាល់ដែរថាខណៈមនុស្សភាគច្រើនជឿការចូលរួមរបស់សហគមន៍អាចធ្វើឱ្យការអប់រំរបស់កុមារកាន់តែប្រសើរឡើង ។ កត្តាដែលមានឥទ្ធិពលលើវិសាលភាពនៃការចូលរួមគឺមានទាំងសេដ្ឋកិច្ចនិងសង្គមនិងផ្តើមចេញពីទំនាក់ទំនងក្នុងសហគមន៍សាលារៀនក៏ដូចជារវាង សាលា និង

សហគមន៍ និងរដ្ឋាភិបាល ឬតួអង្គខាងក្រៅផ្សេងទៀត។ ឪពុកម្តាយ គ្រូបង្រៀន សមាជិក គ.គ.ស សិស្សានុសិស្ស និងព្រះសង្ឃទាំងអស់បានបញ្ជាក់ថាឧបសគ្គធំបំផុតចំពោះការចូលរួមរបស់សហគមន៍ក្នុងការអប់រំគឺ កត្តាជីវភាពក្រីក្រ។ នាយិកាម្នាក់បានពន្យល់ថា «គ្រួសារនិងឪពុកម្តាយចង់ចូលចិត្តចូលរួមជាមួយសាលាខ្លាំងណាស់ប៉ុន្តែដោយសារស្ថានភាពសេដ្ឋកិច្ចយើងមិនអាចឆ្លើយតបទៅនឹងតម្រូវការរបស់សាលាបានពេញលេញទាំងស្រុង» ។

**តារាង៤.៥៖ កត្តាជំរុញឱ្យមានការចូលរួមពីសហគមន៍នៅក្នុងសាលារៀន**

| កត្តាខាងក្រៅ | កត្តាខាងក្នុង |
|---|---|
| • ការលើកទឹកចិត្តពីបុគ្គលិកសាលាក្នុងការស្វាគមន៍ និងលើកទឹកចិត្តឪពុកម្តាយដើម្បីចូលរួម<br>•បុគ្គលិកសាលាបង្ហាញពីការគោរពចំពោះឪពុកម្តាយ និងតម្លៃនៃការរួមចំណែករបស់សហគមន៍ផ្សេងៗគ្នាចំពោះការអប់រំ<br>•ការប្រជុំបន្ថែមទៀតក្នុងចំណោមបុគ្គលិកសាលាSSC ឪពុកម្តាយនិងអ្នកដទៃ សមាជិកសហគមន៍<br>• យន្តការស្ថាប័នសម្រាប់សមាជិកសហគមន៍បម្រើជាមធ្យោបាយនៃការចូលរួម<br>• អារម្មណ៍នៃការជឿទុកចិត្ត និងការសហការ ដែលសាលាបានបង្កើតជាលទ្ធផលនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលាប្រកបដោយតម្លាភាព | • ការយល់ដឹងរបស់មាតាបិតាសិស្សអំពីតម្លៃ និងសារៈសំខាន់នៃការអប់រំ<br>•ក្តីប្រាថ្នារបស់មាតាបិតាសិស្សសម្រាប់ភាពប្រសើរឡើងនៃអនាគតកូនរបស់ពួកគេ។<br>• អារម្មណ៍នៃភាពជាម្ចាស់ និងកម្មសិទ្ធិរបស់សាលា |

ក្រៅពីការគ្រប់គ្រងប្រកបដោយតម្លាភាព និងប្រសិទ្ធភាពនៃការរួមចំណែកនោះ។ សមាជិកសហគមន៍បង្កើតទាំងឪពុកម្តាយនិងសិស្សបានអះអាងថាអាកប្បកិរិយារបស់គ្រូបង្រៀន អាចមានឥទ្ធិពលយ៉ាង

សំខាន់លើការយល់ឃើញរបស់ឪពុកម្តាយថាតើពួកគេគួរចូលរួមឬអត់។ ឪពុកម្តាយ និងសិស្សភាគច្រើនបានយល់ស្របថា អាកប្បកិរិយាវិជ្ជមានរបស់គ្រូបង្រៀនគឺជាកត្តាមួយដែលធ្វើឱ្យពួកគេនិងសមាជិកសហគមន៍ក្លាយចូលរួមក្នុងសាលា។«ដោយមានការលើកទឹកចិត្តពីសាលារៀនតាមរយៈពាក្យល្អដូចជា'អ្នកគឺជាដៃគូសាលាដ៏សំខាន់ មាតាបិតាសិស្សមានអារម្មណ៍ថា កាន់តែចង់ចូលរួមក្នុងសាលា។ ការសរសើរបែបនេះនឹងជួយបង្កើត អារម្មណ៍ល្អឆ្ពោះទៅរកសាលា" (Pricipal#5) ។ ឪពុកម្តាយនិងអ្នកផ្សេងទៀតក៏បានកត់សម្គាល់ផងដែរថាកិច្ចប្រជុំកាន់តែច្រើនរវាងបុគ្គលិកសាលា គណៈកម្មការគ្រប់គ្រងសាលារៀននិងសំខាន់ជាងនេះទៅទៀតជាមួយសមាជិកសហគមន៍ នឹងធ្វើឱ្យទំនាក់ទំនងកាន់តែប្រសើរឡើង បង្កើនការយល់ដឹងរបស់ឪពុកម្តាយ និងសហគមន៍អំពីបញ្ហាសាលា និងជំរុញចំណាប់អារម្មណ៍ក្នុងការចូលរួមក្នុងការកែលម្អសាលារៀន និងការគាំទ្រដល់ការសិក្សារបស់កុមារ។ ដូចដែលក្រុមគណៈកម្មការគ្រប់គ្រងសាលារៀនបានស្នើថា «សាលារៀនត្រូវតែមាន ការប្រជុំយ៉ាងហោចណាស់ពីរឬបីដងក្នុងមួយឆ្នាំដើម្បីផ្សព្វផ្សាយព័ត៌មានសំខាន់ៗនិងព័ត៌មានមានប្រយោជន៍ដើម្បីផ្តល់ការលើកទឹកចិត្តដល់ឪពុកម្តាយ ដែលនឹងជំរុញការយល់ដឹង និងការចូលរួមរបស់ឪពុកម្តាយការក្នុងការអប់រំ។»

ទាក់ទងនឹងភាពជាអ្នកដឹកនាំសាលាល្អ និងមានតម្លាភាព អ្នកគ្រប់គ្រង និងប្រធានគណៈកម្មការទ្រទ្រង់សាលាត្រូវចេះគ្រប់គ្រងថវិកានិងប្រើប្រាស់ថវិកាឱ្យត្រូវតាមគោលដៅ។ លើសពីនេះទៅទៀតការជឿទុកចិត្តគ្នានិងតម្លាភាពក្នុងការគ្រប់គ្រងសាលារៀនជាកត្តាសំខាន់បំផុតសម្រាប់សាលាក្នុងការជំរុញឱ្យសហគមន៍ចូលរួមកាន់តែច្រើន (**គណៈកម្មការគ្រប់គ្រងសាលារៀន,២០២៣**)។

សរុបជារួមទម្រង់នៃការចូលរួមរបស់សហគមន៍មាន ច្រើនទម្រង់ជាមូលដ្ឋានរបស់វាដូចជាការបញ្ជូនកូនទៅសាលារៀន(គ្រាន់តែប្រើប្រាសេវា)ជាសាច់ប្រាក់និងទម្រង់នៃការរួមចំណែកផ្សេងៗ (ការរួមចំណែកធនធាន)ការចូលរួមក្នុងកិច្ចប្រជុំ ឬព្រឹត្តិការណ៍នានានៅសាលា និងចែករំលែកគំនិតទាក់ទងនឹងបញ្ហាដែលសាលាជួបប្រទះ (ការប្រឹក្សាលើបញ្ហា)។ ក្នុងន័យជាក់ស្តែង ការចូលរួមពីសមាជិកសហគមន៍ភាគច្រើនមានកម្រិតខ្ពស់ ទោះបីជាទម្រង់នៃការចូលរួមមួយចំនួននៅមានកម្រិតទាំងនោះកំពុងលេចឡើងក៏ដោយ។ ដូចដែលបានបង្ហាញនៅក្នុងជំពូក៤នេះ គឺភាគច្រើនសាលារៀនដែលផ្តួចផ្តើមការប្រជុំ ឬ

ស្នើសុំការរួមចំណែកពីឪពុកម្តាយនិងសមាជិកសហគមន៍។ ឪពុកម្តាយនិងសហគមន៍ស្ទើរតែទាំងអស់ដែលចូលរួមក្នុងក្រុមគោលដៅបានទទួលស្គាល់ថាការរួមចំណែកសម្ភារៈ ជារឿងដំបូងដែលពួកគេអាចធ្វើបាន (ឬត្រូវការដោយសាលា) ពួកគេកគិតថាសកម្មភាពបង្រៀននិងរៀនក៏ដូចជាការសម្រេចចិត្តលើផែនការរបស់សាលាគឺពួកគាត់ស្ថិតនៅក្រៅប្រព័ន្ធនិងមានកំណត់។ ចំពោះបញ្ហានេះវាចាំបាច់សម្រាប់សាលានិង មន្ត្រីអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ សហគមន៍អំពីតួនាទីរបស់ពួកគេនៅក្នុងការកែលម្អសាលាក្នុងសហគមន៍របស់ពួកគេក៏ដូចជាលើកទឹកចិត្តពួកគេឱ្យចូលរួមបន្ថែមទៀតនៅក្នុង ការសម្រេចចិត្តទាក់ទងនឹងការសិក្សារបស់កូនពួកគេនិងការអនុវត្តការសម្រេចចិត្តចូលរួម។ ទម្រង់នៃការចូលរួមត្រូវបានពន្យល់បន្ថែមដូចខាងក្រោម៖

**ការចិញ្ចឹមកូន**

លទ្ធផលនៃការសិក្សាបង្ហាញថា ការចូលរួមរបស់មាតាបិតាសិស្សក្នុងការរៀនសូត្ររបស់កុមារ តាមរយៈសកម្មភាពនៃការបញ្ជូន កុមារទៅសាលារៀន និងគាំទ្រកុមារឱ្យទៅសាលារៀនប្រចាំថ្ងៃដូចជាការរៀបចំកូនរបស់ពួកគេទៅសាលារៀន ជាមួយនឹងសម្ភារសិក្សា និងការស្លៀកពាក់សមរម្យ។ ឪពុកម្តាយក៏ត្រូវទៅរកគ្រូដើម្បីទទួលបានព័ត៌មានអំពីវឌ្ឍនភាពនៃការសិក្សារបស់កូនពួកគេ និងបានពិគ្រោះជាមួយគ្រូក្នុងថ្នាក់អំពីការសិក្សារបស់កូនពួកគេ។ សកម្មភាពទាំងនេះកាតព្វកិច្ចរបស់ឪពុកម្តាយពីព្រោះឪពុកម្តាយបានជួយកុមារឱ្យមានចំណេះដឹងតាមរយៈការអប់រំ (Bornstein, 2005; Epstein, 1995)។ ការចូលរួមបង្ហាញថាឪពុកម្តាយយកចិត្តទុកដាក់ចំពោះអនាគតរបស់កូន។

**ការរៀននៅផ្ទះ៖**

ឪពុកម្តាយត្រូវបានគេរកឃើញថាជួយកូនរបស់ពួកគេរៀននៅផ្ទះបន្ទាប់ពីថ្នាក់រៀន។ ឪពុកម្តាយដែលចូលរួមត្រូវបាននិយាយថាបានជួយកូនរបស់ពួកគេនៅផ្ទះជាមួយនឹងការសិក្សារបស់ពួកគេ ប៉ុន្តែមានពួកគេមួយភាគធំដែលបានជួយក្នុងការបង្រៀន និងពិនិត្យសៀវភៅរបស់កូនពួកគេហើយភាគតូចនៃពួកគេ ឪពុកម្តាយគ្រាន់តែផ្តល់ការលើកទឹកចិត្ត និងប្រាប់កូនឱ្យរៀនមុនពេលចូលគេង។ ការរកឃើញនៃការស្រាវជ្រាវគឺស្របនឹង (**ងួន**,2012) ដែលឪពុកម្តាយភាគច្រើនចូលរួម ក្នុងការរៀនសូត្ររបស់កូនពួកគេ។

គ្រួសារក្រីក្រមាន ការចូលរួមតិចជាងព្រោះពួកគេរវល់នឹងការងារ។ ឪពុកម្តាយដែលមានការអប់រំខ្លះបានមកសាលាដើម្បីប្រឹក្សាជាមួយគ្រូអំពីវិធីសាស្រ្តបង្រៀនរបស់ពួកគេ ដើម្បីឱ្យពួកគេអាចជួយកូនរៀនបានកាន់តែពូកែ។ គ្រូបង្រៀនបានជំរុញទឹកចិត្តឪពុកម្តាយឱ្យមកពិភាក្សាជាមួយពួកគេដើម្បីស្វែងយល់ពីវឌ្ឍនភាពនៃការសិក្សារបស់កូនៗនិងបានផ្តល់ដំបូន្មានអំពីរបៀបជួយបង្រៀនកូនរបស់ពួកគេផងដែរ។

**ការប្រាស្រ័យទាក់ទងគ្នា**

ជាភស្តុតាងដែលប្រជាជនសហគមន៍ និងឪពុកម្តាយបានចូលរួមក្នុងការអប់រំ តាមរយៈការទំនាក់ទំនងព័ត៌មានអប់រំ។ សាលារៀន និងឪពុកម្តាយបានសហការគ្នាក្នុងការរៀនសូត្ររបស់កុមារតាមរយៈទិដ្ឋភាពផ្សេងៗ ដូចជាការប្រជុំ ការសរសេរ និងចូលរួមមតិយោបល់របស់ឪពុកម្តាយ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀតបានទទួលព័ត៌មានអប់រំថ្មីតាមរយៈការប្រជុំ ការផ្ញើសំបុត្រ និងការហៅទូរស័ព្ទ។ សហគមន៍ និងឪពុកម្តាយផ្សព្វផ្សាយព័ត៌មានអប់រំនៅក្នុងសហគមន៍របស់ពួកគេដើម្បីឱ្យសមាជិកក្នុងសហគមន៍យល់ពីតម្លៃនៃការអប់រំ និងបានចូលរួមនៅក្នុងការរៀនសូត្ររបស់កុមារ។ ដំណើរការទាំងនេះបង្ហាញថាឪពុកម្តាយ និងសមាជិកសហគមន៍បានទទួលបានការចូលរួមក្នុងការផ្តល់ និងបកស្រាយព័ត៌មានអប់រំកាន់តែទូលំទូលាយ។ លើសពីនេះទៀត អាជ្ញាធរមូលដ្ឋាន និងគណៈកម្មការគ្រប់គ្រងសាលារៀន ត្រូវបានរកឃើញថាបានប្រើមធ្យោបាយទំនាក់ទំនងជាច្រើនដូចជាការប្រជុំ ការហៅទូរស័ព្ទ និងការទៅសាលារៀន។ មធ្យោបាយទំនាក់ទំនងចម្រុះរបស់សាលាក្នុងការទាក់ទងឪពុកម្តាយ និងសហគមន៍ តាមរយៈគ្រូបង្រៀនដោយប្រើបណ្តាញទំនាក់ទំនង គ្រួសាររបស់សិស្សដើម្បីតាមដានការសិក្សារបស់កុមារ។ ការសិក្សាបានរកឃើញថា ការទំនាក់ទំនងជាលាយលក្ខណ៍អក្សរជាផ្លូវការកំពុងមានបញ្ហាសម្រាប់ឪពុកម្តាយ និងសមាជិកសហគមន៍មួយចំនួនដោយសារពួកគេពិបាកអាន និងសរសេរ។ វាពិបាកក្នុងការបង្កើតប្រព័ន្ធទំនាក់ទំនងដែលបណ្តាលឱ្យការប្រាស្រ័យទាក់ទងមិនសូវមានប្រសិទ្ធភាព( Epstein (1995, 2004) ។ សាលារៀនមានសហគមន៍ ឪពុកម្តាយ និង គណៈកម្មការគ្រប់គ្រងសាលារៀនបានជួយផ្សព្វផ្សាយព័ត៌មានទៅកាន់សហគមន៍ឱ្យកាន់តែទូលំទូលាយ ជាពិសេសអ្នកដែលមានអក្ខរកម្មកម្រិតទាប។

ការរកឃើញទាំងនេះបង្ហាញថាឧបករណ៍ទំនាក់ទំនងជាលាយលក្ខណ៍អក្សរ ដែលត្រូវបានប្រើជាផ្លូវការសម្រាប់ ទំនាក់ទំនងរវាងសាលារៀន និងឪពុកម្តាយ ក្នុងការរៀនសូត្ររបស់កុមារមិនសូវមានប្រសិទ្ធភាពដោយសារសមត្ថភាពក្នុងការអាន និងសរសេររបស់ឪពុកម្តាយ។ ជម្រើសផ្សេងទៀតដែលបានអនុវត្តដូចជាការប្រជុំ ការទៅជួបនៅផ្ទះ និងការហៅទូរសព្ទដែលតម្រូវឱ្យមានការប្តេជ្ញាចិត្តបន្ថែមរបស់គ្រូ និងឪពុកម្តាយខ្លួនឯង។

**កិច្ចសហការ**

ទម្រង់នៃការចូលរួមនេះគឺពាក់ព័ន្ធនឹងកិច្ចសហការរបស់សាលារៀន ទីភ្នាក់ងារ អាជីវកម្ម អង្គការ និងភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីចែករំលែកការទទួលខុសត្រូវសម្រាប់ការកែលម្អសាលារៀន និងការអប់រំ (Epstein, 1992, 1995, 2006) ។ សកម្មភាពសហការរបស់សហគមន៍ និងឪពុកម្តាយត្រូវបានបញ្ជាក់ថាធ្វើឡើងនៅកម្រិតផ្សេងៗគ្នាចាប់ពី «ការរួមចំណែកធនធាន» ដល់ «អំណាចផ្ទេរសិទ្ធិ» ។ សហគមន៍មាតាបិតាសិស្ស សិស្ស អង្គការក្រៅរដ្ឋាភិបាល ព្រះសង្ឃ លោកគ្រូ អ្នកគ្រូ និងអាជ្ញាធរមូលដ្ឋានកំពុងធ្វើការរួមគ្នាក្នុងការសាងសង់សាលារៀន ការប្រមូលកុមារទៅសាលារៀន បណ្តាញការពារកុមារ និងការកសាងសមត្ថភាព។ ក្នុងករណីនេះ គណៈកម្មការគ្រប់គ្រងសាលារៀនត្រូវបានរាយការណ៍ថាជាដៃគូធ្វើការក្នុងការរៃអង្គាសប្រាក់សម្រាប់ការអភិវឌ្ឍន៍សាលារៀន។ ធនធានសហគមន៍ត្រូវបានប្រមូល ការចូលរួមនេះបញ្ជាក់សហគមន៍ និងគ្រូបង្រៀនបានគោរពគ្នាទៅវិញទៅមកក្នុងការសម្រេចចិត្ត។ យោងតាមលោក Bray (2001) ការចូលរួមពិតប្រាកដគឺការចូលរួមដែលអ្នកចូលរួមទាំងអស់មានសិទ្ធិស្មើគ្នាក្នុងការសម្រេចចិត្ត (វាគឺជា ភាពជាដៃគូនៅក្នុង Arnstein, 1969)។

គោលនយោបាយ និងការអនុវត្តនៃការចូលរួមរបស់សហគមន៍សមាសភាគទីប្រាំនៃគោលនយោបាយរបស់សាលាមិត្តភាពកុមារ (CFS) បង្ហាញពីការលើកកម្ពស់ទំនាក់ទំនង និងការចូលរួមរវាងសាលារៀន និងសហគមន៍តាមលំដាប់លំដោយថាទំនាក់ទំនងនេះក្លាយជាធនធានសមូហភាពសម្រាប់ការអភិវឌ្ឍន៍សាលារៀនក៏ដូចជាការអប់រំ (MoEYS, 2007)។ ក្របខ័ណ្ឌគណៈគ្រប់គ្រងសាលារៀនត្រូវបានបង្កើតឡើងដើម្បី រួមបញ្ចូលតំណាងសហគមន៍នៅក្នុងសាលារៀន។ គំនិតជាមូលដ្ឋាននៃក្របខ័ណ្ឌ

នេះគឺដើម្បីពង្រឹងភាពជាម្ចាស់នៃសហគមន៍ក្នុងសាលារៀនពីព្រោះសាលារៀនមាន ទ្រព្យសម្បត្តិរបស់សហគមន៍ ដែលចាំបាច់ត្រូវតែមានការចូលរួមពីសហគមន៍ (MoEY, 2014)។ យោងតាមគោលនយោបាយនេះ រដ្ឋាភិបាលកម្ពុជា ព្យាយាមធ្វើការរួមគ្នាជាមួយសហគមន៍ដើម្បីកែលម្អការអប់រំ។ គោលការណ៍ណែនាំ សមាសធាតុចម្រុះនៃគណៈកម្មករគ្រប់គ្រងសាលាដើម្បីពង្រីកតំណាងសហគមន៍។ ការរកឃើញនៃការស្រាវជ្រាវក្នុងកម្រិតជាក់លាក់មួយឆ្លុះបញ្ចាំងថានេះ គោលនយោបាយនៃការចូលរួមរបស់សហគមន៍កំពុងដំណើរការប្រកបដោយប្រសិទ្ធភាព។

ទំនៀមទម្លាប់ប្រពៃណីនៃការចូលរួមរបស់សហគមន៍ តាមលទ្ធផលនៃការសិក្សាបង្ហាញថាទម្រង់នៃការចូលរួមក្នុងការអប់រំទូទៅបំផុតគឺ ការរួមចំណែកធនធាន។ ប្រជាជនសហគមន៍ និងក្រុមគ្រួសារបានចូលរួមចំណែកធនធានដែលមានដូចជាប្រាក់ សម្ភារៈ និងកម្លាំងពលកម្មក្នុងការជួសជុលសាលារៀន និងការកែលម្អបរិស្ថាននៅពេលស្នើសុំដោយសាលា។ ការរួមចំណែករបស់ពួកគេត្រូវបានបង្ហាញថាមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍សាលារៀន ព្រោះវាអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលាមិនដូចថវិការបស់រដ្ឋាភិបាលដែលមិនអាចឆ្លើយតបបានលឿន។ ការអនុវត្តដែលបានបង្ហាញនៅក្នុងការសិក្សាឆ្លុះបញ្ចាំងពីថាការរួមចំណែករបស់សហគមន៍គឺជាការចង់បាននៅពេល ដែលធនធានសាធារណៈមិនគ្រប់គ្រាន់ Rose(2003)។

ការរកឃើញនេះឆ្លុះបញ្ចាំងពី រដ្ឋាភិបាលកម្ពុជាបានអំពាវនាវឱ្យមានការចូលរួមចំណែកធនធានសម្រាប់ការសាងសង់សាលារៀនដើម្បីការរៀនសូត្ររបស់កុមារ។ ធនធានសហគមន៍ត្រូវបានបំពេញបន្ថែមនូវបញ្ហាកង្វះថវិការបស់រដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍវិស័យអប់រំ។ ការអនុវត្តនេះ ត្រូវបានបន្តទៅមនុស្សជំនាន់ក្រោយដូចដែលបានបង្ហាញនៅក្នុងការសិក្សារបស់ខ្ញុំ ។

ទោះបីជាការរួមចំណែកធនធានរបស់សហគមន៍មានសារៈសំខាន់ សម្រាប់ការអភិវឌ្ឍន៍សាលារៀនក៏ដោយតាមទស្សនៈរបស់ខ្ញុំការអនុវត្តនៃការចូលរួមមានលក្ខណៈចង្អៀត។ លើសពីនេះទៀតវាទាក់ទងនឹងឥរិយាបទរបស់ប្រជាជនក្នុងសហគមន៍ដែលមានបំណងក្នុងការចូលរួមក្នុងការអប់រំ។ ការអនុវត្តនៃការចូលរួមគួរតែត្រូវបានផ្លាស់ប្តូរតាមរយៈការយល់ឃើញរបស់គ្រូបង្រៀន និងសហគមន៍។ សាលា

រៀនគួរតែគិតគូរពីលទ្ធភាពរបស់ សហគមន៍នៅពេលស្នើសុំគម្រោងអភិវឌ្ឍន៍សាលារៀន។ ដើម្បីបង្កើនប្រសិទ្ធភាពធនធានសហគមន៍ សាលារៀនគួរតែរៀបចចំគម្រោងអភិវឌ្ឍន៍ដែលផ្តល់អត្ថប្រយោជន៍ដល់ការសិក្សារបស់កុមារ។ គណៈគ្រប់គ្រងសាលា គួរតែផ្លាស់ប្តូរការផ្តោតអារម្មណ៍ទៅលើតែការចូលរួមសម្រាប់ការរៀនសូត្ររបស់កុមារទៅជាយកចិត្តទុកដាក់ក្នុងការប្រមូលកុមារទៅសាលារៀននៅវិញ។

ការចូលរួមរបស់ សាលារៀន និង គណៈកម្មការគ្តប់គ្រងសាលា គឺការចូលរួមក្នុងសហគមន៍ក្នុងការអប់រំ តាមការសិក្សាបានរកឃើញថា តួនាទីឈានមុខគេរបស់សាលារៀន និងសហគមន៍ ដើម្បីគៀងគរការចូលរួមពីសហគមន៍។ សាលារៀនដែលមានអ្នកដឹកនាំមានតម្លាភាព គណនេយ្យភាព និងមានអភិបាលកិច្ចល្អនឹងនាំឱ្យសហគមន៍ជឿជាក់ក្នុងការចូលរួម។ តម្លាភាពស្តែងឡើងតាមរយៈភាពស្មោះត្រង់ យុត្តិធម៌ សមធម៌ មនុស្សធម៌។ ការសិក្សាបានរកឃើញថាសាលារៀនមានតម្លាភាពក្នុងការគ្រប់គ្រង សាលាបានបង្ហាញផែនការរបស់ពួកគេដល់សហគមន៍ និងតម្លាភាពថវិកា។ សាលាគឺមានទំនាក់ទំនងល្អ និងជាអ្នកបង្កើតបណ្តាញទំនាក់ទំនងដ៏ល្អជាមួយ សហគមន៍ និងលើកទឹកចិត្តសហគមន៍ឱ្យចូលរួមនៅក្នុងការអប់រំរបស់កុមារ។

ដូចគ្នានេះដែរ ការស្រាវជ្រាវនេះបានរកឃើញថាតួនាទីរបស់សាលារៀន និងគណៈកម្មការគ្រប់គ្រងសាលាគឺមានសារៈសំខាន់ក្នុងការជំរុញឱ្យមានការចូលរួមពីសហគមន៍ក្នុងការអប់រំ។ នាយកសាលា និងគណៈកម្មការគ្រប់គ្រងសាលាត្រូវបានរកឃើញថាមានតួនាទី ជាអ្នកទំនាក់ទំនងសហគមន៍នៅក្នុងសាលារៀន និងនៅក្នុងសហគមន៍។ ទោះជាយ៉ាងណាក៏ដោយ នាយកសាលា និងគណៈកម្មការគ្រប់គ្រងសាលាត្រូវមានសមត្ថភាពក្នុងងការគ្រប់គ្រងខ្លាំង និងជាអ្នកដឹកនាំមានជំនាញដូច្នេះពួកគេអាចគៀងគរការចូលរួមពីសហគមន៍ (Pellini, 1999)។ កាន់តែប្រសើរជាភាពអ្នកដឹកនាំជំនាញ និងការគ្រប់គ្រងល្អអាចជួយឱ្យសាលា និងគណៈកម្មការគ្រប់គ្រងសាលា គៀងគរ សហគមន៍ និងសង្គមស៊ីវិលឱ្យចូលរួមកាន់តែមានប្រសិទ្ធភាពដោយផ្តល់ការបណ្តុះបណ្តាលជំនាញដល់មាតាបិតាសិស្ស និងគ្រូបង្រៀន។

សរុបសេចក្តីមកសហគមន៍ និងមាតាបិតាសិស្សនៅតាមសាលាបឋមសិក្សាក្នុងក្រុងស្វាយរៀងខេត្តស្វាយរៀងគឺ ចូលរួមក្នុងការអប់រំតាមរបៀបផ្សេងៗគ្នា និងកម្រិតផ្សេងៗគ្នាហើយមានភាពខុសគ្នា

យ៉ាងខ្លាំងរវាងប្រភេទនៃការចូលរួមនីមួយៗ ទាក់ទងនឹងកម្រិតនៃការចូលរួមរបស់មាតាបិតាសិស្ស និងសមាជិកសហគមន៍មាននិន្នាការអកម្ម និងដោយប្រយោល។ ពួកគេចូលរួមតាមរយៈការជួយកុមារក្នុងការសិក្សា និងតាមរយៈការរួមចំណែកធនធានហើយ និងការយល់ដឹងរបស់ប្រជាជនក្នុងតំបន់អំពីការចូលរួមរបស់សហគមន៍។ សាលារៀន និងគណៈកម្មការគ្រប់គ្រងសាលា គឺជាដៃគូដែលបាននាំប្រជាជនក្នុងសហគមន៍រួមគ្នាចូលរួមក្នុងការកែលម្អការអប់រំ។ ប្រជាជនសហគមន៍អាចចូលរួមយ៉ាងច្រើនជាងមុននៅពេលដែលដៃគូទាំងពីរនេះមានសមត្ថភាពខ្លាំង។ គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលាបានដើរតួនាទីផ្សេងៗគ្នានៅក្នុងការនាំសហគមន៍ឱ្យចូលរួម និងរួមចំណែកដល់សាលារៀន និងការអភិវឌ្ឍន៍ការអប់រំ។ ពួកគេជាអ្នកសម្របសម្រួល អ្នកទំនាក់ទំនង និងជាបណ្តាញរបស់សាលារៀននិងសហគមន៍និងផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ សាលារៀនជាអង្គភាពមួយដែលស្ថិតនៅក្នុងសហគមន៍។ សហគមន៍បានជួយឧបត្ថម្ភសាលារៀនទាំងកម្លាំងចិត្ត ទ្រព្យសម្បត្តិ សម្ភារ និងថវិកាដើម្បីកសាងទ្រទ្រង់សាលាក្នុងសហគមន៍របស់ខ្លួនដំណើការអប់រំបានល្អប្រសើរ កូនចៅបានរៀនសូត្រមានចំណេះវិជ្ជាខ្ពង់ខ្ពស់ក្លាយខ្លួនទៅជាពលរដ្ឋពេញលេញអាចជួយធ្វើការគ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូលប្រកបដោយគុណធម៌និងចរិយាធម៌ល្អប្រសើរ។

ហេតុដូចនេះ សាលារៀនត្រូវតែយកចិត្តទុកដាក់បង្រៀនអប់រំកូនចៅក្នុងសហគមន៍ឱ្យបានដល់ទិសដៅទៅតាមគោលដៅអប់រំជាតិ កុំគិតតែប្រយោជន៍ផ្ទាល់ខ្លួន ក្បត់មនសិការវិជ្ជាជីវៈជាគ្រូបង្រៀនដែលជាហេតុធ្វើឱ្យសហគមន៍លែងគាំទ្រអស់ជំនឿក្នុងការចូលរួមជាមួយសាលា ជាកត្តាធ្វើឱ្យសាលាជួបផលវិបាកមិនអាចឈានទៅដល់ការរីកចម្រើនបានឡើយ។

ដូចនេះ សាលារៀននិងសហគមន៍ត្រូវតែមានទំនាក់ទំនងល្អនឹងគ្នានិងសហការគ្នាធ្វើអ្វីៗដើម្បីប្រយោជន៍គ្នាទៅវិញទៅមកដោយខានមិនបាន បើមិនដូច្នេះទេលទ្ធផលនៃការអប់រំច្បាស់ជាពុំអាចទៅដល់គោលដៅល្អប្រសើរឡើយ។

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និង សំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី **«ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង»** មានគោលបំណងសិក្សាឈ្វេងយល់អំពីទម្រង់នៃការចូលរួម ការលើកទឹកចិត្ត និងបញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ ជាពិសេសការចូលរួមរបស់សហគមន៍នៅសាលាបឋមសិក្សាក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង។ ជាការសន្និដ្ឋាន ការចូលរួមរបស់សហគមន៍នៅក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀងមានកម្រិតវិជ្ជមានច្រើនគួរឱ្យកត់សម្គាល់ ហើយមានការឆ្លើយតបខ្ពស់ទៅនឹងអ្វីដែលអ្នកសិក្សាស្រាវជ្រាវកំពុងស្វែងរក ដើម្បីបានចូលរួមជាចំណែកដ៏តូចមួយក្នុងការបង្កើននៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំឱ្យរិតតែប្រសើរឡើង។

លទ្ធផលនៃការស្រាវជ្រាវនេះត្រូវបានលើកមកបង្ហាញចំនួនបីចំណុចរួមមាន៖(ទី១)ទម្រង់នៃការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅសាលាបឋមសិក្សាក្នុងក្រុងស្វាយរៀង(ទី២)កត្តាលើកទឹកចិត្តក្នុងកាតចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំក្នុងក្រុងស្វាយរៀង ទី(៣)បញ្ហាប្រឈមរបស់សហគមន៍ក្នុងការចូលរួមក្នុងវិស័យអប់រំនៅសាលាបឋមសិក្សាក្នុងក្រុងស្វាយរៀងខេត្តស្វាយរៀង។

យោងតាមលទ្ធផលទិន្នន័យជារួម ការរកឃើញនៃការសិក្សានេះបានបង្ហាញថាការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំបីប្រភេទ៖(១)ការរួមចំណែករបស់សហគមន៍ដល់សាលារៀន៖សហគមន៍រួមចំណែកទាក់ទងនឹងការបរិច្ចាកជាថវិកា សម្ភារៈ និងកម្លាំងពលកម្ម ដើម្បីឆ្លើយតបទៅនឹងការសំណូមពររបស់សាលា (២)ការចូលរួមនៅតាមសាលា គឺជាការចូលរួមរបស់សហគមន៍នៅក្នុងព្រឹត្តិការណ៍សាលា ការប្រជុំ និងការពិគ្រោះយោបល់ជាមួយសាលា និង(៣)ការចូលរួមសកម្មភាពអប់រំនៅផ្ទះ គឺការចូលរួមរបស់ឪពុកម្តាយក្នុងការបញ្ជូនកូនទៅសាលារៀន ពិនិត្យមើលកិច្ចការផ្ទះរបស់កុមារការបង្រៀនកុមារ ផ្តល់ការលើកទឹកចិត្តដល់កុមារ និងពិនិត្យមើលកំណត់ត្រាការសិក្សារបស់កុមារ និងសៀវភៅកត់ត្រា។ ការចូល

រួមនៅផ្ទះគឺនិយាយជាមួយកុមារអំពីវឌ្ឍនភាពនៃការសិក្សារបស់ពួកគេដោយធានាថាកុមារមានភាពសមស្រប បរិយាកាសសិក្សា និងលើកទឹកចិត្តកុមារឱ្យសិក្សាពេញមួយជីវិត។

ចំពោះកត្តាជំរុញឱ្យសហគមន៍ចូលរួមក្នុងការអប់រំគឺការយល់ដឹងរបស់មាតាបិតាសិស្សពីតម្លៃ និងប្រយោជន៍នៃការអប់រំព្រមទាំងសេចក្ដីប្រាថ្នារបស់ពួកគេ ក្នុងការចង់ឱ្យកូនចៅខ្លួនមានអនាគតល្អប្រសើរដែលនេះ គឺជាកត្តាពីខាងក្នុងដ៏សំខាន់ដែលបានជំរុញពួកគេឱ្យចូលរួម។ អភិបាលកិច្ចល្អ ទំនុកចិត្ត និងតម្លាភាពក្នុងការដឹកនាំចាត់ចែងរបស់សាលារៀន គឺជាកត្តាពីខាងក្រៅដែលនាំឱ្យមានការចូលរួមពីសំណាក់សហគមន៍។ បញ្ហាប្រឈមមួយចំនួនដែលរាំងស្ទះដល់ការចូលរួមរបស់សហគមន៍ក្នុងការអប់រំផងដែរគឺសហគមន៍មិនសូវបានចូលរួមក្នុងកម្មវិធីរបស់សាលាព្រោះរវល់ ការចូលពិគ្រោះយោបល់ក្រៅផ្លូវការ ការប្រជុំម្ដងម្កាល និងការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួនជាមួយគ្រូ។ ឪពុកម្ដាយមានការចូលរួមកាន់តែច្រើនក្នុងការរៀនសូត្ររបស់កូន ប្រសិនបើពួកគេបានយល់ដឹងអំពីជំនាញដែលពាក់ព័ន្ធនឹងការជួយដល់ការរៀនសូត្ររបស់កុមារ និងជាមូលដ្ឋាន នៃវិធីសាស្ត្របង្រៀនកូនរបស់ពួកគេ។

ដូច្នេះសំណូមពរមួយពីការសិក្សានេះគឺថាសាលារៀនផ្ដល់ការគាំទ្រដល់ឪពុកម្ដាយ និងការពិគ្រោះយោបល់លើការរៀនសូត្ររបស់កុមារ។ វាច្បាស់ណាស់ថាសាលារៀនបានព្យាយាមធ្វើពិពិធកម្មមធ្យោបាយទំនាក់ទំនងដោយទំនាក់ទំនងជាលាយលក្ខណ៍អក្សរផ្លូវការហាក់ដូចជាគ្មានប្រសិទ្ធភាពដោយសារអក្ខរកម្មរបស់ឪពុកម្ដាយមានកម្រិត។ នៅក្នុងបរិបទសិក្សាសហគមន៍បានធ្វើការផ្សព្វផ្សាយ ការប្រជុំជាមួយគ្រូ និងឪពុកម្ដាយ ហើយការហៅទូរស័ព្ទគឺជាជម្រើសដ៏មានប្រសិទ្ធភាពជាងក្នុងការទំនាក់ទំនងអំពីវឌ្ឍនភាពនៃការសិក្សារបស់កុមារ។ ជម្រើសទាំងនេះជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការគាំទ្រ មាតាបិតាសិស្ស និងប្រជាពលរដ្ឋក្នុងសហគមន៍ក្នុងការចូលរួមក្នុងការអប់រំ និងការរៀនរបស់កុមារ។ ការរកឃើញដ៏គួរឱ្យចាប់អារម្មណ៍មួយទៀត គឺជាវិធីដែលសហគមន៍សហការគ្នាផ្សព្វផ្សាយព័ត៌មានអំពីការអប់រំ និងការរៀនសូត្ររបស់កុមារ។ ក្រុមប្រឹក្សាសិស្ស (SCs) គណៈកម្មការគ្រប់គ្រងសាលា(គ.គ.ស) អាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល ព្រះសង្ឃ ក៏ដូចជាក្លឹបយុវជនបានចូលរួមក្នុងការអភិវឌ្ឍន៍សាលារៀន។ ពួកគេបានប្រមូលកុមារនៅក្នុងសហគមន៍ដើម្បីទៅសាលារៀននិងលើកកម្ពស់ការអប់រំតាមរយៈការចែករំលែក

ព័ត៌មានអប់រំនៅក្នុងសហគមន៍ដែលជំរុញឱ្យគោលបំណងរួមក្នុងការលើកកម្ពស់ការអប់រំសម្រាប់មនុស្សជំនាន់ក្រោយ។ ទោះជាយ៉ាងនេះក្តី វិធីសាស្ត្រនៃការគៀងគរសហគមន៍ត្រូវបានកំណត់ចំពោះការប្រមូលធនធានសហគមន៍សម្រាប់ការអភិវឌ្ឍន៍សាលារៀនជាជាងការគៀងគរសហគមន៍ឱ្យចូលរួម និងវិនិយោគលើការអប់រំ។

ការគៀងគរអ្នកពាក់ព័ន្ធទាំងនេះ ឱ្យចូលរួមក្នុងការអប់រំផ្តោតសំខាន់តែលើការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលចំណាយធនធានសហគមន៍។ ត្រង់ចំណុចនេះគឺថាការអនុវត្តគួរផ្លាស់ប្តូរទៅជាការផ្តោតអារម្មណ៍លើគុណភាពនៃការរៀនសូត្ររបស់កុមារ ជាជាងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ សាលារៀន និងគណៈកម្មការគ្រប់គ្រងសាលាអាចជាកត្តាជំរុញឱ្យមានការផ្លាស់ប្តូរនេះបាន។

ការរកឃើញសំខាន់មួយទៀតគឺថាគណៈកម្មការគ្រប់គ្រងសាលានិងគណៈគ្រប់គ្រងសាលារៀនបានធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាសម្រាប់ការអភិវឌ្ឍន៍ការអប់រំ។ សាលារៀនតែងតែមានការពិភាក្សាជាមួយគណៈកម្មការគ្រប់គ្រងសាលាអំពីបញ្ហាប្រឈម និងផែនការអភិវឌ្ឍន៍សាលារៀន។ គណៈកម្មការគ្រប់គ្រងសាលាតំណាងឱ្យសហគមន៍នៅក្នុងសាលារៀនដែលបានចូលរួមក្នុងការអប់រំ និងការអភិវឌ្ឍសាលារៀនយ៉ាងច្រើនដូចជាការកសាងផែនការអភិវឌ្ឍន៍សាលារៀន ការគ្រប់គ្រងថវិកា ធនធានផ្សេងៗ។ ឪពុកម្តាយ និងសហគមន៍ត្រូវបានរកឃើញថាបានរួមចំណែកធនធានក្នុងមូលដ្ឋានរបស់ពួកគេសម្រាប់ការអភិវឌ្ឍន៍សាលារៀនតាមរយៈគណៈកម្មការគ្រប់គ្រងសាលានីមួយៗ។ នាយកសាលាលោកគ្រូ អ្នកគ្រូ និងឪពុកម្តាយរួមជាមួយ គណៈកម្មការគ្រប់គ្រងសាលាបានរួមសហការគ្នាក្នុងការសម្រេចចិត្តលើផែនការដំណើរការសាលារៀន។ គណៈគ្រប់គ្រងសាលា និងគណៈកម្មការគ្រប់គ្រងសាលារៀនមានតួនាទីនាំមុខក្នុងការធ្វើឱ្យមានការចូលរួមពីសហគមន៍ក្នុងការអប់រំ។

**អនុសាសន៍សម្រាប់ការចូលរួមកាន់តែប្រសើរឡើងក្នុងការអប់រំ**

សាលារៀនគួរ ផ្តល់ការបណ្តុះបណ្តាលអំពីរបៀបបង្រៀនកូនដល់ឪពុកម្តាយ ដូច្នេះឪពុកម្តាយអាចជួយបង្រៀនកូនៗនៅផ្ទះ។ សាលារៀន និងគណៈកម្មការគ្រប់គ្រងសាលារៀនគួរបង្កើតកម្មវិធីចែក

រំលែកជាមួយឪពុកម្ដាយដែលមានការអប់រំអាចចែករំលែកការចិញ្ចឹមកូន និងជំនាញក្នុងការអប់រំកូនដល់ឪពុកម្ដាយដែលមានការអប់រំទាប។ គំរូនេះអាចជាដំណើរការបានល្អនៅទីក្រុង ដែលឪពុកម្ដាយយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការរៀនសូត្ររបស់កុមារ និងប្រហែលជាមានប្រសិទ្ធភាព និងអាចអនុវត្តបានក្នុងបរិបទទីក្រុងនៃប្រទេសកម្ពុជា។ គំរូនេះនឹងត្រូវការកម្លាំងការប្ដេជ្ញាចិត្តយ៉ាងខ្លាំងពីសាលារៀនគណៈកម្មការគ្រប់គ្រងសាលារៀន អាជ្ញាធរមូលដ្ឋាន និងមាតាបិតាសិស្សដោយមានការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡាផងដែរ។

ក្រសួងអប់រំអាចពិចារណា ផ្ដល់ជំនាញគរុកោសល្យដល់មាតាបិតាសិស្សដូច្នេះ មាតាបិតាសិស្សអាចជួយកុមារសិក្សានៅផ្ទះបានព្រោះកុមារមកសាលាដើម្បីសិក្សាមានរយៈពេលខ្លីជាងពេលវេលានៅផ្ទះ។ គ្រូបង្រៀនអាចលើកកម្ពស់វប្បធម៌នៃការចូលរួមរបស់មាតាបិតាសិស្ស ក្នុងការរៀនសូត្ររបស់កូនតាមរយៈការរចនាកិច្ចការផ្ទះសម្រាប់ឪពុកម្ដាយ និងកូនដែលតម្រូវឱ្យកុមារ និងឪពុកម្ដាយធ្វើការជាមួយគ្នា បច្ចេកទេសនេះអាចផ្លាស់ប្ដូរអាកប្បកិរិយារបស់ឪពុកម្ដាយបន្តិចម្ដងៗចំពោះការសិក្សារបស់កូន (Epstein & Van Voorhis, 2001)។

## ៥.២ សំណូមពរ

យោងតាមលទ្ធផលនៃការស្រាវជ្រាវនេះ បានរកឃើញពីការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង។ ដូច្នេះដើម្បីរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមខាងលើនេះ អ្នកសិក្សាស្រាវជ្រាវសូមលើកយកនូវគំនិតយោបល់និងសំណូមពរដល់ភាគីពាក់ព័ន្ធដូចតទៅ៖

### ៥.២.១. ក្រសួងអប់រំ យុវជន និងកីឡា

- MoEYS បង្ហាញការប្ដេជ្ញាចិត្តក្នុងការរួមបញ្ចូលវិធីសាស្ត្រកែលម្អការអប់រំដែលត្រូវបានបង្ហាញនៅក្នុងរដ្ឋធម្មនុញ្ញច្បាប់អប់រំ និង កម្មវិធីសាលាកុមារមេត្រី(CFS)។
- ក្រសួងអប់រំ យុវជន និងកីឡាផ្ដល់ការគាំទ្រផ្នែកគោលនយោបាយ ដូចដែលបានបង្ហាញនៅក្នុងកម្មវិធីសាលាកុមារមេត្រី (2007) ទោះបីជាយ៉ាងណាក៏ដោយការគាំទ្រផ្នែកបច្ចេកទេស និងការ

គ្រប់គ្រងបន្ថែមទៀតអាចត្រូវបានផ្តល់ឱ្យតាមរយៈការលើកទឹកចិត្ត និងជំបូន្មានដល់សាលា និងគណៈកម្មការគ្រប់គ្រងសាលារៀនដែលអនុវត្តបានល្អក្នុងការគៀងគរការចូលរួមរបស់សហគមន៍សម្រាប់ការលើកកម្ពស់ការអប់រំ ។

### ៥.២.២ គណៈគ្រប់គ្រងសាលារៀន

- សាលារៀនគួរផ្តល់ការបណ្តុះបណ្តាលអំពីរបៀបបង្រៀនកូនដល់ឪពុកម្តាយដូច្នេះឪពុកម្តាយអាចជួយបង្រៀនកូនៗនៅផ្ទះ។
- លោកគ្រូអ្នកគ្រូ និងសហគមន៍ត្រូវធ្វើការសិក្សាស្វែងយល់ឱ្យបានច្បាស់ពីតួនាទី និងការសហការគ្នាដើម្បីធ្វើយ៉ាងណាបង្ហាញនូវឆន្ទៈដ៏មោះមុតរួមគ្នាក្នុងការអភិវឌ្ឍសាលារៀន។
- សាលារៀនគួរធ្វើការប្រជុំទៀងទាត់ជាមួយឪពុកម្តាយ ចែករំលែកវឌ្ឍនភាពនៃការសិក្សារបស់កុមារ និងអញ្ជើញឪពុកម្តាយគំរូឱ្យចែករំលែកជាមួយឪពុកម្តាយដទៃ។
- គ្រូបង្រៀនគួរលើកកម្ពស់វប្បធម៌នៃការចូលរួមរបស់មាតាបិតាសិស្សក្នុងការរៀនសូត្ររបស់កុមារតាមរយៈការរចនាកិច្ចការផ្ទះសម្រាប់ឪពុកម្តាយ និងកូនដែលតម្រូវឱ្យកុមារ និងឪពុកម្តាយធ្វើការជាមួយគ្នា។
- នាយកសាលាគួរផ្តល់រង្វាន់ឱ្យឪពុកម្តាយគំរូដែលមានកុមារដែលជាសិស្សឆ្នើមនៅក្នុងសាលារៀន និងក្នុងសហគមន៍។
- សាលារៀនគួរពិចារណាពីសមត្ថភាពរបស់ សាលារៀន និងសហគមន៍ នៅពេលស្នើសុំគម្រោងអភិវឌ្ឍន៍សាលារៀន។ វិធីសាស្ត្រនៃការកៀរគរសហគមន៍ត្រូវបានកំណត់ចំពោះការប្រមូលធនធានសហគមន៍សម្រាប់ការអភិវឌ្ឍន៍សាលារៀនជាជាងការកៀរគរប្រជាជនសហគមន៍ឱ្យចូលរួម និងវិនិយោគការអប់រំ។
- នាយកសាលាគួររៀបចំគណៈកម្មការនិងក្រុមប្រឹក្សានានារបស់សាលាធ្វើការផ្សព្វផ្សាយ រៀបចំកិច្ចប្រជុំជាមួយមាតាបិតាសិស្ស ចុះផ្ទាល់សាកសួរគ្រួសារសិស្ស អញ្ជើញមាតាបិតា

សិស្សមកសាលា ប្រជុំក្រុមប្រឹក្សាអប់រំ និងសមាគមន៍មាតាបិតាសិស្សឱ្យបានទៀងទាត់សិក្ខាសាលាការងារសហគមន៍ និងរៀបចំសកម្មភាព/ព្រឹត្តិការណ៍ផ្សេងៗទាក់ទាញសហគមន៍។

### ៥.២.៣ សហគមន៍

- គួរសម្រេចចិត្តចូលរួមក្នុងសកម្មភាពបង្រៀននិងរៀនជាជាងការរួមវិភាគទានជាថវិកា
- សហគមន៍ត្រូវធ្វើការសិក្សាស្វែងយល់ឱ្យបានច្បាស់ពីតួនាទីនិងការសហការគ្នាដើម្បីធ្វើយ៉ាងណាបង្ហាញនូវឆន្ទៈដ៏មោះមុតរួមគ្នាក្នុងការអភិវឌ្ឍសាលារៀន។
- សហគមន៍គួរចូលរួមសហការជាមួយសាលារៀនក្នុងកាប្រមូលកុមារឱ្យចូលរៀន ជួយស្វែងរកចំណូលនិងថវិការ ជួយគ្រប់គ្រងថវិកា ថែរក្សាទ្រព្យសម្បត្តិសាលារៀនចូលរួមក្នុងការសាងសង់និងជួសជុលសាលា ជួយបំផុសកូនចៅឱ្យទៅសាលា តាមដានកាតសិក្សារៀនសូត្ររបស់កុមារ ចូលរួមអនុវត្តផែនការរបស់សាលានិងការងារតាមដានត្រួតពិនិត្យ និងពង្រឹងនិងពង្រីកសមត្ថភាពយល់ដឹងអំពីការអភិវឌ្ឍសាលារៀន

## ៥.៣ សំណូមពរសម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវនេះផ្តោតទៅលើទម្រង់ កត្តាជំរុញលើកទឹកចិត្ត និងបញ្ហាប្រឈមរបស់សហគមន៍ក្នុងការអប់រំនៅកម្រិតបឋមសិក្សាក្នុងក្រុងស្វាយរៀង។ វិធីសាស្រ្តនៃការកៀរគរត្រូវបានកំណត់ចំពោះការប្រមូលធនធានពីសហគមន៍សម្រាប់អភិវឌ្ឍសាលារៀនជាជាងការកៀរគរសហគមន៍ឱ្យចូលរួមនិងវិនិយោគក្នុងការអប់រំ។

ការសិក្សាស្រាជ្រាវផ្តោតទៅលើរបៀបដែលសាលារៀន និងគណៈកម្មការទ្រទ្រង់សាលាធ្វើការរួមគ្នាដើម្បីប្រមូលធនធានពីសហគមន៍ ដើម្បីបំពេញបន្ថែមលើ ថវិការបស់រាជរដ្ឋាភិបាលសម្រាប់អភិវឌ្ឍសាលារៀន។

សម្រាប់ការសិក្សាបន្ត អ្នកស្រាវជ្រាវដទៃទៀតអាចធ្វើការពិចារណាដូចខាងក្រោម៖

- សិក្សាប្រធានបទខាងលើនេះដោយកំណត់យកចំនួនសាលារៀននៅតំបន់ដាច់ស្រយាលបន្ថែម ដោយមានពង្រីកចំនួនសំណាកសម្រាប់កម្រងសំណួរ ទាំង គណៈកម្មការទ្រទ្រង់សាលា មាតាបិតាសិស្ស អជ្ញាធរ និងព្រះចៅអធិការវត្ត និងភាគីពាក់ព័ន្ធដទៃទៀតក្នុងសហគមន៍
- សិក្សាពីការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមភូមិឬកម្រិតទុតិយភូមិក្នុងខេត្តស្វាយរៀង
- ការសិក្សាស្រាវជ្រាវបន្ថែមគួរតែផ្តោតលើវិធីសាស្ត្រនៃការកៀរគរសហគមន៍ក្នុងមូលដ្ឋានឱ្យចូលរួមកាន់តែច្រើនក្នុងដំណើរការសិក្សារបស់កុមារ។

# ឯកសារយោង


1. ក្រសួងអបរំ យុវជន និងកីឡា (២០០៧), គោលនយោបាយស្តីពីសាលាកុមារមេត្រី, រាជធានីភ្នំពេញ, កម្ពុជា, ក្រសួងអបរំ យុវជន និងកីឡា
2. ក្រសួង អបរំ យុវជន និងកីឡា (២០១០). គោលនយោបាយស្តីពីការអភិវឌ្ឍកម្រងសាលារៀន
3. ក្រសួងអបរំ យុវជន និងកីឡា (២០១២), គោលការណ៍ណែនាំ របស់គណៈកម្មការទ្រទ្រង់សាលា, ភ្នំពេញ, ក្រសួងអបរំ យុវជន និងកីឡា
4. ក្រសួងអបរំ យុវជន និងកីឡា (២០១៤a), ផែនការយុទ្ធសាស្ត្រវិស័យអប់រំ( ២០១៤-២០១៨) ភ្នំពេញ,ក្រសួងអបរំ យុវជន និងកីឡា
5. ក្រសួងអបរំ យុវជន និងកីឡា (២០១៤b), ផែនការសកម្មភាពជាតិស្តីពីការថែទាំនិងអភិវឌ្ឍកុមារតូច( ២០១៤-២០១៨) ភ្នំពេញ, ក្រសួងអបរំ យុវជន និងកីឡា
6. KAPE. (២០១៥). របាយការណ៍ស្តីពីកម្មវិធីសាលាកុមារមេត្រី
7. Arnstein, S. R. (1969). A ladder of citizen participation. Journal of the American Institute of Planners, 35(4), 216-224. doi: 10.1080/01944366908977225
8. Bornstein, M. H. (2005). Handbook of parenting: Volume 4 social conditions and applied parenting. London: Lawrence Erlbaum Associates.
9. Bray, M. (1999). The private costs of public schooling: Household and community financing: Paris: International Institute for Educational Planning/UNESCO.
10. Bray, M. (2001). Community partnerships in education: Dimensions, variations and implications. Paris: UNESCO
11. Bray, M. (2003). Community Initiatives in Education: Goals, dimensions and linkages with governments. Compare: A Journal of Comparative and International Education, 33(1), 31-45. doi:10.1080/03057920302598
12. Clayton, T. (2005). Re-orientations in moral education in Cambodia since 1975. Journal of Moral Education, 34(4), 505-517.
13. Dy, S. S. (2004). Strategies and Policies for Basic Education in Cambodia: Historical Perspectives. International education journal, 5(1), 90-97.

14. Epstein, J. (1992). School and family partnerships. In M. Alkin (Ed.), Encyclopedia of educational research (6th ed., pp. 1139–1151). New York: Macmillan.

15. Epstein, J. L. (1995). School/family/community partnerships. Phi Delta Kappan, 76(9), 701-712.

16. Epstein, J. L. (2006). Families, schools, and community partnerships. YC Young Children,61(1), 40-40. Retrieved from http://search.proquest.com/docview/197603268?accountid=14782

17. Epstein, J. L., & Salinas, K. C. (2004). Partnering with families and communities. Educational Leadership, 61(8), 12-19.

18. Epstein, J. L., & Van Voorhis, F. L. (2001). More than minutes: Teachers_ roles in designing homework. Educational psychologist, 36(3), 181–193.

19. Epstein, J. L., Sanders, M. G., Simon, B. S., Salinas, K. C., Jansorn, N. R., & Van Voorhis, F. L. (2002). School, family, and community partnerships: Your handbook for action: Corwin Press. Califonia.

20. Nguon, S. (2012). Parental involvement and students' achievement in Cambodia: Focusing on parental resourcing of public schooling. International Journal of Educational Research, 53, 213-224.

21. Pak, V. (2012). Understanding rural parent-school-community partnerships in Cambodia: Practices, communications and perceptions. The University of Hong Kong, Pokfulam, Hong Kong.

22. Pellini, A. (2005). Decentralisation of education in Cambodia: Searching for spaces of participation between traditions and modernity. Compare: A Journal of Comparative andInternational Education, 35(2), 205-216.

23. Pellini, A. (2007). Decentralization and community participation: School clusters in Cambodia in School Decentralization in the Context of Globalizing Governance (pp. 175-194): Springer.

24. Pellini, A., & Bredenberg, K. (2015). Basic education clusters in Cambodia: Looking at the future while learning from the past. Development in Practice, 25(3), 419-432.

25. Rose, P. (2003). Community Participation in School Policy and Practice in Malawi: Balancing local knowledge, national policies and international agency priorities. Compare: A Journal of Comparative and International Education, 33(1), 47-64. doi:10.1080/03057920302597

26. Save the Children Cambodia. (2015). Program Based Budget Reform and Community Participation in Primary Education in Cambodia 2015. Retrieved from Phnom Penh, Cambodia:

https://cambodia.savethechildren.net/sites/cambodia.savethechildren.net/files/library/4.CRG%20publication_2%20Sept.pdf

27. Shaeffer, S. (1992). Collaborating for educational change: The role of parents and the community in school improvement. International Journal of Educational Development, 12(4), 277-295. doi: http://dx.doi.org/10.1016/0738-0593(92)90004-6
28. Shaeffer, S. (1994). Participation for educational change: A synthesis of experience: International Institute for Educational Planning. Paris, UNESCO.
29. UNESCO. (2013a). Toward universal learning: What every child should learn Universal Education (Vol. 1, pp. 1-101). Washington, DC.
30. UNESCO. (2013b). Education for All: Policy Paper Education for All Global Monitoring Report (Vol. 09, pp. 1-9).
31. WB. (2015). Life Expectancy at Birth, Total (Years) Retrieved from http://data.worldbank.org/indicator/SP.DYN.LE00.IN. Retrieved 25/09/2015, from The World Bank http://data.worldbank.org/indicator/SP.DYN.LE00.IN
32. Williams, R. (2008). The epistemology of knowledge and the knowledge process cycle: Beyond the — objectivist‖ vs —inter pretivist‖. Journal of Knowledge Management, 12(4), 72-85.
33. Wolf, J. M., Kane, E., & Strickland, B. (1997). Planning for community participation in education: Office of Sustainable Development, Bureau for Africa, US Agency for International Development.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**វិទ្យាស្ថានជាតិអប់រំ**
លេខ : ៤៨០.....ទជអ. លក

# លិខិតបង្គាប់ការ

យោង៖ - លិខិតឧទ្ទេសនាមលេខ៨៤៧៣ អយក.ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីគណៈកម្មការមេប្រយោគ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

- លិខិតឧទ្ទេសនាមលេខ៨៥០១ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីគណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៤ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការរៀបចំ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៦ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការគណនេយ្យ និងសម្ភារៈ សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។
- លិខិតឧទ្ទេសនាមលេខ៨៤៧៥ អយក. ឧទន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី គណៈកម្មការកណ្តាល សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០។

បុគ្គលិកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៨-៩ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង ០៨:០០នាទីព្រឹក នៅវិទ្យាស្ថានជាតិអប់រំ៖

I. **គណៈកម្មការការពារនិក្ខេបបទ**

**ក្រុមទី១ នៅអគារ** B07 **បន្ទប់** 101

| **គោត្តនាម និងនាម** | | **អង្គភាព** | **តួនាទី** |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិកា |
| ៣- លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ: www.nie.edu.kh

| | | | |
|---|---|---|---|
| ៥- លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៦- លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី២ នៅអគារ** B07 **បន្ទប់** 105

| | | | |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត | ប៊ិច សៀង | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៣- លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោកបណ្ឌិត | ទៀង សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | យុន គីមរៀង | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៣ នៅអគារ** B07 **បន្ទប់** 107

| | | | |
|---|---|---|---|
| ១- លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកបណ្ឌិត | អែ សុងហ៊ាង | មជ្ឈមណ្ឌល SEAMEO TED | សមាជិក |
| ៣- លោកបណ្ឌិត | កាន់ ពុទ្ធី | នាយកដ្ឋានបឋមសិក្សា | សមាជិក |
| ៤- លោកស្រី | សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៥- លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៦- លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | យុន ស៊ីណូត | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៤ នៅអគារ** B07 **បន្ទប់** 109

| | | | |
|---|---|---|---|
| ១- លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកបណ្ឌិត | លី គីមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៣- លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៤- លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- កញ្ញា | ណុច ស្រីនាង | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៥ នៅអគារ** B07 **បន្ទប់** 110

| | | | |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២- លោកបណ្ឌិត | ឈួក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិកា |
| ៤- លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោកបណ្ឌិត | សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

| | | | |
|---|---|---|---|
| ៦- លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧- លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨- កញ្ញា | ភាព សុខនី | វិទ្យាស្ថានជាតិអប់រំ | លេខា |

**ក្រុមទី៦ នៅ** B07 **បន្ទប់** 111

| | | | |
|---|---|---|---|
| ១- លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ៣- លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោកបណ្ឌិត | អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥- លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦- លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | លេខា |

II. **គណៈកម្មការកណ្តាល** B07 **បន្ទប់** 103

| | | | |
|---|---|---|---|
| ១- លោកស្រី | ធុក ផល្លីនី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | ធ្វើកំណត់ហេតុ |
| ៣- លោកស្រី | ទៀប ច័ន្ទវត្តី | វិទ្យាស្ថានជាតិអប់រំ | រៀបចំជាប់/ធ្លាក់ |
| ៤- កញ្ញា | ឈឺន លីន | វិទ្យាស្ថានជាតិអប់រំ | យកវត្តមាន |
| ៥- លោកស្រី | ម៉ម ចំប៉ី | វិទ្យាស្ថានជាតិអប់រំ | បូកពិន្ទុ/ផ្ទៀងផ្ទាត់ |

III. **គណៈកម្មការរដ្ឋបាល និងគណនេយ្យ**

| | | | |
|---|---|---|---|
| ១- លោក | គិន កោសល្ល | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- លោក | ឡេង បូរី | វិទ្យាស្ថានជាតិអប់រំ | រៀបចំបន្ទប់/សម្ភារៈ |
| ៣- លោកស្រី | អ៊ុំ សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | រៀបចំហិរញ្ញវត្ថុ |
| ៤- លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | យកវត្តមាន |

ថ្ងៃ ច័ន្ទ ៩រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ២០២៣

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**បានឃើញ និងឯកភាព**

**ប្រធានគណៈកម្មាធិការកំណែទម្រង់**

បណ្ឌិត ឌី_ខាំបូលី

**កន្លែងទទួល៖**

- ការិយាល័យ/ដេប៉ាតឺម៉ង់នៃ វជអ ដែលពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ.វជអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ២១៤៧ ខជអ. ស៊ក

## ប្រធានបទនិក្ខេបបទស្រាវជ្រាវ

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | គោត្តនាម-នាមនិស្សិត |
|---|---|---|
| ១ | ទស្សនៈគ្រូបង្រៀនចំពោះការគ្រប់គ្រងសាលារៀនរបស់នាយកសាលារៀនមធ្យមសិក្សាក្នុងខេត្តកណ្តាល | កង សុផារ៉ាមី |
| ២ | ទស្សនសហគមន៍ចំពោះកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២២ករណីសិក្សាខេត្តកំពង់ចាម | កន កុល |
| ៣ | កត្តាជះឥទ្ធិពលលើអាកប្បកិរិយារបស់សិស្សចំពោះការអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាករណីសិក្សាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសបាវិតខេត្តស្វាយរៀង | គង់ បូរ៉ា |
| ៤ | ឥរិយាបថ និងសមត្ថភាពគ្រូបង្រៀនចំពោះការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT)នៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តតាកែវ | គុយ វង្សា |
| ៥ | គោលការណ៍ណែនាំអំពីការគ្រប់គ្រងការអនុវត្តអធិការកិច្ចនៅកម្រិតបឋមសិក្សាក្នុងក្រុងស្ទឹងសែន ខេត្តកំពង់ធំ | គៅ លីមហ៊ាត់ |
| ៦ | ទស្សនៈរបស់បុគ្គលិកអប់រំ និងសហគមន៍ទៅលើប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលាមធ្យមសិក្សាបឋមភូមិករណីសិក្សាក្នុងស្រុករមាសហែកខេត្តស្វាយរៀង | ជុំ ជឿន |
| ៧ | ប្រសិទ្ធភាពនៃការគ្រប់គ្រងអគារធនធាន និងសាលាបណ្តាញក្នុងខេត្តរតនគិរី | ឈឹម នីនគោ |
| ៨ | ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងនៅសាលាមត្តេយ្យសិក្សាធនធានក្នុងខេត្តស្វាយរៀង | ញ៉ឹក កិត្យា |
| ៩ | ការសិក្សាប្រៀបធៀបនៃការអនុវត្តគោលការណ៍គណនេយ្យភាពសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ | ទៀន រតនៈ |
| ១០ | តម្រូវការអក្ខរកម្មឌីជីថលលើការបំពេញការងាររបស់គ្រូបង្រៀនក្នុងខេត្តកំពង់ស្ពឺ | ជឿន វង្សា |
| ១១ | ស្ថានភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំរបស់នាយកសាលាមធ្យមសិក្សាក្នុងខេត្តកំពង់ចាម | ពុំ សុធីតាមុនី |

| | | |
|---|---|---|
| ១២ | ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង | ពៅ ស្រីម៉ៅ |
| ១៣ | ស្ថានភាពនៃការអនុវត្តស្តង់ដាសាលាមធ្យមសិក្សាធនធាននៅក្នុងខេត្តកំពង់ឆ្នាំង | ព្រុំ ណារិន |
| ១៤ | ស្ថានភាពនៃការអនុវត្តក្របខ័ណ្ឌកម្មវិធីសាលាកុមារមេត្រីនៅកម្រិតបឋមសិក្សា ក្នុងខេត្តត្បូងឃ្មុំ | ម៉ុល មួយគា |
| ១៥ | ស្ថានភាពនៃការគ្រប់គ្រងការអនុវត្តដឹកនាំដំណើរការសាលារៀននៅតាមអនុវិទ្យាល័យក្នុង តំបន់លិចទឹកករណីសិក្សាខេត្តកំពង់ឆ្នាំង | ម៉ោញ សុធាវ័ន្ត |
| ១៦ | ស្ថានភាពនៃការបង្រៀន និងរៀនតាមបែបស្ទែម(STEM)នៅសាលារៀនជំនាន់ថ្មី ក្នុងខេត្តកណ្ដាល | មឿន ផល្លា |
| ១៧ | កម្រិតយល់ដឹងដោយគរុសិស្សលើអក្ខរកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាននៅគ្រឹះស្ថាន បណ្តុះបណ្តាលគ្រូក្នុងខេត្តព្រៃវែង | យ៉ម រិទ្ធី |
| ១៨ | ស្ថានភាពនៃការគ្រប់គ្រងធនធានរូបវន្តនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពង់ចាម | យឹម ធារ៉ា |
| ១៩ | ស្ថានភាពនៃការអនុវត្តគណនេយ្យភាពអ្នកដឹកនាំរបស់នាយកសាលាបឋមសិក្សាក្នុង ខេត្តត្បូងឃ្មុំ | លី សុផា |
| ២០ | ការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍសាលារៀននៅកម្រិតវិទ្យាល័យក្នុង ខេត្តកំពង់ស្ពឺ | សឹម ភក្តី |
| ២១ | ស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកំពត | សួង គីមសាន |
| ២២ | ស្ថានភាពនៃការគ្រប់គ្រងនិងប្រើប្រាស់បណ្ណាល័យនៅបឋមសិក្សាក្នុងខេត្តកំពត | សេន ម៉ៅ |
| ២៣ | ទស្សនៈរបស់នាយកសាលាលើកំណែទម្រង់ការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូមធ្យម សិក្សាទុតិយភូមិនៅកម្ពុជាករណីសិក្សាខេត្តតាកែវ | សែម ជ្រាន |
| ២៤ | ស្ថានភាពនៃការអនុវត្តការគ្រប់គ្រងសុខភាពសិក្សានៅសាលាបឋមសិក្សាក្នុងខេត្តតាកែវ | សោ សុផាត |
| ២៥ | ស្ថានភាពនៃការរៀបចំ និងអនុវត្តតេស្តស្តង់ដាកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង | ហ៊ីង សុវណ្ណា |
| ២៦ | កត្តាជះឥទ្ធិពលលើជម្រើសសិក្សាសម្រាប់អាជីពនាពេលអនាគតរបស់សិស្សមធ្យមសិក្សា បច្ចេកទេសនៅខេត្តកំពង់ឆ្នាំង កំពង់ធំ និងកំពង់ស្ពឺ | ហឿន សារ៉ុត |
| ២៧ | កត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សាមុខវិជ្ជាភាសាអង់គ្លេសសិស្សមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ | អិន ផល្លាក់ |
| ២៨ | ប្រសិទ្ធភាពនៃការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបដំណោះស្រាយបញ្ហាដោយបញ្ចូល ICT ក្នុងការបង្រៀនគណិតវិទ្យានៅវិទ្យាល័យនៅរាជធានីភ្នំពេញ | អ៊ាង ប៊ុនរឿង |
| ២៩ | ការសិក្សាឥទ្ធិពលលក្ខណៈនៃភាពជាអ្នកដឹកនាំបែបស្វ័យភាពរបស់នាយកទៅលើការពេញចិត្ត ក្នុងការបម្រើការងាររបស់គ្រូបង្រៀននៅកម្រិតវិទ្យាល័យ | អួន ពិសី |
| ៣០ | ស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យខេត្តតាកែវ | អៀក ចន្នី |
| ៣១ | ស្ថានភាពការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីការលើកកម្ពស់សុខភាពសិក្សានៅកម្រិត បឋមសិក្សាក្នុងខេត្តស្វាយរៀង | រ៉ា សុភ័ក្ត្រា |

| | | |
|---|---|---|
| ៣២ | ការអភិវឌ្ឍយុទ្ធសាស្ត្រលើកកម្ពស់គុណសម្បទាសតវត្សទី២១របស់យុវជនករណីសិក្សា ខេត្តសៀមរាប | មៀច បូរ៉ា |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ច័ន្ទ ១១រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០២៣

**នាយកវិទ្យាស្ថានជាតិអប់រំ** ហត្ថលេខា

បណ្ឌិត.សៀង សុវណ្ណា

**បានឃើញ និងឯកភាព**
**ប្រធានគណៈកម្មាធិការកំណែទម្រង់**

បណ្ឌិត ឌី_ខាំបូលី

**កន្លែងទទួល៖**
-សាមីខ្លួន " ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

# លិខិតអនុញ្ញាត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**វិទ្យាស្ថានជាតិអប់រំ**

**គោរពជូន**
**ឯកឧត្តមបណ្ឌិតនាយកវិទ្យាស្ថានជាតិអប់រំ**

អនុញ្ញាតឱ្យនិស្សិតឈ្មោះ ៖ **ពៅ ស្រីម៉ៅ**

ប្រធានបទស្រាវជ្រាវ ៖ ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង

ដើម្បីចូលរួម ៖ ការពារនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០

កាលបរិច្ឆេទការពារបញ្ចប់ ៖ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង ៧:០០ នាទីព្រឹកតទៅ

ទីកន្លែង ៖ វិទ្យាស្ថានជាតិអប់រំ

យើងខ្ញុំជាគ្រូណែនាំបង្គោល និងគ្រូណែនាំរង ពិតជាបានអនុញ្ញាតឱ្យនិស្សិតមានឈ្មោះខាងលើចូលរួមការពារនិក្ខេបបទបញ្ចប់ ដើម្បីបំពេញក្របខណ្ឌនៃការបណ្តុះបណ្តាលនៃថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២១-២០២៣ តាមការកំណត់របស់វិទ្យាស្ថានជាតិអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា។

ថ្ងៃសុក្រ ១២កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៣

**គ្រូណែនាំបង្គោល**

**អ៊ឹម គឿន**

**គ្រូណែនាំរង**

**សោន វណ្ណៈ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៤៧២អយក.ខ៩ន

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូណែនាំគោល និងគ្រូណែនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានទទួលការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គោត្តនាម-នាម គ្រូណែនាំគោល | គោត្តនាម-នាម គ្រូណែនាំរង | គោត្តនាម-នាម និស្សិត |
|---|---|---|---|
| ១ | បណ្ឌិត នៀ សុផន | បណ្ឌិត សៀង សុវណ្ណា | កង សុផាក់មី |
| ២ | បណ្ឌិត នី វង្ឃា | បណ្ឌិត ទី សុផល | កន កុល |
| ៣ | បណ្ឌិត អាន វ៉ូប្រាវ | បណ្ឌិត ទី សុផល | គង់ បូរ៉ា |
| ៤ | បណ្ឌិត ឌី ខាំបូលី | បណ្ឌិត កាន់ ពុទ្ធី | គុយ វង្ឃា |
| ៥ | បណ្ឌិត ម៉ម ចាន់សៀន | បណ្ឌិត ប៉ិច សៀង | គៅ លឹមហ៊ាត់ |
| ៦ | បណ្ឌិត ឡឹយ សុខគា | បណ្ឌិត គួយ សុគាន | ជុំ ជឿន |
| ៧ | លោក លឹម វ៉ាន់ | បណ្ឌិត គួយ សុគាន | ឈឹម ឌីនគោ |
| ៨ | បណ្ឌិត សៀង សុវណ្ណា | បណ្ឌិត នៀ សុផន | ញឹក កិត្យា |
| ៩ | លោកស្រី នូ ចន្ទី | បណ្ឌិត ឈាង សង្វាត | ទៀន រតនៈ |
| ១០ | បណ្ឌិត ឈាង សង្វាត | លោក ម៉ន មុនិន្ទ | ជឿន វង្ឃា |
| ១១ | បណ្ឌិត នៀ សុផន | បណ្ឌិត សៀង សុវណ្ណា | ពុំ សុធីតាមុនី |
| ១២ | បណ្ឌិត អ៊ឹម គឿន | បណ្ឌិត សោម វណ្ណៈ | ពៅ ស្រីម៉ៅ |
| ១៣ | បណ្ឌិត នូវ វ៉ៃ | បណ្ឌិត នៀ សុផន | ព្រុំ ណារិន |
| ១៤ | បណ្ឌិត អ៊ឹម គឿន | បណ្ឌិត នី វង្ឃា | ម៉ុល មួយគា |
| ១៥ | បណ្ឌិត នូវ វ៉ៃ | លោក ចាប រតនា | ម៉ោញ សុជាវត្ថ |
| ១៦ | លោកស្រី ប៊ុន សុផានី | លោក ថៃ ហេង | មឿន ផល្លា |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

| | | | |
|---|---|---|---|
| ១៧ | បណ្ឌិត លី គិមឡុង | លោក ចាន់ រ៉ាដា | យ៉ម វុទ្ធី |
| ១៨ | លោក ឡុច ចាន់ថន | បណ្ឌិត បូ ច័ន្ទគុលិកា | យឹម ផារ៉ា |
| ១៩ | បណ្ឌិត សិត សេង | បណ្ឌិត អាន វ៉ូប្រាវ | លី សុផា |
| ២០ | បណ្ឌិត គួយ សុគាន | បណ្ឌិត នី រដ្ឋា | សឹម ភក្តី |
| ២១ | លោក ចាន់ ធឿន | បណ្ឌិត ឈន ថន | សួង គឹមសាន |
| ២២ | បណ្ឌិត ឈន ថន | បណ្ឌិត សោន វណ្ណៈ | សេន ម៉ៅ |
| ២៣ | បណ្ឌិត សិត សេង | បណ្ឌិត នូវ វីរ៉ា | សែម ជ្រាន |
| ២៤ | បណ្ឌិត លី គិមឡុង | បណ្ឌិត ឌី ខាំបូលី | សោ សុផាត |
| ២៥ | បណ្ឌិត អាន វ៉ូប្រាវ | លោក ឡុច ចាន់ថន | ហ៊ឹង សុវណ្ណា |
| ២៦ | លោក ចាប រតនា | បណ្ឌិត ម៉ម ចាន់សៀន | ហឿន សារ៉ុត |
| ២៧ | បណ្ឌិត សោន វណ្ណៈ | លោក ប៉ូ ប៊ុន្នន | អ៊ិន ផល្លាក់ |
| ២៨ | លោក ចាន់ រ៉ាដា | បណ្ឌិត សិត សេង | អ៊ាង ប៊ុនឿង |
| ២៩ | បណ្ឌិត មាឃ ចាន់ថេង | បណ្ឌិត លី គិមឡុង | អួន ពិសី |
| ៣០ | បណ្ឌិត ឡឹយ សុខគា | បណ្ឌិត ឈន ថន | អៀក ចន្ទី |
| ៣១ | បណ្ឌិត ម៉ម ចាន់សៀន | លោក ចាប រតនា | វ៉ា សុភ័ក្រ្តា |
| ៣២ | បណ្ឌិត ជ័យ សារិន | បណ្ឌិត ឡឹយ សុខគា | មៀច បូរ៉ា |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០២៣
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ -ឯកសារ វដអ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ«ក»កម្រងសំណួរសម្រាប់មាតាបិតាសិស្ស

នាងខ្ញុំឈ្មោះ **ពៅ ស្រីម៉ៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សិក្សាក្រោមប្រធានបទ **«ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង»**។

នាងខ្ញុំសូមគោរពអញ្ជើញមាតាបិតាសិស្សនិងសមាជិកគ្រួសារចូលរួមក្នុងការផ្តល់ចម្លើយលើកម្រងសំណួរស្រាវជ្រាវខាងក្រោម ក្នុងគោលបំណងឈ្វេងយល់ពីការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ នៅតាមសាលាបឋមសិក្សានានាក្នុងខេត្តស្វាយរៀង ។

សូមគោរពថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការនិងការចំណាយពេលវេលាដ៏មានតម្លៃរបស់មាតាបិតាសិស្ស និងសមាជិកគ្រួសារក្នុងការបំពេញកម្រងសំណួររបស់នាងខ្ញុំ។ សូមអាននូវសេចក្តីណែនាំមុននឹងធ្វើការសម្រេចចិត្តឆ្លើយសំណួរតាមផ្នែកនីមួយៗ និងឆ្លើយឱ្យបានគ្រប់សំណួរតាមស្ថានភាពពិតជាក់ស្តែង ដោយមិនចាំបាច់ដាក់ឈ្មោះទេ។ នាងខ្ញុំសូមអះអាងថារាល់ចម្លើយរបស់មាតាបិតាសិស្សនិងសមាជិកគ្រួសារ និងរក្សាទុកជាការសម្ងាត់ ដោយពុំមានផលប៉ះពាល់អ្វីទាំងអស់ដល់គ្រួសារខ្លួនឯងឡើយ ។

### ផ្នែកទី១៖ព័ត៌មានអំពីស្ថានភាពទូទៅ

**សូមមេត្តាបំពេញចម្លើយឬគូសសញ្ញា (√) ក្នុងប្រអប់ □ ជាចម្លើយតែមួយប៉ុណ្ណោះ ដែលត្រូវជាមួយនឹងស្ថានភាពទូទៅ**

១. អ្នកចូលរួម.............................

២. ភេទ □ ប្រុស □ ស្រី

៣.អាយុ □ ២០ឆ្នាំ-៣០ឆ្នាំ □៣១ឆ្នាំ-៤០ឆ្នាំ □៤១ឆ្នាំឡើងទៅ

៤.កម្រឹតវប្បធម៌ □ បឋមសិក្សា □ ទុតិយភូមិ □ បរិញ្ញាបត្រ □ ខ្ពស់ជាងបរិញ្ញាបត្រ

៥. មុខរបរ.....................

៦. អាស័យដ្ឋានបច្ចុប្បន្ន....................................................

៧.សមាជិកគ្រួសារដែលកំពុងសិក្សានៅបឋមសិក្សា.......................

### ផ្នែកទី២៖ ដើម្បីកំណត់ទម្រង់ ការលើកទឹកចិត្ត នៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ

សំណួរទី១៖ តើការអប់រំមានសារៈសំខាន់យ៉ាងណា? (១=មិនសំខាន់សោះ, ២=មិនសំខាន់, ៣=សំខាន់ខ្លះ, ៤=សំខាន់, ៥=សំខាន់បំផុត)

□១ □២ □៣ □៤ □៥

សំណួរទី ២: តើអ្នកចូលរួមក្នុងការអប់រំយ៉ាងដូចម្តេច?

□ បញ្ជូនកូនទៅសាលារៀន □ ផ្សព្វផ្សាយព័ត៌មានអប់រំ

□ លើកទឹកចិត្តកុមារឱ្យសិក្សា □ ប្រមូលកុមារនៅក្នុងសហគមន៍

□ ចូលរួមកិច្ចប្រជុំ □ ផ្សេងៗ........................

សំណួរទី ៣: តើអ្នកគាំទ្រកូនរបស់អ្នករៀននៅផ្ទះយ៉ាងដូចម្ដេច?

□ ការបង្រៀនកុមារ □ ពិនិត្យមើលសៀវភៅកត់ត្រារបស់កុមារ

□ លើកទឹកចិត្តកុមារឱ្យសិក្សា □ ផ្សេងៗ.....................

សំណួរទី៤៖ តើអ្នកបានទៅសាលារៀនញឹកញាប់ប៉ុណ្ណា?

□ ជារៀងរាល់ថ្ងៃ □ ម្ដងក្នុងមួយសប្ដាហ៍

□ ច្រើនជាងម្ដងក្នុងមួយសប្ដាហ៍ □ ម្ដងក្នុងមួយឆ្នាំ

□ ពេលណាដែលបានអញ្ជើញ □ មិនដែល

សំណួរទី៥៖ តើការទៅសាលារៀនមានហេតុផលអ្វីខ្លះ?

□ ការចុះឈ្មោះកុមារ □ នាំកុមារទៅសាលារៀន

□ ជួបជាមួយលោកគ្រូ អ្នកគ្រូ □ ផ្សេងៗ......

សំណួរទី៦៖ តើអ្នកប្រាស្រ័យទាក់ទងជាមួយសាលាដោយរបៀបណា?

□ ទៅសាលារៀន □ ការហៅទូរស័ព្ទ □មានការអញ្ជើញ

□ ចូលរួមការប្រជុំ □ ផ្សេងៗ …………

សំណួរទី៧៖ តើសាលាជាកម្មសិទ្ធិរបស់អ្នកណា?

□ រដ្ឋាភិបាល □ យើងទាំងអស់គ្នា □ នាយកសាលា

□ គ្រូបង្រៀន □ ផ្សេងៗ...................

សំណួរទី ៨៖ តើអ្នករួមចំណែកអ្វីខ្លះក្នុងការអប់រំ/ការអភិវឌ្ឍន៍សាលារៀន?

□ បរិច្ចាកថវិកា □ បរិច្ចាកសម្ភារៈ □ ចូលរួមចំណែកការងារ

□ ថែទាំសាលារៀន □ ផ្សេងទៀត........................

សំណួរ៩៖តើអ្នកធ្លាប់ចូលរួមក្នុងសកម្មភាពរបស់សាលារៀនដូចខាងក្រោម?

□ ចូលរួមកិច្ចប្រជុំ □ ចូលរួមចំណែកថវិកា សម្ភារៈ កម្លាំងពលកម្ម...

□ ណែនាំសាលាអំពីសកម្មភាព/ផែនការ □ ចូលរួមក្នុងការបើកបវេសនកាលឆ្នាំសិក្សាថ្មី

□ធ្វើការសម្រេចចិត្តលើសកម្មភាពរបស់សាលា □ផ្សេងៗ...............

សំណួរទី១០៖ តើអ្នកគិតថាការរួមចំណែកធនធានមានសារៈសំខាន់ឬទេ? (១=មិនសូវសំខាន់, ២=មិនសំខាន់, ៣=សំខាន់ខ្លះ, ៤=សំខាន់, ៥=សំខាន់បំផុត)

□១ □២ □៣ □៤ □៥

សំណួរទី១១៖ តើអ្វីជាការលើកទឹកចិត្តរបស់អ្នកក្នុងការចូលរួមក្នុងការអប់រំ?

□ សម្រាប់ការអប់រំរបស់កុមារ □ដើម្បីអភិវឌ្ឍសាលារៀន

□ដើម្បីអនាគតរបស់កូនចៅ □ដើម្បីកាត់បន្ថយអនាធិបតេយ្យ □ផ្សេងៗ

សំណួរទី១២៖តើអ្នកធ្លាប់ចូលរួមស្វែងរកថវិកាសម្រាប់ឧបត្ថម្ភដល់សាលារៀនដោយវិធីណា?

□ បុណ្យផ្កា □ បុណ្យសាលា □ បុណ្យអង្គាសបច្ច័យ

□ បុណ្យកឋិន □ ផ្សេងៗ.....................

សំណួរទី១៣៖ តើអ្នកចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗដែលរៀបចំដោយសាលា?

□ ពិពណ៌ស្នាដៃសិស្ស □ ការប្រកួតកីឡា □ ពិធីចែករង្វាន់សិស្សពូកែ

□ ទស្សនកិច្ចសិក្សា □ ផ្សេងៗ............................

សំណួរទី១៤៖ តើអ្នកចូលរួមថែរក្សាទ្រព្យសម្បត្តិរបស់សាលារៀនដោយរបៀបណា?

□ ចាត់ទុកទ្រព្យសម្បត្តិសាលាជាសម្បត្តិរួម □ ជួយថែរក្សានិងការពារ

□ ជួយជួសជុល □ ជួយយាមកាម □ ផ្សេងៗ.....................

សំណួរទី១៥៖តើអ្នកចូលរួមផ្តល់នូវមូលដ្ឋានសម្ភារៈអ្វីខ្លះដើម្បីបម្រើឱ្យការរៀននិងបង្រៀនដល់សាលារៀន?

□ សម្ភារៈសម្រាប់ផលិត □ សម្ភារៈសម្រាប់ពិសោធន៍ □ សម្ភារៈសម្រាប់ឧបទេស

□ សម្ភារៈសម្រាប់សិក្សា(សៀវភៅ ប៊ិក ជីស ហ្វឺត...) □ ផ្សេងៗ.............

**ផ្នែកទី៣៖ឧបសគ្គនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ**

សំណួរទី១៦៖ តើអ្វីជាឧបសគ្គនៃការចូលរួមក្នុងការអប់រំ?

□ ជីវភាពក្រីក្រ □ ផ្ទះនៅឆ្ងាយពីសាលារៀន

□ រវល់ □ មិនចាប់អារម្មណ៍ចូលរួម

□ ផ្សេងៗ

សំណួរទី ១៧: តើអ្នកមានយោបល់ណាមួយសម្រាប់ការកែលម្អសាលារៀនដែរឬទេ?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

......................................................................

# ឧបសម្ព័ន្ធ«ខ»កម្រងសំណួរសម្រាប់គ្រូបង្រៀន

នាងខ្ញុំឈ្មោះ **ពៅ ស្រីម៉ៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សិក្សាក្រោមប្រធានបទ **«ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង»**។

នាងខ្ញុំសូមគោរពអញ្ជើញលោកគ្រូនិងអ្នកគ្រូចូលរួមក្នុងការផ្តល់ចម្លើយលើកម្រងសំណួរស្រាវជ្រាវខាងក្រោម ក្នុងគោលបំណងឈ្វេងយល់ពីការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ នៅតាមសាលាបឋមសិក្សានានាក្នុងខេត្តស្វាយរៀង ។

សូមគោរពថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការនិងការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកគ្រូនិងអ្នកគ្រូក្នុងការបំពេញកម្រងសំណួររបស់នាងខ្ញុំ។ សូមអាននូវសេចក្តីណែនាំមុននឹងធ្វើការសម្រេចចិត្តឆ្លើយសំណួរតាមផ្នែកនីមួយៗ និងឆ្លើយឱ្យបានគ្រប់សំណួរតាមស្ថានភាពពិតជាក់ស្តែង ដោយមិនចាំបាច់ដាក់ឈ្មោះទេ។ នាងខ្ញុំសូមអះអាងថារាល់ចម្លើយរបស់លោកគ្រូអ្នកគ្រូ នឹងរក្សាទុកជាការសម្ងាត់ ដោយទិន្នន័យដែលប្រមូលបានសម្រាប់ប្រើប្រាស់តែការសិក្សាស្រាវជ្រាវនេះប៉ុណ្ណោះ។

## ផ្នែកទី១៖ព័ត៌មានអំពីស្ថានភាពទូទៅ

**សូមមេត្តាបំពេញចម្លើយឬគូសសញ្ញា (√) ក្នុងប្រអប់ □ ជាចម្លើយតែមួយប៉ុណ្ណោះ ដែលត្រូវជាមួយនឹងស្ថានភាពទូទៅ**

១. អ្នកចូលរួម.............................

២. ភេទ □ ប្រុស □ ស្រី

៣.អាយុ □ ២០ឆ្នាំ-៣០ឆ្នាំ □៣១ឆ្នាំ-៤០ឆ្នាំ □៤១ឆ្នាំឡើងទៅ

៤.កម្រឹតវប្បធម៌□ បឋមសិក្សា □ ទុតិយភូមិ □ បរិញ្ញាបត្រ

□ ខ្ពស់ជាងបរិញ្ញាបត្រ

៥.បទពិសោធការងារ □តិចជាង២ឆ្នាំ □២-៥ឆ្នាំ □៥-១០ឆ្នាំ □១១-១ឆ្នាំ

□ លើសពី១៥ឆ្នាំឡើងទៅ

៦. អាស័យដ្ឋានបច្ចុប្បន្ន......................................................................................

៧.កំពុងបង្រៀននៅបឋមសិក្សា...........................................................................

## ផ្នែកទី២៖ ដើម្បីកំណត់ទម្រង់ ការលើកទឹកចិត្តនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ

១.តើទំនាក់ទំនងរវាងគ្រូ និងឪពុកម្តាយមានទំនាក់ទំនងមានសារៈសំខាន់ដែរឬទេ?

(១=មិនសូវសំខាន់, ២=មិនសំខាន់, ៣=សំខាន់ខ្លះ, ៤=សំខាន់, ៥=សំខាន់បំផុត)

□ ១ □ ២ □ ៣ □ ៤ □ ៥

២.តើអ្នកប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយ និងសមាជិកសហគមន៍ដោយរបៀបណា?

□ ទៅជួបនៅគេហដ្ឋាន □ ការហៅទូរស័ព្ទ □មានការអញ្ជើញ

□ ចូលរួមការប្រជុំ □ ផ្សេងៗ …………

៣.តើសហគមន៍ចូលរួមក្នុងសកម្មភាពសាលារបស់អ្នកខាងក្រោមដែរឬទេ?

□ចូលរួមកិច្ចប្រជុំ □ចូលរួមចំណែកថវិកា សម្ភារៈ កម្លាំងពលកម្ម...

□ ណែនាំសាលាអំពីសកម្មភាព/ផែនការជាក់លាក់ □ចូលរួមក្នុងសកម្មភាពបង្រៀន

□ ធ្វើការសម្រេចចិត្តលើសកម្មភាពរបស់សាលា □ ផ្សេងៗ..........

៤. តើអ្នកណាចូលរួមញឹកញាប់ជាង?

□ មាតាបិតាសិស្ស □ អាជ្ញាធរមូលដ្ឋាន □ គណៈកម្មការទ្រទ្រង់សាលា

□ អង្គការក្រៅរដ្ឋាភិបាល □ផ្សេងៗ...................

៥.ហេតុអ្វីបានជាពួកគេសម្រេចចិត្តចូលរួម? (កត្តាខាងក្នុង និងខាងក្រៅ)

□ សម្រាប់ការអប់រំរបស់កុមារ □ ដើម្បីអភិវឌ្ឍសាលារៀន

□ ដើម្បីអនាគតរបស់កូនចៅ □ ដើម្បីកាត់បន្ថយអនាធិបតេយ្យ□ ផ្សេងៗ ………

៦.តើអ្នកធ្លាប់ចូលរួមក្នុងសកម្មភាពរបស់សាលារៀនដូចខាងក្រោម?

□ ចូលរួមកិច្ចប្រជុំជាមួយសហគមន៍□ចូលរួមចំណែកថវិកា សម្ភារៈកម្លាំងពលកម្ម...

□ ណែនាំអំពីសកម្មភាព/ផែនការសាលា □ ផ្តល់ព័ត៌មានអំពីការសិក្សារបស់សិស្ស

□ ធ្វើការសម្រេចចិត្តលើសកម្មភាពរបស់សាលា □ផ្សេងៗ...............

៧.តើសកម្មភាពក្រៅសាលាអ្វីខ្លះ ដែលជួយឱ្យសិស្សក្លាយជាពលរដ្ឋល្អ?

□ជួយបង្រៀនកុមារ(ក្លឹបសិក្សា)

□បង្រៀនរបាំចម្រៀងភ្លេងនិងសម្តែង(ក្លឹបវប្បធម៌សិល្បះ)

□បង្រៀនកីឡាដល់កុមារ(ក្លឹបកីឡា)

□បំផុសគំនិតឱ្យកុមារចូលចិត្តចិត្តហាត់ប្រាណលេងកីឡា

□ផ្សេងៗ...................................

៨.ហេតុអ្វីបានជាអ្នកទំនាក់ទំនងជាមួយឪពុកម្តាយរបស់សិស្ស?

□ផ្តល់ព័ត៌មាន □សហការគ្នា □តាមដានការសិក្សានៅផ្ទះរបស់សិស្ស

□វាយតម្លៃការសិក្សារបស់សិស្ស □ផ្សេងៗ..........

៩.តើអ្នកធ្លាប់ចូលរួមជាមួយសហគមន៍ស្វែងរកថវិកាសម្រាប់ឧបត្ថម្ភដល់សាលារៀនដោយវិធីណា?

□ បុណ្យផ្កា □ បុណ្យសាលា □ បុណ្យអង្គាសបច្ច័យ

□ បុណ្យកឋិន □ ផ្សេងៗ..........

១០.តើអ្នកចូលរួមថែរក្សាទ្រព្យសម្បត្តិរបស់សាលារៀនដោយរបៀបណា?

□ ចាត់ទុកទ្រព្យសម្បត្តិសាលាជាសម្បត្តិរួម □ ជួយថែរក្សានិងការពារ

□ ជួយជួសជុល □ ជួយយាមកាម □ ផ្សេងៗ.........

១១.តើអ្វីជាការលើកទឹកចិត្តអ្នកក្នុងការអប់រំកុមារ?

□ សម្រាប់ការអប់រំរបស់កុមារ □ ដើម្បីអនាគតរបស់កូនចៅជំនាន់ក្រោយ

□ ដើម្បីអភិវឌ្ឍសាលារៀន □ ដើម្បីកាត់បន្ថយអនាធិបតេយ្យ □ ផ្សេងៗ ………

១២.តើអ្នកបានទទួលនូវមូលដ្ឋានសម្ភារៈអ្វីខ្លះ ដើម្បីបម្រើឱ្យការរៀននិងបង្រៀនពីសហគមន៍?

□ សម្ភារៈសម្រាប់ផលិត □ សម្ភារៈសម្រាប់ពិសោធន៍ □ សម្ភារៈសម្រាប់ឧបទេស

□ សម្ភារៈសម្រាប់សិក្សា(សៀវភៅ ប៊ិក ដីស ហ្វឹត...) □ ផ្សេងៗ.............

១៣.តើមានការផ្លាស់ប្តូរអ្វីខ្លះដែលបានធ្វើឡើងជាលទ្ធផលនៃការចូលរួមរបស់សហគមន៍?

□ការអប់រំមានភាពប្រសើរឡើង □កូនចៅបានសិក្សារៀនសូត្រគ្រប់គ្នា

□សហគមន៍មានការអភិវឌ្ឍ □ពលរដ្ឋមានការងារល្អ □ផ្សេងៗ.........

១៤.តើធ្វើយ៉ាងណាដើម្បីឱ្យមាតាបិតាសិស្សមានទំនាក់ទំនងល្អជាមួយសាលាក្នុងការអប់រំ?

□មានអភិបាលកិច្ចល្អ(តម្លាភាព ទំនួលខុសត្រូវ ប្រសិទ្ធិភាព និងការចូលរួម)

□មានវិមជ្ឈការក្នុងសាលារៀន □មានប្រជាធិបតេយ្យ

□ផ្តល់ផលប្រយោជន៍គ្នាទៅវិញទៅមក □ផ្សេងៗ...........

**ផ្នែកទី៣៖ឧបសគ្គនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ**

១៥.ហេតុអ្វីបានជាសហគមន៍មិនចូលរួម?

□ ជីវភាពក្រីក្រ □ ផ្ទះនៅឆ្ងាយពីសាលារៀន □ រវល់ □ មិនចាប់អារម្មណ៍ចូលរួម □ ផ្សេងៗ..............

១៦.អ្វីដែលអ្នកគិតថាគួរធ្វើ ដើម្បីទទួលបានការចូលរួមកាន់តែច្រើនពីសហគមន៍?

..............................................................................................................................

..............................................................................................................................

..............................................................................................................................

...................................................................................

# សំណួរសម្រាប់សម្ភាសសន៍

## ឧបសម្ព័ន្ធ«គ»សំណួរសម្ភាសន៍សម្រាប់នាយក

នាងខ្ញុំឈ្មោះ **ពៅស្រីម៉ៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សិក្សាក្រោមប្រធានបទ«**ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង**»។

គោលបំណងនៃការសម្ភាសនេះគឺះដើម្បីឈ្វេងយល់នាយកសាលាលើអំពីទម្រង់និងដំណើរការនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំនិងវិធីសាស្ត្រនៃការគៀរគរសហគមន៍ដែលសាលាបានប្រើ។

ទិន្នន័យដែលប្រមូលបានពីការសម្ភាសនេះ គឺសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ទិន្នន័យជាក់លាក់ដែលប្រមូលបានពីលោក/លោកស្រីមានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ការវិភាគ ឆ្លើយតបនឹងប្រធានបទខាងលើ។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការនិងការចំណាយពេលវេលាដ៏មានតម្លៃរបស់នាយកនាយិកាក្នុងការផ្តល់ព័ត៌មានកម្រងសំណួរសម្ភាសន៍របស់នាងខ្ញុំ។នាងខ្ញុំសូមអះអាងថារាល់ចម្លើយរបស់នាយកនាយិកានឹងរក្សាទុកជាការសម្ងាត់ដោយពុំមានផលប៉ះពាល់អ្វីទាំងអស់ដល់លោកនាយកនិងសាលារៀនឡើយ ។

**ផ្នែកទី១-ព័ត៌មានទូទៅះ**

១)ឈ្មោះអ្នកធ្វើបទសម្ភាសះ.......................................................................

២)ថ្ងៃខែឆ្នាំសម្ភាសះ...........................................វេលាម៉ោងះ...................

៣)អង្គភាព/ទីកន្លែងះ...........................................................................

៤)ឈ្មោះអ្នកចូលរួមះ............................................................................

៥) រៀបចំការសម្ភាសះ ដោយផ្ទាល់ ទូរសព្ទ អនឡាយ .

**ផ្នែកទី២ះទម្រង់នៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ**

សំណួរទី ១ តើសហគមន៍មានការចូលរួមក្នុងការអប់រំអ្វីខ្លះ ?

សំណួរទី ២ តើការចូលរួមរបស់សហគមន៍បានកើតឡើងយ៉ាងដូចម្តេចក្នុង ការអប់រំ/សាលា? (ការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ ការវាយតម្លៃ)

សំណួរទី ៣ តើភាគីពាក់ព័ន្ធណាខ្លះចូលរួមក្នុងសាលា/ការអប់រំ?

សំណួរទី ៤ តើអ្នក/សាលាបានធ្វើអ្វីខ្លះដើម្បីឱ្យសហគមន៍ចូលរួមសាលារៀន?

សំណួរទី ៥ តើកត្តាអ្វីខ្លះដែលជំរុញ/លើកទឹកចិត្តពួកគេចូលរួមក្នុងកាអប់រំនៅបឋមសិក្សា?

**ផ្នែកទី៣ះបញ្ហាប្រឈមក្នុងការចូលរួមរបស់សហគមន៍ក្នុងការអប់រំ**

សំណួរទី៦ តើអ្វីជាបញ្ហាប្រឈមនៃការចូលរួមរបស់សហគមន៍ក្នុងដំណើរការសាលារៀន?

សំណួរទី ៧ តើទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ មានលក្ខណៈដូចម្តេច?

សំណួរទី៨ ក្នុងនាមជានាយកសាលា តើអ្នកមានវិធីសាស្ត្របែបណាក្នុងការដោះស្រាយ/ធ្វើឱ្យសហគមន៍ងាកមកចូលរួមក្នុងការអប់រំ?

# ឧបសម្ព័ន្ធ«ឃ»សំណួរសម្ភាសន៍សម្រាប់គណៈកម្មការគ្រប់គ្រងសាលារៀន

នាងខ្ញុំឈ្មោះ **ពៅស្រីម៉ៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សិក្សាក្រោមប្រធានបទ **«ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង»**។

គោលបំណងនៃការសម្ភាសនេះគឺះដើម្បីឈ្វេងយល់អំពីគណៈកម្មការទ្រទ្រង់សាលារៀន លើទម្រង់និងដំណើរការនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ។ ទិន្នន័យដែលប្រមូលបានពីការសម្ភាសនេះ គឺសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ដើម្បីស្វែងរកភាពសមស្របលើប្រធានបទ ទិន្នន័យជាក់លាក់តាមគុណវិស័យនៃសំណួរខាងក្រោមបានរៀបចំសម្រាប់សម្ភាសន៍ដែលប្រមូលបានពីលោក/លោកស្រីមានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ការវិភាគឆ្លើយតបនឹងប្រធានបទខាងលើ។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការនិងការចំណាយពេលវេលាដ៏មានតម្លៃរបស់លោក លោកស្រីក្នុងការផ្តល់ព័ត៌មានកម្រងសំណួរសម្ភាសន៍របស់នាងខ្ញុំ។ នាងខ្ញុំសូមអះអាងថារាល់ចម្លើយរបស់លោក លោកស្រីនឹងរក្សាទុកជាការសម្ងាត់ដោយពុំមានផលប៉ះពាល់អ្វីទាំងអស់ដល់លោក លោកស្រីឡើយ ។

## ផ្នែកទី១ៈព័ត៌មានទូទៅៈ

១)ឈ្មោះអ្នកធ្វើបទសម្ភាសៈ.......................................................................

២)ថ្ងៃខែឆ្នាំសម្ភាសៈ.............................................វេលាម៉ោងៈ...................

៣)អង្គភាព/ទីកន្លែងៈ.....................................................................................

៤)ឈ្មោះអ្នកចូលរួមៈ.....................................................................................

៥) រៀបចំការសម្ភាសៈ☐ ដោយផ្ទាល់ ☐ទូរសព្ទ ☐អនឡាយ

## ផ្នែកទី២ៈទម្រង់នៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ

សំណួរទី១ តើសហគមន៍មានការចូលរួមក្នុងការអប់រំអ្វីខ្លះ?

សំណួរទី២ តើការចូលរួមរបស់សហគមន៍បានកើតឡើងយ៉ាងដូចម្តេចក្នុងការអប់រំ/សាលា?

(ការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ ការវាយតម្លៃ)

សំណួរទី៣ តើភាគីពាក់ព័ន្ធណាខ្លះចូលរួមក្នុងសាលា/ការអប់រំ?

សំណួរទី៤ តើអ្នក/សាលាបានធ្វើអ្វីខ្លះដើម្បីឱ្យសហគមន៍ចូលរួមសាលារៀន?

សំណួរទី៥ តើកត្តាអ្វីខ្លះដែលជំរុញ/លើកទឹកចិត្តពួកគេឱ្យចូលរួមក្នុងការអប់រំនៅបឋមសិក្សា?

## ផ្នែកទី៣ៈបញ្ហាប្រឈមក្នុងការចូលរួមរបស់សហគមន៍ក្នុងការអប់រំ

សំណួរទី៦ តើបញ្ហាប្រឈមអ្វីខ្លះនៃការចូលរួមរបស់សហគមន៍ក្នុងដំណើរការសាលារៀន?

សំណួរទី៧ តើទំនាក់ទំនងរវាង សាលារៀន និងសហគមន៍ ក្នុងវិស័យអប់រំមានលក្ខណៈដូចម្តេច?

សំណួរទី៨ ក្នុងនាមជាគណៈកម្មការទ្រទ្រង់សាលា តើលោក លោកស្រីមានវិធីសាស្ត្របែបណាក្នុង ការដោះស្រាយ/ធ្វើឱ្យសហគមន៍ងាកមកចូលរួមក្នុងការអប់រំ?

## ឧបសម្ព័ន្ធ«ខ»សំណួរសម្ភាសន៍សម្រាប់ព្រះចៅអធិការវត្ត

នាងខ្ញុំឈ្មោះ **ពៅស្រីម៉ៅ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សិក្សាក្រោមប្រធានបទ **«ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំនៅកម្រិតបឋមសិក្សាក្នុងខេត្តស្វាយរៀង»**។

គោលបំណងនៃការសម្ភាសនេះគឺះដើម្បីឈ្វេងយល់អំពីទម្រង់និងដំណើរការនៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ ។ ទិន្នន័យដែលប្រមូលបានពីការសម្ភាសនេះគឺសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។

ដើម្បីស្វែងរកភាពសមស្របលើប្រធានបទ ទិន្នន័យជាក់លាក់តាមគុណវិស័យនៃសំណួរខាងក្រោមបានរៀបចំសម្រាប់សម្ភាសន៍ដែលប្រមូលបានពីព្រះចៅអធិការវត្តមានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ការវិភាគឆ្លើយតបនឹងប្រធានបទខាងលើ។
សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការនិងការចំណាយពេលវេលាដ៏មានតម្លៃរបស់ព្រះចៅអធិការក្នុងការផ្តល់ព័ត៌មានកម្រងសំណួរសម្ភាសន៍របស់នាងខ្ញុំ។

នាងខ្ញុំសូមអះអាងថារាល់ចម្លើយរបស់ព្រះចៅអធិការវត្តនឹងរក្សាទុកជាការសម្ងាត់ដោយពុំមានផលប៉ះពាល់អ្វីទាំងអស់ដល់ព្រះចៅអធិការឡើយ ។

### ផ្នែកទី១៖ ព័ត៌មានទូទៅ៖

១)ឈ្មោះអ្នកធ្វើបទសម្ភាស៖.......................................................................

២)ថ្ងៃខែឆ្នាំសម្ភាស៖................................................វេលាម៉ោង៖...................

៣)អង្គភាព/ទីកន្លែង៖..................................................................................

៤)ឈ្មោះអ្នកចូលរួម៖...................................................................................

៥) រៀបចំការសម្ភាស៖□ ដោយផ្ទាល់ □ទូរសព្ទ □អនឡាយ

### ផ្នែកទី២៖ ទម្រង់នៃការចូលរួមរបស់សហគមន៍ក្នុងការអប់រំ

សំណួរទី១ តើវត្តអារាមមានការចូលរួមក្នុងការអប់រំអ្វីខ្លះ?

សំណួរទី២ តើការចូលរួមរបស់វត្តអារាមបានកើតឡើងយ៉ាងដូចម្តេចក្នុងការអប់រំ/សាលា? (ការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ ការវាយតម្លៃ)

សំណួរទី៣ តើអ្វីទៅជាការចូលរួមរបស់សហគមន៍ក្នុងការអប់រំ?

សំណួរទី៤ តើព្រះអង្គចូលរួមក្នុងការអប់រំដោយរបៀបណា? (លុយ ពលកម្ម សម្ភារៈ គំនិត ការសម្រេចចិត្ត)

### ផ្នែកទី៣៖បញ្ហាប្រឈមក្នុងការចូលរួមរបស់សហគមន៍ក្នុងការអប់រំ

សំណួរទី៥ តើអ្វីជាបញ្ហាប្រឈមរបស់វត្តអារាមនិងសហគមន៍ក្នុងដំណើរការសាលារៀន?

សំណួរទី៦ តើទំនាក់ទំនងរវាង សាលារៀន និងវត្តអារាមក្នុងវិស័យអប់រំមានលក្ខណៈដូចម្តេច?